# គបស

# សៀវភៅសម្រាប់គ្រូ

## គម្រោងនៃការបង្កើតសិស្ស

## Design for Discipleship

## Leader's Guide


*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to [www.cambodianchristianresources.com/dfd-leaders/](www.cambodianchristianresources.com/dfd-leaders/)*

# មាតិកា

ការចាប់ផ្ដើម

សៀវភៅទី១

ជីវិតរបស់លោកអ្នកនៅក្នុងព្រះគ្រីស្ទ

សៀវភៅទី២

អ្នកដើរតាមព្រះយេស៊ូវដែលពេញដោយព្រះវិញ្ញាណ

សៀវភៅទី៣

ការដើរជាមួយព្រះគ្រីស្ទ

សៀវភៅទី៤

អត្តចរិតរបស់អ្នកដើរតាមព្រះយេស៊ូវ

សៀវភៅទី៥

មូលដ្ឋានគ្រឹះនៃជំនឿ

សៀវភៅទី៦

ការរីកចម្រើនក្នុងភាពជាសិស្សរបស់ព្រះយេស៊ូវ

សៀវភៅទី៧

សេចក្ដីសង្ឃឹមរបស់យើងនៅក្នុងព្រះគ្រីស្ទ

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to [www.cambodianchristianresources.com/dfd-leaders/](www.cambodianchristianresources.com/dfd-leaders/)*

# ការចាប់ផ្ដើម

ព្រះគម្ពីរគឺជាកំណត់ត្រាមួយដែលបានចែងពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះយើងរាល់គ្នា ។ ទ្រង់បានប្រទានព្រះគម្ពីរនេះមកដើម្បីជាសារប្រយោជន៍របស់យើង ។ តាមរយៈបទគម្ពីរយើងអាចចាប់ផ្ដើមស្គាល់បានថា ទ្រង់មានលក្ខណៈយ៉ាងណា ហើយទ្រង់បានធ្វើអ្វីខ្លះសម្រាប់យើង ក៏ដូចជាដឹងនូវការដែលទ្រង់សព្វព្រះហឫទ័យឲ្យយើងធ្វើ និងសព្វព្រះហឫទ័យឲ្យយើងក្លាយទៅជាអ្វីម្យ៉ាង ។

ការសិក្សាព្រះគម្ពីរតាមលំដាប់របស់ក្រុម The Navigator នៃ **គម្រោងនៃការបង្កើតសិស្ស** គឺមិនមែនគ្រាន់តែជាឯកសារដែលជួយនរណាម្នាក់ឲ្យមានការរីកចម្រើនចំណេះដឹងផ្នែកព្រះគម្ពីរប៉ុណ្ណោះឡើយ ។ ហើយគោលដៅរបស់លោកអ្នកក្នុងនាមជាអ្នកដឹកនាំក៏មិនមែនត្រឹមតែស្គាល់ព្រះគម្ពីរនោះទេ ប៉ុន្តែត្រូវអនុវត្តផងដែរ ។

**គម្រោងនៃការបង្កើតសិស្ស** គឺជាធនធានមួយសម្រាប់អភិវឌ្ឍសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ។ ការយល់ដឹងបន្ថែមពីព្រះគម្ពីរ គឺគ្រាន់តែជាផ្នែកមួយនៃការក្លាយជាសិស្សរបស់ព្រះគ្រីស្ទប៉ុណ្ណោះ ។ ហើយការដែលសំខាន់ជាងនោះទៀតនោះគឺ ការអភិវឌ្ឍទំនាក់ទំនងឲ្យបានជ្រាលជ្រៅ ហើយឲ្យបានស្អិតល្អួតជាមួយព្រះជាម្ចាស់ និង

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ការយកអ្វីៗដែលយើងបានរៀនពីព្រះគម្ពីរមកអនុវត្តក្នុងជីវិត ។ សូមកុំគ្រាន់តែជ្រើសរើសយកអ្វីមួយឲ្យតែរួចៗ តែសូមជ្រើសរើសយកអ្វីដែលល្អបំផុតសម្រាប់ក្រុម ។

ជាការពិតណាស់ សៀវភៅទាំងប្រាំពីរនៃ **គម្រោងនៃការបង្កើតសិស្ស** គឺគ្រាន់តែជាឯកសារជំនួយប៉ុណ្ណោះ ។ ព្រះជាម្ចាស់ឯណោះទេដែលជាអ្នកបំពេញភាពពេញវ័យដល់អ្នកដើរតាមព្រះយេស៊ូវ ។ ប៉ុន្តែតាមរយៈកត្តារួមផ្សំមួយចំនួនដូចជាក្រុមដែលបើកចិត្តចង់សិក្សា ការអធិស្ឋានរបស់លោកអ្នកសម្រាប់ពួកគេ និងគំរូរបស់លោកអ្នកក្នុងការដើរតាមព្រះយេស៊ូវក៏នឹងអាចជួយឲ្យពួកគេមានភាពពេញវ័យឡើងផងដែរ ។ សៀវភៅទាំងនេះក៏អាចជាសំភារៈដែលស្ថិតក្នុងព្រះហស្តរបស់ព្រះវិញ្ញាណក្នុងការបំផ្លាស់បំប្រែជីវិតរបស់ពួកគេនិងលោកអ្នកផងដែរ ។

## តើគួរមាននរណាខ្លះនៅក្នុងក្រុម?

សៀវភៅ **គម្រោងនៃការបង្កើតសិស្ស** គឺជាការសិក្សាដ៏ពេញលេញនៃគោលការណ៍ដ៏សាមញ្ញនៃព្រះគម្ពីរសម្រាប់ដើរតាមព្រះយេស៊ូវគ្រីស្ទ ។ សៀវភៅនេះគឺសម្រាប់អស់អ្នកដែលចង់ក្លាយជាសិស្សរបស់ទ្រង់ ។ សិស្សថ្នាក់វិទ្យាល័យ សិស្សមហាវិទ្យាល័យ ឬក៏មនុស្សពេញវ័យអាចប្រើការសិក្សាព្រះគម្ពីរតាមលំដាប់នេះបាន

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ហើយក៏សម្រាប់អ្នករៀបការ អ្នកនៅលីវ ទាំងបុរស និងនារី ព្រមទាំងគ្រួសារដែលមានក្មេងជំទង់ផងដែរ ។

សៀវភៅនេះអាចប្រើបានទាំងក្នុងថ្នាក់ថ្ងៃអាទិត្យ និងក្រុមតូចដែលមានដូចជា ការសិក្សាព្រះគម្ពីរតាមផ្ទះ ឬតាមកន្លែងការងារជាដើម ។ល។

អស់អ្នកណាដែលចង់ចូលក្រុមសិក្សាសៀវភៅ **គម្រោងនៃការបង្កើតសិស្ស** គួរតែដឹងពីដំបូងថា ពួកគេត្រូវចំណាយពេលសិក្សាសៀវភៅនោះមុនចូលក្រុមពិភាក្សា នេះមានន័យថា ពួកគេដាច់ខាតត្រូវតែរៀនដោយខ្លួនឯងមុនពេលចូលក្រុមពិភាក្សា ។

លោកអ្នកប្រហែលត្រូវការបង្ហាញសៀវភៅទី១ និងទំព័រផ្សេងៗនៃជំពូកមួយណាក៏បាន ដើម្បីឲ្យពួកគេដឹងថា ពួកគេត្រូវចំណាយពេលប៉ុន្មានម៉ោងក្នុងមួយសប្តាហ៍ដើម្បីរៀបចំមេរៀន ។

ជាទូទៅ បើមានសមាជិកចាប់ពីប្រាំមួយទៅដប់នាក់នៅក្នុងក្រុមនោះជាការល្អសម្រាប់ការពិភាក្សា ។ ប្រសិនបើក្រុមរបស់លោកអ្នកមានគ្នាច្រើន នោះចូរបែងចែកក្រុមជាតូចៗវិញ ។ ចូរស្នើសុំអ្នកណាម្នាក់ឲ្យជួយលោកអ្នកក្នុងការដឹកនាំ ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

## កាលវិភាគរបស់លោកអ្នក

បើបូករួមជាមួយគ្នា សៀវភៅទាំងប្រាំពីរក្បាលនៃសៀវភៅ **គម្រោងនៃការបង្កើតសិស្ស** មានសាមសិបប្រាំមួយជំពូក ។ ការសិក្សា និងការពិភាក្សាមួយជំពូកក្នុងមួយសប្ដាហ៍ នោះគឺជាដំណើរការដ៏ល្អមួយ ។ ទោះបីជាយ៉ាងណាក៏ដោយ ចូរចងចាំថា គោលដៅរបស់លោកអ្នកនោះគឺ ធ្វើឲ្យមានការលូតលាស់ក្នុងព្រះគ្រីស្ទ មិនមែនគ្រាន់តែរៀនឲ្យឆាប់ចប់មេរៀននោះទេ ។ លោកអ្នកប្រហែលជាត្រូវចំណាយពេល មួយម៉ោងទៅមួយម៉ោងកន្លះជារៀងរាល់សប្ដាហ៍ក្នុងការពិភាក្សា ។ ត្រូវឲ្យប្រាកដថា លោកអ្នកបានចាប់ផ្ដើម ហើយបញ្ចប់បានទៀងម៉ោង ។

## ការជួបជុំគ្នាជាលើកទី១របស់លោកអ្នក

នៅពេលដែលក្រុមរបស់លោកអ្នកជួបជុំគ្នាជាលើកទី១ នោះលោកអ្នកត្រូវធ្វើកិច្ចការបីដូចខាងក្រោម ៖

១. បង្កើតបរិយាកាសមិនឲ្យមានភាពតានតឹង ។ ត្រូវដឹងឲ្យច្បាស់ថា គ្រប់គ្នាស្គាល់គ្នា និងមានភាពកក់ក្ដៅចំពោះគ្នាទៅវិញទៅមក ។

២. ប្រាប់នូវអ្វីដែលពួកគេត្រូវដឹងពីសៀវភៅ **គម្រោងនៃការបង្កើតសិស្ស** និងពីរបៀបដែលក្រុមរបស់លោកអ្នកនឹងត្រូវធ្វើ ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

៣. ប្រាប់នូវអ្វីដែលពួកគេនឹងត្រូវរៀននៅពេលជួបគ្នាពេលក្រោយ ។

ដើម្បីបង្កើតបរិយាកាសមិនឲ្យមានភាពតានតឹងនៅក្នុងក្រុមក្នុងចំណោមមនុស្សដែលមិនសូវស្គាល់គ្នា នោះត្រូវចំណាយពេលបន្តិច ដើម្បីណែនាំឈ្មោះ ទីកន្លែងកំណើត និងកន្លែងរស់នៅបច្ចុប្បន្ន និងការងារដល់គ្នាទៅវិញទៅមក ។ល។ ក្នុងនាមយើងជាអ្នកដឹកនាំ យើងគួរតែណែនាំពីខ្លួនយើងមុន ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកផ្សេងទៀតក្នុងការណែនាំខ្លួនគេដែរ ។

ត្រូវដឹងឲ្យប្រាកដថា គ្រប់គ្នានៅក្នុងក្រុមត្រូវតែមានព្រះគម្ពីរ និងសៀវភៅទី១នៃ **គម្រោងនៃការបង្កើតសិស្ស** ។ (លោកអ្នកគួរតែមានព្រះគម្ពីរត្រៀមទុកសម្រាប់អ្នកមិនមានព្រះគម្ពីរ) ។ សូមពន្យល់ដល់ក្រុមពីរបៀបដែលពួកគេត្រូវរៀបចំមេរៀននីមួយៗបែបណា ។ លោកអ្នកត្រូវសុំឲ្យពួកគេប្តេជ្ញាចិត្តក្នុងការរៀបចំមេរៀននីមួយៗដោយចិត្តស្មោះ ហើយឲ្យមកចូលរួមការពិភាក្សានីមួយៗពីសៀវភៅទី១ ។ បន្ទាប់មក ពួកគេអាចវាយតម្លៃលើការសម្រេចចិត្តថា ពួកគេគួរតែបន្ត ឬបញ្ឈប់ការរៀននៅក្នុងក្រុម ។

សូមឲ្យពួកគេបើកសៀវភៅទី១ ត្រង់សេចក្តីផ្តើមនៅក្នុង

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ទំព័រទី៥ ។ ស្នើសុំអ្នកណាម្នាក់ឲ្យអានកថាខណ្ឌទី១ឲ្យឮៗ រហូតចប់សេចក្ដីផ្ដើម ។ បន្ទាប់មកសួរពួកគេ ប្រសិនបើពួកគេមានសំណួរអ្វីផ្សេងៗ ។ សូមពន្យល់ពួកគេថា សៀវភៅទី១មានរៀបរាប់ពីព្រះជាម្ចាស់ និងការដែលទ្រង់យកព្រះហឫទ័យទុកដាក់ចំពោះយើង ព្រមទាំងមានរៀបរាប់ពីព្រះយេស៊ូវគ្រីស្ទ ពីការសុគតរបស់ទ្រង់ និងពីការរស់ឡើងវិញ ហើយក៏មានរៀបរាប់ពីព្រះវត្តមានរបស់ព្រះវិញ្ញាណបរិសុទ្ធដែលគង់នៅក្នុងយើងផងដែរ ។

សូមបើកត្រង់ទំព័រទី៧ រួចមកឲ្យអ្នកណាអានកថាខណ្ឌទីមួយនៃជំពូកទី១ ។ សូមឆ្លើយសំណួរខ្លះៗជាមួយគ្នានៅជំពូកទី១ ដើម្បីជួយឲ្យអ្នកដែលនៅក្នុងក្រុមស្គាល់ពីរបៀបរៀបចំដែលពួកគេនឹងត្រូវធ្វើជារៀងរាល់អាទិត្យ ។ លោកអ្នកប្រហែលត្រូវឆ្លើយឲ្យបានបីទៅបួនសំណួរត្រង់ជំពូកនេះជាដំបូងសិន ឬក៏ជ្រើសរើសយកពីជំពូកផ្សេងទៀត ។

គោលដៅរបស់លោកអ្នកគឺ ដើម្បីជួយឲ្យពួកគេស្គាល់ពីរបៀបបំពេញមេរៀនក្នុងការសិក្សា ។ ស្នើសុំនរណាម្នាក់ឲ្យឡើងអានសំណួរមួយឲ្យឮៗ បន្ទាប់មកសូមឲ្យសមាជិកក្រុមទាំងអស់បើកខគម្ពីរមើលខយោងដែលទាក់ទងនឹងសំណួរនោះ ក្រោយមកទៀតស្នើសុំម្នាក់ឲ្យអានបទគម្ពីរត្រង់នោះឲ្យឮៗ ។ ដើម្បីឲ្យកាន់តែច្បាស់ លោកអ្នកក៏អាចអានបទគម្ពីរនោះចេញពីព្រះគម្ពីរបកប្រែចាស់

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន និងព្រះគម្ពីរសម្រាយជាដើម ។ល។ សូមពិភាក្សាជាមួយគ្នាពីរបៀបដែលលោកអ្នកត្រូវឆ្លើយនឹងសំណួរទាំងនោះ ហើយបន្ទាប់មកសូមឲ្យពួកគេម្នាក់ៗសរសេរចម្លើយដាក់ក្នុងសៀវភៅ ។

សូមមើលជំពូកទី១ត្រួសៗ ដើម្បីឲ្យដឹងថានៅសល់ប៉ុន្មានទំព័រទៀត បន្ទាប់មកប្រាប់ក្រុមថា នេះគឺជាកិច្ចការដែលពួកគេត្រូវបំពេញសម្រាប់សប្តាហ៍ក្រោយ ។ សូមបញ្ជាក់ប្រាប់ពីពេលវេលា និងទីកន្លែងប្រជុំឲ្យបានច្បាស់លាស់ ។

## ការដឹកនាំលើការពិភាក្សា

ក្នុងនាមជាអ្នកដឹកនាំ ចូរដឹកនាំដោយមានទំនុកចិត្ត ព្រោះអ្នកនៅក្នុងក្រុម ពួកគេកំពុងតែសម្លឹងរកការដឹកនាំដ៏ល្អចេញពីលោកអ្នក ប៉ុន្តែក៏ត្រូវដឹកនាំដោយចិត្តស្ងប់ផងដែរ ព្រោះលោកអ្នកមិនចាំបាច់ឲ្យមានគ្រប់ទាំងចម្លើយនោះទេ!

លោកអ្នកប្រហែលជាគួរសាកល្បងវិធីផ្សេងៗក្នុងការពិភាក្សាមេរៀន ។ វិធីដ៏សាមញ្ញមួយនោះគឺ ពិភាក្សាពីសំណួរមួយទៅសំណួរមួយ ។ លោកអ្នកអាចធ្វើវិធីនេះបានដោយ ចោទសួរជាសំណួរម្តងម្នាក់ៗ ដោយឲ្យអ្នកទីមួយឆ្លើយសំណួរទី១ ហើយអ្នកទីពីរឆ្លើយសំណួរទី២ ។ល។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

វិធីនេះអាចជាវិធីមួយដ៏ល្អក្នុងការពន្យល់ណែនាំការសិក្សាព្រះគម្ពីរចំពោះអ្នកដែលមិនធ្លាប់រៀនព្រះគម្ពីរជាក្រុម ។ ផ្នែកផ្សេងៗនៃវិធីនេះជួយពួកគេឲ្យមានទំនុកចិត្ត និងមានភាពងាយស្រួល ដើម្បីស្គាល់គោលដៅនៃការពិភាក្សា ។

ម្យ៉ាងវិញទៀត ប្រសិនបើសមាជិកក្រុមរបស់លោកអ្នកទាំងអស់សុទ្ធតែជាអ្នកដែលធ្លាប់បានរៀនព្រះគម្ពីរច្រើនមកហើយ នោះលោកអ្នកអាចពិភាក្សាមួយវគ្គម្តងៗវិញ ដើម្បីឲ្យពួកគេចែកចាយនូវអ្វីៗដែលបានប៉ះពាល់ចិត្តរបស់ពួកគេ ។ សូមប្រាប់ក្រុមថា ជំពូកនីមួយៗនៃសៀវភៅទី១មានវគ្គផ្សេងៗដូចជា ៖

. ព្រះជាម្ចាស់បានបង្កើតលោកអ្នក

. ព្រះជាម្ចាស់គង់នៅគ្រប់ទីកន្លែងហើយទ្រង់ស្គាល់លោកអ្នក

. ព្រះជាម្ចាស់ស្រឡាញ់លោកអ្នក

. ព្រះជាម្ចាស់បានយកលោកអ្នកមកធ្វើជាបុត្រចិញ្ចឹមនៅក្នុងគ្រួសាររបស់ទ្រង់

## សំណួរក្នុងការចាប់ផ្តើម

សូមចាប់ផ្តើមការពិភាក្សាដោយសួរសំណួរដូចខាងក្រោមនេះ ៖

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

. «តើលោកអ្នកមានយោបល់យ៉ាងដូចម្ដេចអំពីវគ្គ **ព្រះជាម្ចាស់បានបង្កើតលោកអ្នក?»**

. «យោងទៅតាមវគ្គដំបូងនេះ តើលោកអ្នកមានចំណាប់អារម្មណ៍យ៉ាងដូចម្ដេចអំពីរបៀបដែលព្រះជាម្ចាស់បង្កើតយើងរាល់គ្នា?»

របៀបនេះអាចជួយបង្ហាញឲ្យក្រុមដឹងថា លោកអ្នកនឹងមិនពិភាក្សាលើសំណួរតាមលំដាប់លំដោយទាំងអស់នោះទេ ប៉ុន្ដែពួកគេអាចលើកឡើងពីចំណុចសំខាន់ៗ ឬក៏ការពិនិត្យសង្កេតរបស់ពួកគេដែលដកស្រង់ចេញពីសំណួរនៅក្នុងវគ្គនេះ ។ ជាការពិតណាស់ **សំណួរក្នុងការចាប់ផ្ដើម**បង្ហាញថា ពួកគេម្នាក់ៗពិតជាបានបំពេញការរៀបចំមេរៀនបានរួចជាស្រេច ។ សូមសួរសំណួរទៅក្រុមទាំងមូល មិនមែនត្រឹមតែបុគ្គលម្នាក់នោះទេ ។ ហើយសូមចងចាំថា នេះគឺជាសំណួរបញ្ចេញមតិ ។ នេះមិនមែនជាសំណួរដែលគ្រាន់តែឲ្យពួកគេឆ្លើយឲ្យតែរួចពីមាត់ដូចជា «បាទ» ឬ «ទេ» នោះទេ ប៉ុន្ដែត្រូវឆ្លើយដោយមានការរៀបរាប់ ។

## សំណួរបន្ត

ប្រសិនបើមានម្នាក់នៅក្នុងក្រុមឆ្លើយសំណួរបញ្ចេញមតិដំបូងរបស់

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

លោកអ្នកដោយលើកឡើងនូវសំណួរជាក់លាក់ណាមួយនៅក្នុងវគ្គនោះ នោះលោកអ្នកគួរតែសួរដេញដោលបន្ថែមពីបុគ្គលនោះ ដោយសួរសំណួរដូចខាងក្រោមនេះ ៖

«ចម្លើយនោះគួរឲ្យចាប់អារម្មណ៍ អញ្ចឹងសូមជួយពន្យល់បន្ថែមទៀតបានឬទេ?»

«តើអាចផ្ដល់ជាឧទាហរណ៍ពីអត្ថន័យដែលអ្នកចង់មានន័យបានដែរឬទេ?»

លោកអ្នកអាចស្នើសុំឲ្យអ្នកផ្សេងទៀតឆ្លើយសំណួរដដែលនោះដោយសួរថា ៖

«តើអ្នកផ្សេងទៀត មានយោបល់យ៉ាងដូចម្ដេចវិញអំពីសំណួរនេះ?»

«តើអ្នកផ្សេងទៀតមានយោបល់បន្ថែមលើសំណួរនេះទេ?»

ឧទាហរណ៍ ប្រហែលជាមានបុគ្គលម្នាក់នៅក្នុងក្រុមអាចលើកឡើងថា អ្វីដែលគាត់ចាប់អារម្មណ៍បំផុតនៅក្នុងវគ្គ **ព្រះជាម្ចាស់បានបង្កើតលោកអ្នក** គឺគាត់បានរៀនចេញពីកណ្ឌគម្ពីរ លោកុប្បត្តិ ១ នៅក្នុងសំណួរទី៤ថា ព្រះជាម្ចាស់បានបង្កើតមនុស្សឲ្យដូចរូបអង្គទ្រង់ ។

ហើយប្រហែលជាមានអ្នកមួយចំនួនទៀតចង់ផ្ដល់មតិយោបល់បន្ថែម

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៩៩០៤៩១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ទៅលើចម្លើយនេះ ។ បន្ទាប់មក ដើម្បីឲ្យការពិភាក្សាមាន ភាពជាក់លាក់ នោះត្រូវសួរសំណួរដែលលោកអ្នកបានរៀបចំរួច ដើម្បីសួរសំណួរបន្តដែលជំរុញឲ្យពួកគេគិតឲ្យបានជ្រាលជ្រៅជាង មុន ដូចជា៖

. តើការដែលព្រះជាម្ចាស់បានបង្កើតមនុស្សឲ្យដូចរូបអង្គទ្រង់ មានន័យយ៉ាងដូចម្តេច?

. តើមានភស្តុតាងអ្វីដែលបញ្ជាក់ថា ព្រះជាម្ចាស់បានបង្កើត មនុស្សមកឲ្យដូចរូបអង្គទ្រង់?

. តើការដែលព្រះជាម្ចាស់បានបង្កើតមនុស្សឲ្យដូចរូបអង្គទ្រង់ បានផ្តល់កិត្តិយសដល់យើងយ៉ាងដូចម្តេចខ្លះ?

បន្ទាប់មក លោកអ្នកអាចសួរអ្នកផ្សេងទៀតពីអ្វីដែលពួកគេចាប់ អារម្មណ៍បំផុតនៅក្នុងវគ្គនេះ ។ ក្រោយពីការជជែកគ្នា និងការសួរ សំណួរបន្តបន្ថែម ដើម្បីពិភាក្សាគ្នាលើវគ្គនេះរួចមក សូមបន្ត ការសិក្សាទៅវគ្គបន្ទាប់ ។ លោកអ្នកមិនចាំបាច់ពិភាក្សាគ្រប់ទាំង សំណួរនៅក្នុងវគ្គនេះនោះទេ ។ គោលការណ៍នៃការពិភាក្សាមេរៀន ជាក្រុមគឺ ដើម្បីឲ្យពួកគេចែកចាយនូវអ្វីៗដែលព្រះវិញ្ញាណបរិសុទ្ធ បានបង្រៀននៅក្នុងការរៀបចំការសិក្សារបស់ពួកគេដោយផ្ទាល់ ដែលមានសារៈសំខាន់ ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to [www.cambodianchristianresources.com/dfd-leaders/](www.cambodianchristianresources.com/dfd-leaders/)*

## សំណួរចំៗ

វាជាការសំខាន់ណាស់ក្នុងការដែលយើងសិក្សាព្រះបន្ទូលយ៉ាងយកចិត្តទុកដាក់ ព្រមទាំងអនុវត្តយ៉ាងជាក់ស្តែងនោះ ។ ដូច្នេះការសួរសំណួរដែលបញ្ជាក់ពីការអនុវត្តជាក់ស្តែងមានសារៈសំខាន់ជាងការដែលយើងគ្រាន់តែសង្កេតទៅទៀត ។ កណ្ឌគម្ពីរ សុភាសិត ៤:២៣ បង្ហាញថា ដំណើររឿងទាំងឡាយនៃជីវិតគឺកើតមកពីចិត្តរបស់យើងនេះឯង ។ មធ្យោបាយជាទូទៅមួយនៃការលើកយកសំណួរប្រភេទបែបនេះមកគឺត្រូវសួរថា ៖

«នៅពេលដែលលោកអ្នកពិចារណាលើអត្ថបទព្រះគម្ពីរ ឬក៏វគ្គនេះ តើនាំឲ្យមានការប៉ះពាល់ចិត្តលោកអ្នកយ៉ាងដូចម្តេចខ្លះ?»

«តើលោកអ្នកយល់យ៉ាងដូចម្តេច ចំពោះការដែលព្រះជាម្ចាស់បង្កើតលោកអ្នកឲ្យដូចរូបអង្គទ្រង់?»

ក្នុងនាមជាអ្នកដឹកនាំ វាជាការសំខាន់ណាស់ដែលលោកអ្នកត្រូវចាំថា បុគ្គលគ្រប់រូបក្នុងក្រុមរបស់លោកអ្នក (រួមទាំងលោកអ្នកផងដែរ) កំពុងតែស្ថិតនៅក្នុងដំណើរខាងឯវិញ្ញាណ ។ ដំណើរនេះរួមមាន ការយល់ដឹងពីសេចក្តីពិត ព្រមទាំងការទទួលជឿលើសេចក្តីពិត ។ យើងត្រូវទទួលស្គាល់ថា សមាជិកទាំងអស់កំពុងតែ

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

លូតលាស់ទៅរកភាពពេញវ័យខាងឯវិញ្ញាណ ។ ដូច្នេះហើយបានជាការដែលយើងសួរនូវសំណួរថា «តើលោកអ្នកយល់ស្របជាមួយនឹងយោបល់នេះ?» មិនមែនជាការល្អទេ ។ ការបង្ខំឲ្យសមាជិកយល់ស្របមិនមែនជាការល្អទេ ប៉ុន្តែការស្នើសុំឲ្យពួកគេចែកចាយនូវអ្វីដែលមាននៅក្នុងចិត្តរបស់ពួកគេ គឺជាការប្រសើរជាង ។ នៅពេលដែលលោកអ្នកសួរថា «តើមានអ្នកណាមានយោបល់បន្ថែម ឬទស្សនៈផ្សេងទាក់ទងនឹងរឿងនេះដែរឬទេ?» នោះមានន័យថាលោកអ្នកកំពុងតែស្នើសុំឲ្យពួកគេគិតដោយខ្លួនឯងជាជាងគ្រាប់តាមនូវអ្វីដែលអ្នកផ្សេងនៅក្នុងក្រុមគិត ។

## សំណួរអនុវត្តន៍

ចំណុចសំខាន់បីយ៉ាងនៃមេរៀននីមួយៗគឺ គំនិតជាមូលដ្ឋានគ្រឹះមួយចំនួននៃបទគម្ពីរ អាកប្បកិរិយាដែលស្តែងចេញពីចិត្ត និងគម្រោងនៃការអនុវត្តដែលចេញមកពីការសិក្សារបស់យើង ។ នៅពេលដែលលោកអ្នកដឹកនាំការពិភាក្សាលើមេរៀន សូមញែកពេលទុកសម្រាប់ការពិភាក្សាលើការអនុវត្តផង ព្រោះមេរៀនទាំងនោះមានផ្ទុកនូវសំណួរអនុវត្តន៍ខ្លះៗរួចហើយ ។ វិធីផ្សេងៗទៀតនៃការសួរសំណួរអនុវត្តន៍អាចមានដូចជា ៖

. «ខណៈពេលដែលលោកអ្នកពិចារណាលើជំពូកនេះ តើមានចំណុច

Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៩៩០៤៩១-៧-០
Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information,
come back to www.cambodianchristianresources.com/dfd-leaders/

ប៉ះពាល់ចិត្តណាខ្លះដែលព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យលោកអ្នក យកទៅអនុវត្តនៅក្នុងសប្តាហ៍នេះ?»

. «ចេញពីមេរៀនដែលលោកអ្នកបានសិក្សានៅក្នុងជំពូកនេះ តើលោកអ្នកមានអារម្មណ៍ថា ព្រះជាម្ចាស់កំពុងតែមានបន្ទូលមកកាន់លោកអ្នកអំពីចំណុចណាមួយដែលលោកអ្នកត្រូវអនុវត្តដែរឬទេ?»

. «តើមានចំណុចណាមួយដែលព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យលោកអ្នកលើកឡើង ឬក៏ផ្លាស់ប្តូរ ដែលជាលទ្ធផលមួយចេញពីការសិក្សារបស់លោកអ្នក?»

## ការបញ្ចប់កិច្ចពិភាក្សា

មានសំណួរមួយចំនួនដែលលោកអ្នកអាចប្រើ ដើម្បីនាំការពិភាក្សាឲ្យបានល្អ ហើយក៏មានវិធីផ្សេងៗទៀតដែលលោកអ្នកអាចបញ្ចប់ការពិភាក្សាផងដែរ ។ បើទោះជាលោកអ្នកមិនបានបញ្ចប់គ្រប់ទាំងសំណួរពីការពិភាក្សាក៏ដោយ សូមញែកពេលវេលាយ៉ាងហោចណាស់ឲ្យបានពីប្រាំទៅដប់នាទី ដើម្បីឲ្យក្រុមអាចអនុវត្តលើសេចក្តីបញ្ចប់មួយចំនួនដូចខាងក្រោម ៖

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

**ការចូលឲ្យបានស៊ីជម្រៅ**

នេះគឺជាសំណួរបន្ថែមដែលក្រុមនីមួយៗអាចឆ្លើយ ដើម្បីស្គាល់ប្រធានបទឲ្យបានកាន់តែស៊ីជម្រៅ ។ ពីព្រោះនេះគឺជាសំណួរបន្ថែម ហើយអ្នកនៅក្នុងក្រុមទាំងអស់មិនបានបំពេញទេ ប៉ុន្តែសម្រាប់អ្នកផ្សេងវិញទៀត វគ្គត្រង់នេះប្រហែលជាគន្លឹះនៃការសិក្សារបស់ពួកគេ ។ មុនពេលដែលលោកអ្នកបញ្ចប់ការសិក្សា សូមសួរសំណួរដូចនេះ «តើមានអ្នកណាចង់ចែកចាយពីអ្វីដែលអ្នករាល់គ្នាបានរៀនចេញពីវគ្គ **ការចូលឲ្យបានស៊ីជម្រៅ** ដែរឬទេ?»

## រូបភាពនិងសម្រង់សម្ដី

នៅក្នុងជំពូកនីមួយៗមានបញ្ចូលនូវរូបភាព និងសម្រង់សម្ដីផ្សេងៗ ។ ពេលខ្លះរូបភាព និងសម្រង់សម្ដីទាំងនោះអាចប៉ះពាល់ដល់ចិត្តយើង ហើយមានពេលខ្លះក៏បង្អាក់ចិត្តយើងដែរ ។ មិនថាចំណុចមួយណានោះទេ ចូរលោកអ្នកស្នើសុំឲ្យពួកគេផ្ដល់មតិយោបល់ទៅលើរូបភាព ឬក៏សម្រង់សម្ដីនៅក្នុងជំពូកនីមួយៗ ។

## ការអនុវត្ត

សូមញែកពេលវេលាសម្រាប់ការពិភាក្សាពីការអនុវត្តផ្ទាល់ខ្លួនដែលដកស្រង់ចេញពីព្រះគម្ពីរ ។ បើមិនដូច្នោះទេ ក្រុមរបស់លោកអ្នក

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

នឹងមានការខកខានត្រង់ផ្នែកដ៏មានសារៈសំខាន់នៃភាពជាសិស្ស របស់ព្រះគ្រីស្ទជាមិនខាន ។ នៅក្នុងជំពូកនីមួយៗមានរួមបញ្ចូលនូវសំណួរដែលបានស្នើសុំពីក្នុងក្រុមឲ្យអនុវត្តលើសេចក្តីពិតនៅក្នុងជីវិតគេរួចទៅហើយ ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើវិធីចែកចាយរបៀបនេះមិនមានធ្វើឡើងទេ នោះចូរសួរសំណួរបែបនេះវិញ ៖ «តើអត្ថបទព្រះគម្ពីរបានប៉ះពាល់ចិត្តរបស់លោកអ្នកយ៉ាងដូចម្តេចខ្លះក្នុងសប្តាហ៍នេះ ខណៈពេលដែលលោកអ្នកសញ្ជឹងគិតលើការសិក្សានេះ? តើលោកអ្នកគិតថា ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យលោកអ្នកអនុវត្តលើចំណុចដែលបានប៉ះពាល់ចិត្តទាំងនេះនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃក្នុងសប្តាហ៍នេះយ៉ាងដូចម្តេច?» លោកអ្នកគួរចែកចាយពីអ្វីដែលព្រះជាម្ចាស់បានប៉ះពាល់ចិត្តលោកអ្នកក្នុងការអនុវត្តនូវអ្វីដែលលោកអ្នកបានសិក្សាម្តងកាល ព្រោះការធ្វើដូច្នេះនឹងបណ្តាលឲ្យលោកអ្នកក្លាយជាគំរូដល់ក្រុមលើការអនុវត្ត ។

## ការសង្ខេប

ជាការល្អ ប្រសិនបើលោកអ្នករំឭកមេរៀនចាស់មុនចាប់ផ្តើមសិក្សាមេរៀនថ្មី ហើយមុនបញ្ចប់ការពិភាក្សាសូមសង្ខេបមេរៀនថ្មីដែលលោកអ្នកទើបតែរៀននោះ ។ ការសង្ខេបនេះមានរួមដូចជា

Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០
Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information,
come back to www.cambodianchristianresources.com/dfd-leaders/

គំនិតចម្បង និងពីរបៀបដែលគំនិតនោះជាប់ទាក់ទងគ្នា ។ មានមធ្យោបាយច្រើនដែលលោកអ្នកអាចសង្ខេបបានដូចជា ស្នើសុំឲ្យម្នាក់ៗអានត្រង់**ចំណុចគួរចងចាំ**មួយចំណុចម្នាក់ៗ ឬឲ្យសង្ខេបមេរៀន ហើយសួរថា «តើមានសេចក្ដីពិតណាខ្លះបានប៉ះពាល់ចិត្តលោកអ្នកបំផុត នៅពេលដែលលោកអ្នកពិចារណាទៅលើជំពូកទាំងមូល?»

## ការអធិស្ឋាន

សូមចំណាយពេលអធិស្ឋានមុនបញ្ចប់ការពិភាក្សា ។ លោកអ្នកត្រូវដឹងឲ្យច្បាស់ថា មានសមាជិកខ្លះនៅក្នុងក្រុមមិនទាន់ហ៊ានអធិស្ឋានឮៗនៅឡើយទេ ។ ដូច្នេះ ត្រូវស្នើសុំឲ្យអ្នកនៅក្នុងក្រុមចែកចាយពីសំណូមពរអធិស្ឋានខ្លីៗ បន្ទាប់មកអធិស្ឋានសម្រាប់ពួកគេឲ្យអនុវត្តមេរៀននេះ ។ ត្រូវយល់ស្របជាមួយសមាជិកក្នុងក្រុមថា បញ្ហាដែលគេបានចែកចាយនៅក្នុងការពិភាក្សា រួមទាំងសំណូមពរអធិស្ឋាននោះលោកអ្នកមិនត្រូវចែកចាយដល់អ្នកផ្សេងៗឡើយ ។

**បទគម្ពីរត្រូវចងចាំ**

លោកអ្នកគួរលើកទឹកចិត្តដល់សមាជិកក្នុងក្រុមឲ្យទន្ទេញខគម្ពីរគន្លឹះនៅក្នុងសៀវភៅទី២ដល់សៀវភៅទី៧ ឲ្យចាំមាត់ ។ ការដាក់ពិន័យឲ្យទន្ទេញខគម្ពីរគន្លឹះឲ្យចាំមាត់គឺជាវិធីសាស្ត្រដ៏ល្អមួយ ដើម្បីទុក

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងចិត្តរបស់យើង ។ ប៉ុន្តែនេះគ្រាន់តែជាជម្រើសមួយប៉ុណ្ណោះ ។ ប្រសិនបើក្រុមរបស់លោកអ្នកប្តេជ្ញាចិត្តទន្ទេញខគម្ពីរឲ្យចាំមាត់ទាំងអស់គ្នា នោះលោកអ្នកត្រូវតែបង្រៀនពួកគេពីហេតុផល និងរបៀបទន្ទេញដល់ពួកគេ ហើយក៏ត្រូវជួយជំរុញចិត្តឲ្យពួកគេទន្ទេញផងដែរ ដោយចាប់ផ្តើមពីសៀវភៅទី២ ។ សូមជួយលើកទឹកចិត្តដល់សមាជិកក្រុមឲ្យរំឭកខគម្ពីរចងចាំជាដៃគូ នៅពេលដែលពួកគេមកដល់ ឬក៏រំឭកខគម្ពីរទាំងអស់គ្នាមុនពេលបញ្ចប់ការសិក្សា ។ នៅក្នុងទំព័រទី ៤១-៤៣ មានសេចក្តីណែនាំបន្ថែមស្តីពីការដឹកនាំក្នុងការទន្ទេញខគម្ពីរចងចាំ ។

## ការបង្កើតបរិយាកាសឲ្យមានសុវត្ថិភាព

ក្រុមពិភាក្សាមួយដែលល្អ ទាមទារឲ្យមានការទុកចិត្តគ្នា ។ នៅពេលដែលសមាជិកនៅក្នុងក្រុមរបស់លោកអ្នកចាប់ផ្តើមទុកចិត្តគ្នាទៅវិញទៅមកហើយ នោះការពិភាក្សារបស់លោកអ្នកក៏កាន់តែស៊ីជម្រៅហើយល្អជាងមុនដែរ ។ ក្នុងនាមជាអ្នកដឹកនាំ លោកអ្នកអាចជួយបង្កើតការទុកចិត្តគ្នា ដោយលោកអ្នកត្រូវទុកចិត្តពួកគេជាមុន និងត្រូវចែកចាយពីជីវិតផ្ទាល់ខ្លួនរបស់លោកអ្នកក្នុងកាលៈទេសៈដ៏សមរម្យដែលអាចជួយបង្កើតឲ្យមានសុវត្ថិភាពដល់

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to [www.cambodianchristianresources.com/dfd-leaders/](www.cambodianchristianresources.com/dfd-leaders/)*

ពួកគេ នៅពេលដែលពួកគេចែកចាយវិញ ។ នោះមានន័យថា លោកអ្នកត្រូវចែកចាយពីការតយុទ្ធ និងការបរាជ័យ មិនមែនគ្រាន់តែចែកចាយពីជ័យជម្នះ ឬក៏ការលូតលាស់នោះប៉ុណ្ណោះទេ ។ រាល់ពេលដែលលោកអ្នកជួបជុំគ្នា មានការពីរយ៉ាងដែលអាចកើតឡើងចំពោះការទុកចិត្តគ្នា ការទីមួយគឺការចម្រើនឡើង ទីពីរគឺការធ្លាក់ចុះ ។ ក្នុងនាមជាអ្នកដឹកនាំ លោកអ្នកអាចជួយថែបំប៉នការទុកចិត្តគ្នាទៅវិញទៅមកដោយអធិស្ឋានសូមព្រះជាម្ចាស់បង្កើតបរិយាកាសឲ្យមានសុវត្ថិភាពនៅក្នុងក្រុមរបស់លោកអ្នក ។ លោកអ្នកប្រហែលជាត្រូវជួយលើកទឹកចិត្តដល់ក្រុមរបស់លោកអ្នកម្តងកាល ដើម្បីឲ្យពួកគេចេះទុកចិត្តគ្នាទៅវិញទៅមក ហើយឲ្យរក្សាការចែកចាយនោះនៅក្នុងក្រុមតែប៉ុណ្ណោះ ។

## ការរៀបចំសម្រាប់ការពិភាក្សានីមួយៗ

គន្លឹះពីរយ៉ាងដែលនឹងទាក់ទាញចំណាប់អារម្មណ៍ ហើយនាំឲ្យមានប្រយោជន៍ក្នុងការពិភាក្សាគ្នានោះគឺ ត្រូវមានគោលបំណងជាក់លាក់សម្រាប់ជំពូកនីមួយៗ និងត្រូវរៀបចំសំណួរពិភាក្សាដ៏ល្អៗទុកជាមុន ។

សៀវភៅសម្រាប់គ្រូនេះរួមមាន ព័ត៌មានមួយចំនួនដែលនឹងអាចជួយលោកអ្នកក្នុងការរៀបចំគន្លឹះទាំងពីរនោះ ។ សៀវភៅ

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

**គម្រោងនៃការបង្កើតសិស្ស**ទាំងប្រាំពីរក្បាល មានកត់ទុកពីសំណើនៃគោលបំណងក្នុងជំពូកនីមួយៗ ។ ប្រសិនបើលោកអ្នកពិភាក្សាគ្រប់សំណួរទាំងអស់នៅក្នុងការសិក្សានោះ វានឹងមានការពិបាក ហើយក៏មិនសូវមានប្រយោជន៍ដែរ ពីព្រោះពួកគេបានរៀនជាច្រើនចេញពីការសិក្សាផ្ទាល់ខ្លួនហើយ ។ ដូច្នេះការដែលយើងធ្វើតាមគោលបំណងនៃជំពូកនីមួយៗគឺ យើងក៏បានជ្រើសរើសសំណួរប្រហែលប្រាំទៅដប់សំណួរដែលនឹងជួយបង្កើនឲ្យការពិភាក្សាកាន់តែមានប្រសិទ្ធភាព ។ លើសពីនោះទៅទៀត លោកអ្នកអាចជ្រើសរើសសំណួរដ៏ល្អផ្សេងៗទៀតចេញពីវគ្គនៃ**ការចូលឲ្យបានស៊ីជម្រៅ** ។ យើងបានទុកចន្លោះនៅក្នុងសៀវភៅដែលលោកអ្នកអាចសរសេរសំណួរពិភាក្សារបស់លោកអ្នកបាន ។ មានអ្នកដឹកនាំជាច្រើនបានយល់ឃើញថា ការគូសសញ្ញាគ្រីស្ទត្រង់សំណួរនៅក្នុងសៀវភៅមេរៀន គបស ដែលសៀវភៅសម្រាប់គ្រូបានលើកឡើងត្រង់សំណើនៃការពិភាក្សា ព្រមទាំងយកសំណួរបន្ថែមត្រង់ចំណុចនោះមកសរសេរនៅគែមចុងសន្លឹកសៀវភៅមេរៀននោះមានប្រយោជន៍ណាស់ក្នុងការបង្រៀន ។ នៅពេលដែលលោកអ្នកមានបទពិសោធន៍ច្រើនក្នុងការដឹកនាំលើការពិភាក្សាព្រះគម្ពីរ នោះលោកអ្នកនឹងអាចបង្កើតសំណួរដ៏មានប្រសិទ្ធភាពមួយចំនួនចេញពីគំនិតលោកអ្នកផ្ទាល់ទៅលើការពិភាក្សានោះជាច្រើនថែមទៀត ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៩១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

លោកអ្នកនឹងឃើញគន្លឹះនៃការពិភាក្សានៅផ្នែកខាងចុងនៃជំពូកនីមួយៗក្នុង**សៀវភៅសម្រាប់គ្រូ**នេះដែលអាចជួយលោកអ្នកក្នុងការបង្កើនភាពជាអ្នកដឹកនាំ ។ ប្រសិនបើលោកអ្នកមានដៃគូដែលជាអ្នកដឹកនាំដូចគ្នា ជាការល្អបើអ្នកទាំងពីរអាន**គន្លឹះនៃការពិភាក្សា**ជាមួយគ្នា ដើម្បីជួយបង្ហាត់បង្រៀនជំនាញទាំងនេះដល់គ្នាទៅវិញទៅមក ។

ខាងក្រោមនេះគឺជាចំណងជើងនៃ**គន្លឹះនៃការពិភាក្សា**លើជំពូកនីមួយៗនៃ**សៀវភៅសម្រាប់គ្រូ** ៖

សៀវភៅទី១ ៖ ១ ស្តាប់ដោយយកចិត្តទុកដាក់
សៀវភៅទី១ ៖ ២ អ្នកដឹកនាំដែលពូកែ ឬអ្នកសម្របសម្រួល
សៀវភៅទី១ ៖ ៣ អធិស្ឋាន អធិស្ឋាន ហើយអធិស្ឋាន
សៀវភៅទី១ ៖ ៤ លើកសំណួរទៅអ្នកផ្សេងវិញ

សៀវភៅទី២ ៖ ១ ជួយឲ្យគ្រប់គ្នាមានចំណែកក្នុងការចូលរួម
សៀវភៅទី២ ៖ ២ ជួយអ្នកដែលនិយាយច្រើនឲ្យចេះស្តាប់
សៀវភៅទី២ ៖ ៣ បញ្ចប់ឲ្យទៀងពេលវេលា
សៀវភៅទី២ ៖ ៤ ចាប់ផ្តើមឲ្យទៀងពេលវេលា
សៀវភៅទី២ ៖ ៥ ពេលខ្លះត្រូវបង្វែរមេរៀន

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

សៀវភៅទី៣ ៖ ១ ចូលរួមអធិស្ឋានជាមួយគ្នា
សៀវភៅទី៣ ៖ ២ មានការប្រកបជាមួយគ្នា
សៀវភៅទី៣ ៖ ៣ មានភាពប្រាកដប្រជា
សៀវភៅទី៣ ៖ ៤ សំណួរដែលមិនទាន់មានចម្លើយ
សៀវភៅទី៣ ៖ ៥ ការចូលឲ្យបានស៊ីជម្រៅ

សៀវភៅទី៤ ៖ ១ ការដឹកនាំក្រុមជាមួយដៃគូ
សៀវភៅទី៤ ៖ ២ ស្ដាប់ដោយយកចិត្តទុកដាក់បន្ថែមទៀត
សៀវភៅទី៤ ៖ ៣ ជឿជាក់ព្រះជាម្ចាស់នឹងជួយបំផ្លាស់បំប្រែ
សៀវភៅទី៤ ៖ ៤ គិតពិចារណាលើការចាប់ផ្ដើមបង្កើតក្រុមថ្មី
សៀវភៅទី៤ ៖ ៥ ការផ្លាស់ប្ដូរទីតាំង

សៀវភៅទី៥ ៖ ១ ភាពស្និទ្ធស្នាលជាមួយព្រះជាម្ចាស់
សៀវភៅទី៥ ៖ ២ ការយល់ឃើញលើភាពជាក់ស្ដែង
សៀវភៅទី៥ ៖ ៣ បញ្ហានៃដួងចិត្ត
សៀវភៅទី៥ ៖ ៤ ការស្រឡាញ់អ្នកដទៃ
សៀវភៅទី៥ ៖ ៥ ការការពារធម្មជាតិ

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to [www.cambodianchristianresources.com/dfd-leaders/](www.cambodianchristianresources.com/dfd-leaders/)*

សៀវភៅទី៦ ៖ ១ ការបម្រើអ្នកផ្សេងទៀតក្រៅពីក្រុម

សៀវភៅទី៦ ៖ ២ ការចែកចាយក្នុងបរិយាកាសដែលមានសុវត្ថិភាព

សៀវភៅទី៦ ៖ ៣ ការរំឭកពីសៀវភៅកំណត់ហេតុ

សៀវភៅទី៦ ៖ ៤ ការស្នើសុំពួកគេឲ្យមានការប្ដេជ្ញាចិត្ត

សៀវភៅទី៦ ៖ ៥ ការមានសេចក្ដីមេត្តាករុណា និងដៃគូកែតម្រង់គ្នា

សូមឲ្យលោកអ្នកទទួលបានអំណរក្នុងការរួបរួមគ្នាជាមួយព្រះគ្រីស្ទនៅក្នុងនគររបស់ទ្រង់ នៅពេលដែលលោកអ្នកដឹកនាំ ហើយជួយអ្នកផ្សេងៗនៅក្នុងដំណើរខាងឯវិញ្ញាណរបស់ពួកគេ ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

# សៀវភៅទី១
# ជីវិតរបស់លោកអ្នក
# នៅក្នុងព្រះគ្រីស្ទ

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information,*
*come back to [www.cambodianchristianresources.com/dfd-leaders/](www.cambodianchristianresources.com/dfd-leaders/)*

សៀវភៅទី១
ជំពូកទី១
## ព្រះជាម្ចាស់យកព្រះទ័យទុកដាក់ចំពោះលោកអ្នក

**គោលបំណងនៃជំពូកនេះគឺ៖** ដើម្បីមើលឃើញឲ្យច្បាស់អំពីការធានាបានថា យើងមានសេចក្ដីសង្គ្រោះក្នុងព្រះគ្រីស្ទ ។ ការធានាអះអាងនេះផ្អែកលើសេចក្ដីពិតនៅក្នុងព្រះបន្ទូល ។

លោកអ្នកអាចជួយសមាជិកក្រុមទាំងអស់ឲ្យស្គាល់គ្នាដោយឲ្យពួកគេចែកចាយពីដំណើរខាងឯវិញ្ញាណរបស់ខ្លួន ហើយសួរពីអ្វីដែលជំរុញចិត្តឲ្យពួកគេចង់ចូលរួមសិក្សាព្រះគម្ពីរក្នុងក្រុមនេះ ។ ជាថ្មីម្ដងទៀត ក្នុងនាមជាអ្នកដឹកនាំ លោកអ្នកគួរតែជាអ្នកចាប់ផ្ដើមចែកចាយការនេះមុនគេ ។ លោកអ្នកប្រហែលជាត្រូវស្នើសុំដល់សមាជិកដែលមានភាពខ្មាសអៀន និងមិនសូវចេះនិយាយស្ដីឲ្យចែកចាយពីការនេះដោយផ្ទាល់ ប៉ុន្តែសូមកុំបង្ខំពួកគេឲ្យសោះ ។

សូមចាំថា សមាជិកក្រុមទាំងអស់បានចំណាយពេល ហើយនិងបានខិតខំឆ្លើយទៅនឹងសំណួរដែលមាននៅក្នុងសៀវភៅសិក្សារបស់ពួកគេរួចមកហើយ ។ ហើយក៏ប្រហែលជាមានមនុស្សជាច្រើនចង់ចែកចាយពីអ្វីដែលពួកគេបានសិក្សាស្វែងយល់ដល់ក្រុម

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ដែរ ។ ចំណុចផ្ដោតសំខាន់នៃការពិភាក្សានោះគួរតែផ្ដោតទៅលើអ្វីដែលបានប៉ះពាល់ចិត្តពួកគេចេញពីការសិក្សា ។

លោកអ្នកគួរតែបង្កើតសំណួរពិភាក្សាខ្លះៗ ដើម្បីជួយជំរុញឲ្យពួកគេចែកចាយពីអ្វីៗដែលពួកគេបានសិក្សា ។ សំណើមួយចំនួនតាមផ្នែកនីមួយៗនៃជំពូកទី១ មានបង្ហាញនៅខាងក្រោម ។ សូមប្រើចន្លោះខាងក្រោមនេះ ដើម្បីសរសេរសំណួរពិភាក្សាផ្ទាល់របស់លោកអ្នក ។

សំណួរទី៥, ៩, ១៣, ១៧និង១៩ ដែលដកស្រង់ចេញពីជំពូកនេះអាចជួយក្រុមរបស់លោកអ្នកឲ្យមានការពិភាក្សាគ្នាបានល្អ ។ លោកអ្នកគួរគូសចំណាំសំណួរទាំងនោះក្នុងសៀវភៅមេរៀន ដើម្បីរំឭកលោកអ្នកឲ្យលើកសំណួរនោះឡើង ប្រសិនបើមិនមានអ្នកផ្សេងលើកសំណួរទាំងនោះឡើង ។

## ព្រះជាម្ចាស់បានបង្កើតលោកអ្នក (សំណួរទី១-៦)

**ជម្រើសទី១៖** លោកអ្នកអាចចាប់ផ្ដើមការពិភាក្សាដោយ សួរសំណួរពិភាក្សាមួយដូចជា «តើមានអ្វីខ្លះដែលប៉ះពាល់ចិត្តលោកអ្នក នៅពេលដែលលោកអ្នកពិចារណាលើវគ្គទី១នេះ?»

ចូរចាំថា តាមធម្មតាពេលពួកគេឮសំណួរនេះ ពួកគេនឹងចំណាយពេលគិតយ៉ាងស្ងាត់ស្ងៀម ។ សូមស្ដាប់ចម្លើយរបស់ពួកគេ

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ដោយយកចិត្តទុកដាក់ ហើយជ្រើសរើសម្នាក់ដើម្បីសួរសំណួរបន្ត ។ ចូរចងចាំថា យើងអាចប្រើវិធីនេះនៅក្នុងវគ្គផ្សេងៗនៅក្នុងជំពូកណាក៏បាន ។ សំណួរដែលយើងបានលើកឡើងនៅក្នុងសៀវភៅនេះគ្រាន់តែជាសំណួរបន្ទាប់បន្សំទៅលើការពិភាក្សាដែលអាចជួយឲ្យក្រុមរបស់លោកអ្នកមានភាពងាយស្រួលក្នុងការពិភាក្សាគ្នាអំពីមេរៀនរបស់គេ ។

**ជម្រើសទី២ ៖** លោកអ្នកអាចចាប់ផ្ដើមពិភាក្សាគ្នាដោយសួរសំណួរបញ្ចេញមតិដែលទាក់ទងទៅនឹងអ្វីៗដែលពួកគេបានរៀនរួចមកហើយ ។ ឧទាហរណ៍ ៖

«ក្នុងវគ្គទី១នេះ ហេតុអ្វីបានជាការទទួលស្គាល់ថាព្រះជាម្ចាស់បានបង្កើតយើងជាការសំខាន់?»

«យោងតាមសំណួរទាំង៦ដំបូងនេះ តើការទទួលស្គាល់ថាព្រះជាម្ចាស់បានបង្កើតលោកអ្នកដូចរូបអង្គទ្រង់ នោះមានន័យយ៉ាងដូចម្ដេចចំពោះជីវិតប្រចាំថ្ងៃរបស់លោកអ្នក?»

សូមស្ដាប់ចម្លើយរបស់ពួកគេដោយយកចិត្តទុកដាក់ ។ បន្ទាប់មកសួរសំណួរបន្តដោយផ្អែកលើចម្លើយរបស់ពួកគេផ្ទាល់ ។ វិធីនៃការសួរសំណួរ និងការស្ដាប់ដោយយកចិត្តទុកដាក់ និងវិធីនៃការសួរសំណួរបន្តដោយផ្អែកលើចម្លើយរបស់ពួកគេ នោះនឹងជួយឲ្យ

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to [www.cambodianchristianresources.com/dfd-leaders/](www.cambodianchristianresources.com/dfd-leaders/)*

ពួកគេអាចឈានចូលដល់ការពិភាក្សាដ៏មានប្រយោជន៍លើគ្រប់ទាំងប្រធានបទ ។

**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី៥

សូមប្រើចន្លោះខាងក្រោមនេះ ដើម្បីសរសេរសំណួរពិភាក្សាសម្រាប់វគ្គទី១ ។

**ការពន្យល់បន្ថែមលើសំណួរទី៥៖**

ប្រសិនបើសិស្សរបស់លោកអ្នកមិនយល់សំណួរត្រង់នេះ សូមសួរបែបនេះ៖ «តើលោកអ្នកចូលចិត្តលក្ខណៈជាមនុស្សដែលព្រះជាម្ចាស់បានបង្កើតមកនេះដែរឬទេ? ហេតុអ្វីចូលចិត្ត ឬហេតុអ្វីមិនចូលចិត្ត?»

**ព្រះជាម្ចាស់គង់នៅគ្រប់ទីកន្លែងហើយទ្រង់ស្គាល់លោកអ្នក**

(សំណួរទី៧-៩)

**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី៩

ស្តេច ដាវីឌ យល់យ៉ាងច្បាស់ថា ព្រះជាម្ចាស់មានព្រះវត្តមាននៅគ្រប់ទីកន្លែង ។ តើការដែលព្រះជាម្ចាស់មានព្រះវត្តមានគ្រប់ទីកន្លែង នោះមានន័យយ៉ាងដូចម្តេចចំពោះ

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

លោកអ្នក?

តើលោកអ្នកចង់ឲ្យមនុស្សស្គាល់លោកអ្នកយ៉ាងច្បាស់ដែរឬទេ? ហេតុអ្វីចង់ ឬហេតុអ្វីមិនចង់?

**ព្រះជាម្ចាស់ស្រឡាញ់លោកអ្នក** (សំណួរទី១០-១៤)

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី១៣

តើលោកអ្នកយល់ពីមូលហេតុដែលព្រះជាម្ចាស់ស្រឡាញ់លោកអ្នកដែរឬទេ?

លោកអ្នកប្រហែលជាត្រូវស្នើសុំអ្នកណាម្នាក់ឲ្យអានសម្រង់សម្ដីរបស់លោក ដាលឡាស វើលឡាឌ (Dallas Willard) នៅត្រង់ទំព័រទី១៦-១៧ រួចមកសូមលោកអ្នកផ្ដល់ជាមតិយោបល់បន្តិចបន្តួច ។

**ព្រះជាម្ចាស់បានយកលោកអ្នកមកធ្វើជាបុត្រចិញ្ចឹមនៅក្នុងគ្រួសាររបស់ទ្រង់** (សំណួរទី១៥-១៩)

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី១៧និង១៩

លោកអ្នកអាចជ្រើសរើសម្នាក់ក្នុងក្រុមឲ្យអានត្រង់ការធានាដែលមាននៅក្នុង៥ទាំងបីក្នុងទំព័រទី២៣ ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

## ការបញ្ចប់កិច្ចពិភាក្សា

សូមជ្រើសរើសយកសកម្មភាពមួយឬពីរខាងក្រោមនេះ ដើម្បីបញ្ចប់ការពិភាក្សា ។

## រូបភាពនិងសម្រង់សម្ដី

ស្នើសុំឲ្យសមាជិកផ្ដល់យោបល់លើ រូបភាព ឬ សម្រង់សម្ដី នៅក្នុងជំពូកនេះ ។ ការឲ្យយោបល់នោះអាចជាមតិដែលបានប៉ះពាល់ចិត្តពួកគេ ឬជាមតិដែលមិនគាំទ្រ ។

## ការសង្ខេប

ជារឿយៗ នៅចុងបញ្ចប់នៃការពិភាក្សា លោកអ្នកគួរតែនិយាយត្រួសៗពីអ្វីដែលពួកគេបានរៀនពីជំពូកនោះ ។ សូមរំឭកពីគំនិតសំខាន់ៗនៅក្នុងជំពូកនោះ ហើយពន្យល់ពីរបៀបដែលគំនិតនោះមានទំនាក់ទំនងជាមួយគ្នា ។ យើងអាចធ្វើការនេះបានតាមរយៈការសួរសំណួរសង្ខេបមួយដូចជា ៖ «ឥឡូវសូមសង្ខេបជំពូកនេះ! តើមានសេចក្ដីពិតណាខ្លះដែលបានប៉ះពាល់ចិត្តលោកអ្នកខ្លាំងជាងគេបំផុត នៅពេលលោកអ្នកពិចារណាទៅលើជំពូកនេះទាំងមូល?»

របៀបសង្ខេបជំពូកមួយទៀតនោះគឺ ឲ្យសមាជិកក្រុមណាម្នាក់អានប្រយោគដែលមានសរសេរជាចំណងជើងថា «**ចំណុចគួរចងចាំ**» ឲ្យឮៗ ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

## ការអនុវត្ត

សូមចងចាំថា លោកអ្នកត្រូវពិភាក្សាលើការអនុវត្តតាមព្រះបន្ទូល ។ បើមិនដូច្នោះទេ ក្រុមរបស់លោកអ្នកនឹងអាចបាត់បង់ផ្នែកដ៏សំខាន់មួយក្នុងនាមជាសិស្សរបស់ព្រះយេស៊ូវជាមិនខាន ។ លោកអ្នកក៏អាចសួរសំណួរថា «តើអត្ថបទព្រះគម្ពីរទាំងនេះបានបំផ្លាស់បំប្រែជីវិតរបស់លោកអ្នកក្នុងអាទិត្យនេះយ៉ាងដូចម្ដេច?» ឬក៏សួរថា «តើលោកអ្នកអាចអនុវត្តសេចក្ដីពិតទាំងនេះនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់លោកអ្នកនៅសប្ដាហ៍នេះដោយរបៀបណា?»

## ការចូលឲ្យបានស៊ីជម្រៅ

ដោយសារតែវគ្គនេះមិនមែនជាវគ្គដែលតម្រូវឲ្យសមាជិកក្រុមបំពេញ នោះប្រហែលជាមានអ្នកខ្លះមិនបានបំពេញនោះទេ ។ តែសម្រាប់អ្នកផ្សេងទៀត វគ្គនេះអាចជាវគ្គគន្លឹះដ៏សំខាន់ក្នុងការសិក្សារបស់ពួកគេ ។ លោកអ្នកអាចនឹងសួរនូវសំណួរជាទូទៅមួយដូចជា ៖ «តើមានអ្នកណាចង់ចែកចាយពីអ្វីដែលខ្លួនបានសិក្សាពីវគ្គ **ការចូលឲ្យបានស៊ីជម្រៅ**ដែរឬទេ?»

## ការអធិស្ឋាន

សូមចំណាយពេលអធិស្ឋានសិនមុនបញ្ចប់ការពិភាក្សា ។ លោកអ្នកត្រូវដឹងឲ្យច្បាស់ថា ប្រហែលជាមានសមាជិកខ្លះនៅក្នុង

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ក្រុមមិនទាន់ហ៊ានអធិស្ឋានឮៗនៅឡើយទេ ។ ដូច្នេះ ត្រូវស្នើសុំឲ្យអ្នកនៅក្នុងក្រុមចែកចាយពីសំណូមពរអធិស្ឋានខ្លីៗ បន្ទាប់មកអធិស្ឋានឲ្យពួកគេអាចអនុវត្តមេរៀននេះ ។

**គន្លឹះនៃការពិភាក្សា ៖ ស្តាប់ដោយយកចិត្តទុកដាក់**

សូមស្តាប់ចម្លើយរបស់ពួកគេដោយយកចិត្តទុកដាក់ ។ បន្ទាប់មក សួរសំណួរបន្តដោយផ្អែកលើចម្លើយរបស់ពួកគេផ្ទាល់ ។ វិធីនៃការសួរសំណួរ ការស្តាប់ដោយយកចិត្តទុកដាក់ និងការសួរសំណួរបន្តដោយផ្អែកលើចម្លើយរបស់ពួកគេ នោះនឹងជួយឲ្យពួកគេឈានដល់ការពិភាក្សាដ៏មានប្រយោជន៍លើគ្រប់ទាំងប្រធានបទ ។

- **សួរសំណួរចាប់ផ្តើម**
- **ស្តាប់ដោយយកចិត្តទុកដាក់**
- **សួរសំណួរបន្ត**

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

សៀវភៅទី១
ជំពូកទី២
**បុគ្គលភាពនៃព្រះយេស៊ូវគ្រីស្ទ**

**គោលបំណងនៃជំពូកនេះគឺ៖** ដើម្បីមើលឲ្យឃើញពីភាពជាព្រះជាម្ចាស់ផង និងភាពជាមនុស្សផងរបស់ព្រះយេស៊ូវគ្រីស្ទ ។ នេះមានន័យថាទ្រង់គឺជាអ្នកសង្រ្គោះសង្រ្គោះតែមួយគត់រវាងព្រះជាម្ចាស់និងមនុស្ស ។ មួយទៀតគឺ ដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់យើងទៅកាន់បុគ្គលភាពនៃព្រះយេស៊ូវបន្ថែមទៀត ។

សូមរំឭកមេរៀនចាស់ឡើងវិញដោយសង្ខេប មុននឹងចាប់ផ្តើមសិក្សាមេរៀនថ្មីនេះ ។ បន្ទាប់មកស្នើសុំអ្នកណាម្នាក់ឲ្យអានសេចក្តីផ្តើមដែលមាននៅដើមជំពូកឲ្យឮៗ ។

សំណួរដ៏ល្អៗមួយចំនួនសម្រាប់ការពិភាក្សាមានដូចជា សំណួរទី៣, ១១, ១៣និង១៥ ។

**ភាពជាព្រះរបស់ព្រះយេស៊ូវគ្រីស្ទ** (សំណួរទី១-១១)
លោកអ្នកគួរចាប់ផ្តើមដោយការសួរសំណួរទូទៅដូចជា ៖
«នៅពេលដែលលោកអ្នកពិចារណាលើវគ្គទី១នេះ តើភាពជា

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ព្រះជាម្ចាស់របស់ព្រះយេស៊ូវបានប៉ះពាល់ចិត្តលោកអ្នកយ៉ាង
ដូចម្ដេច?»

សូមស្ដាប់ចម្លើយគេដោយយកចិត្តទុកដាក់ ហើយជ្រើសរើសម្នាក់ដើម្បីសួរសំណួរបន្ត ។ ចូរចងចាំថា យើងអាចប្រើវិធីនេះនៅក្នុងវគ្គផ្សេងៗក្នុងជំពូកនីមួយៗបាន ។ សំណួរដែលយើងបានលើកឡើងនៅក្នុងសៀវភៅនេះ គឺគ្រាន់តែជាសំណួរបន្ទាប់បន្សំទៅលើការពិភាក្សាជាមូលដ្ឋានដែលអាចនាំឲ្យពួកគេមានភាពងាយស្រួលក្នុងការពិភាក្សាគ្នាអំពីមេរៀនប៉ុណ្ណោះ ។

**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី៣និង១១

តើព្រះយេស៊ូវបានបង្ហាញថា ទ្រង់ជាព្រះជាម្ចាស់ដោយរបៀបណា?

តើព្រះយេស៊ូវគឺជាព្រះអាទិករដោយរបៀបណាបាន បើទ្រង់ទើបតែចាប់កំណើតជាង២000ឆ្នាំមុនហ្នឹង?

ដោយសារលោកអ្នកដឹងថា ព្រះគ្រីស្ទគឺជាព្រះជាម្ចាស់ តើការនេះបំផ្លាស់បំប្រែជីវិតរស់នៅប្រចាំថ្ងៃរបស់លោកអ្នកយ៉ាងដូចម្ដេច?

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

**ភាពជាមនុស្សរបស់ព្រះយេស៊ូវគ្រីស្ទ** (សំណួរទី១២-១៩)

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី១៣និង១៥

តើមានលក្ខណៈអ្វីខ្លះដែលបង្ហាញថា ព្រះយេស៊ូវជាមនុស្ស?

តាមការយល់ឃើញរបស់លោកអ្នក សូមគិតទៅមើលថា តើហេតុអ្វីបានជាការដែលព្រះជាម្ចាស់មកយកកំណើតជាមនុស្ស ហើយត្រូវល្បួងដូចយើងរាល់គ្នាមានសារៈសំខាន់?

តើភាពជាមនុស្សរបស់ព្រះគ្រីស្ទជួយយើងឲ្យយល់ដឹងពីព្រះជាម្ចាស់យ៉ាងដូចម្ដេច?

នៅពេលដែលលោកអ្នកពិចារណាទៅលើភាពជាព្រះ និងភាពជាមនុស្សរបស់ព្រះយេស៊ូវ តើលោកអ្នកពេញចិត្តនឹងទ្រង់ដែរឬទេ? ហេតុអ្វីបានជាពេញចិត្ត ឬ ហេតុអ្វីបានជាមិនពេញចិត្ត?

នៅក្នុងវគ្គនេះមានសម្រង់សម្ដីបី ។ តើសម្រង់សម្ដីមួយណាដែលបានប៉ះពាល់ចិត្តលោកអ្នកខ្លាំងជាងគេ?

**ការបញ្ចប់កិច្ចពិភាក្សា**

សូមជ្រើសរើសយកសកម្មភាពមួយខាងក្រោមនេះ ដើម្បីបញ្ចប់ការពិភាក្សា ។

**រូបភាពនិងសម្រង់សម្ដី**

ស្នើសុំឲ្យសមាជិកផ្ដល់យោបល់លើ រូបភាព ឬ សម្រង់សម្ដីនៅក្នុងជំពូកនេះ ។ ការឲ្យយោបល់នោះអាចជាមតិដែលបាន

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ប៉ះពាល់ចិត្តពួកគេ ឬជាមតិដែលមិនគាំទ្រ ។

**ការអនុវត្ត**

សូមចងចាំថា លោកអ្នកត្រូវពិភាក្សាលើការអនុវត្តតាមព្រះបន្ទូល ។ បើមិនដូច្នោះទេ ក្រុមរបស់លោកអ្នកនឹងអាចបាត់បង់ផ្នែកដ៏សំខាន់មួយក្នុងនាមជាសិស្សរបស់ព្រះយេស៊ូវជាមិនខាន ។ លោកអ្នកក៏អាចសួរសំណួរថា «តើអត្ថបទព្រះគម្ពីរទាំងនេះបានបំផ្លាស់បំប្រែជីវិតរបស់លោកអ្នកក្នុងអាទិត្យនេះយ៉ាងដូចម្តេច?» ឬក៏សួរថា «តើលោកអ្នកអាចអនុវត្តសេចក្តីពិតទាំងនេះនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់លោកអ្នកនៅសប្តាហ៍នេះដោយរបៀបណា?»

**ការសង្ខេប**

លោកអ្នកអាចនិយាយ ឬសួរថា «សូមយើងទាំងអស់គ្នាសង្ខេបគំនិតចម្បងនៃជំពូកនេះ ។ តើលោកអ្នកដឹងថា ព្រះយេស៊ូវជាព្រះជាម្ចាស់បានដោយរបៀបណា? តើលោកអ្នកដឹងថា ព្រះយេស៊ូវជាមនុស្សបានដោយរបៀបណា?» របៀបមួយទៀតក្នុងការសង្ខេបជំពូកផ្សេងៗនោះគឺ ជ្រើសរើសសមាជិកក្រុមណាម្នាក់ឲ្យអាន ឃ្លាប្រយោគដែលមានសរសេរជាចំណងជើងថា **ចំណុចគួរចងចាំ** ឲ្យឮៗ ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

**ការចូលឲ្យបានស៊ីជម្រៅ**

ដោយសារតែវគ្គនេះមិនមែនជាវគ្គដែលតម្រូវឲ្យសមាជិកក្រុមបំពេញ នោះប្រហែលជាមានអ្នកខ្លះមិនបានបំពេញនោះទេ ។ តែសម្រាប់អ្នកផ្សេងទៀត វគ្គនេះអាចជាវគ្គគន្លឹះដ៏សំខាន់ក្នុងការសិក្សារបស់ពួកគេ ។ លោកអ្នកអាចនឹងសួរនូវសំណួរជាទូទៅមួយដូចជា ៖ «តើមានអ្នកណាចង់ចែកចាយពីអ្វីដែលខ្លួនបានសិក្សាពីវគ្គ **ការចូលឲ្យបានស៊ីជម្រៅ**ដែរឬទេ?»

## ការអធិស្ឋាន

មុនពេលលោកអ្នកអធិស្ឋានជាមួយគ្នាក្នុងការបញ្ចប់ការសិក្សា លោកអ្នកគួរស្នើសុំឲ្យសមាជិកនីមួយៗចែកចាយពីសំណូមពរអធិស្ឋានដែលពួកគេមាននាពេលថ្មីៗនេះ ។ សូមប្រាប់ពួកគេឲ្យច្បាស់ថា ការរក្សាសំណូមពរអធិស្ឋានរបស់សមាជិកក្រុមមិនឲ្យអ្នកផ្សេងទៀតដឹង នោះគឺជាការសំខាន់ណាស់ ។

**គន្លឹះនៃការពិភាក្សា ៖ អ្នកដឹកនាំដែលពូកែ ឬអ្នកសម្របសម្រួល** ក្នុងនាមជាអ្នកដឹកនាំ លោកអ្នកមិនចាំបាច់ដឹងគ្រប់ទាំងចម្លើយនោះទេ ។ លោកអ្នកគឺជាអ្នកសម្របសម្រួល មិនមែនជាអ្នកជំនាញខាងទេវសាស្ត្រនៃព្រះគម្ពីរនោះទេ ។ នៅពេលដែលមានសំណួរពិបាកៗដែលសមាជិកក្នុងក្រុមលើកឡើង លោកអ្នកអាចថា

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៩១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

«ខ្ញុំមិនដឹងចម្លើយនោះទេ តែនោះគឺជាសំណួរដ៏គួរឲ្យចាប់អារម្មណ៍មែន ។ ពេលយើងសិក្សាបន្តទៀតយើងអាចពិចារណាលើសំណួរនោះ ហើយរកចម្លើយនៅពេលក្រោយ» ។ ឬក៏ «តើមានអ្នកណាចង់រកចម្លើយទាក់ទងនឹងសំណួរនេះ ហើយអាចប្រាប់យើងទាំងអស់គ្នានៅសប្ដាហ៍ក្រោយបានដែរឬទេ?» ការនេះបង្ហាញចំពោះសមាជិកនៃក្រុមរបស់លោកអ្នកថា លោកអ្នកកំពុងតែធ្វើដំណើរខាងឯវិញ្ញាណ ហើយក៏កំពុងតែលូតលាស់ក្នុងការយល់ដឹង និងក្នុងជំនឿលើព្រះគ្រីស្ទដូចជាពួកគេផងដែរ ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to [www.cambodianchristianresources.com/dfd-leaders/](www.cambodianchristianresources.com/dfd-leaders/)*

សៀវភៅទី១
ជំពូកទី៣
**ព័ន្ធកិច្ចរបស់ព្រះគ្រីស្ទ ៖**

**គោលបំណងនៃជំពូកនេះគឺ ៖** ដើម្បីឲ្យអាចយល់ផ្នែកផ្សេងៗនៃដំណឹងល្អឲ្យកាន់តែច្បាស់ពីការដែលព្រះគ្រីស្ទបានសុគតជំនួសបាបរបស់យើង ហើយបានរស់ពីស្លាប់ឡើងវិញទុកជាប្រយោជន៍សម្រាប់យើង ។

ចូរចងចាំពីគោលបំណងនៃជំពូកនីមួយៗឲ្យបានច្បាស់ នៅពេលដែលលោកអ្នករៀបចំ ហើយនិងដឹកនាំការពិភាក្សាមេរៀន ។ លោកអ្នកគួរមានគោលបំណងច្បាស់លាស់នៅពេលដែលលោកអ្នកដឹកនាំ ។ ការស្គាល់គន្លឹះ និងគោលការណ៍មេរៀនបានច្បាស់លាស់នៅពេលដឹកនាំ នោះគឺជាទំនួលខុសត្រូវរបស់លោកអ្នក ។

សូមចាប់ផ្តើមការសិក្សាដោយសង្ខេបចំណុចសំខាន់ៗនៃជំពូកមុន ឬក៏ស្នើសុំសមាជិកក្រុមម្នាក់ឲ្យសង្ខេប ។ បន្ទាប់មកស្នើសុំអ្នកណាម្នាក់ឲ្យអានសម្រង់សម្ដីរបស់លោក អិដវើឌ ខ្លាក (Edward Clarke) ឲ្យឮៗនៅទំព័រទី៦២ ។ ព្រមទាំងអានកថាខណ្ឌនៅដើមជំពូកឲ្យឮៗផងដែរ ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

សំណួរដ៏ល្អៗមួយចំនួនសម្រាប់ការពិភាក្សាមានដូចជា សំណួរទី៥, ៨, ១០, ១៦, ១៧និង១៨ ។

**ជីវិតរបស់ព្រះយេស៊ូវគ្រីស្ទ** (សំណួរទី១-៥)

លោកអ្នកគួរចាប់ផ្ដើមដោយការសួរសំណួរទូទៅដូចជា ៖

«តើមានអ្វីខ្លះដែលបានប៉ះពាល់ចិត្តរបស់លោកអ្នកស្ដីពីជីវិតរបស់ព្រះយេស៊ូវ យោងតាមសំណួរផ្សេងៗដែលបានលើកឡើងនៅក្នុងវគ្គទី១នេះ?»

សូមស្ដាប់ចម្លើយគេដោយយកចិត្តទុកដាក់ ហើយជ្រើសរើសម្នាក់ដើម្បីសួរសំណួរបន្ត ។ ចូរចងចាំថា យើងអាចប្រើវិធីនេះនៅក្នុងវគ្គផ្សេងៗនៃជំពូកនីមួយៗបាន ។ សំណួរដែលយើងបានលើកឡើងនៅក្នុងសៀវភៅនេះគ្រាន់តែជាសំណួរបន្ទាប់បន្សំទៅលើការពិភាក្សាជាមូលដ្ឋានដែលអាចនាំឲ្យពួកគេមានភាពងាយស្រួលក្នុងការពិភាក្សាគ្នាអំពីមេរៀនប៉ុណ្ណោះ ។

**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី៥

តើជីវិតរបស់ព្រះយេស៊ូវមានលក្ខណៈខុសប្លែកពីបុរសផ្សេងៗយ៉ាងដូចម្ដេច?

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

**ការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ** (សំណួរទី៦-១០)
**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី៨និង១០

តើហេតុអ្វីបានជាព្រះយេស៊ូវយាងមកសុគត?

**ការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ** (សំណួរទី១១-១៨)
**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី១៦, ១៧និង១៨

ប្រសិនបើព្រះគ្រីស្ទមិនបានរស់ឡើងវិញ តើការសុគតរបស់ទ្រង់មានន័យដែរឬទេ? សូមពន្យល់ ៖

តើបុគ្គលម្នាក់ដែលមិនជឿពីការរស់ឡើងវិញរបស់ព្រះគ្រីស្ទអាចក្លាយជាអ្នកដើរតាមព្រះយេស៊ូវដ៏ពិតបានដែរឬទេ? ហេតុអ្វីបាន ឬហេតុអ្វីមិនបាន?

ស្នើសុំអ្នកណាម្នាក់ឲ្យអានសម្រង់សម្ដីរបស់លោក ភីលីព យេនស៊ី (Phillip Yancey) នៅទំព័រទី៦៤ ។ តើសម្រង់សម្ដីនេះបានប៉ះពាល់ចិត្តរបស់លោកអ្នកយ៉ាងដូចម្ដេច?

**ការបញ្ចប់កិច្ចពិភាក្សា**

សូមជ្រើសរើសយកសកម្មភាពណាមួយខាងក្រោមនេះ (មិនយកទាំងអស់ទេ) ដើម្បីបញ្ចប់ការពិភាក្សា ។

**រូបភាពនិងសម្រង់សម្ដី**

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to [www.cambodianchristianresources.com/dfd-leaders/](www.cambodianchristianresources.com/dfd-leaders/)*

ស្នើសុំឲ្យសមាជិកផ្តល់យោបល់លើ រូបភាព ឬ សម្រង់សម្ពី នៅក្នុងជំពូកនេះ ។ ការឲ្យយោបល់នោះអាចជាមតិដែលបាន ប៉ះពាល់ចិត្តពួកគេ ឬជាមតិដែលមិនគាំទ្រ ។

**ការអនុវត្ត**

សូមចងចាំថា លោកអ្នកត្រូវពិភាក្សាលើការអនុវត្តតាមព្រះបន្ទូល ។ បើមិនដូច្នោះទេ ក្រុមរបស់លោកអ្នកនឹងអាចបាត់បង់ផ្នែកដ៏សំខាន់មួយក្នុងនាមជាសិស្សរបស់ព្រះយេស៊ូវជាមិនខាន ។ លោកអ្នកក៏អាចសួរសំណួរថា «តើអត្ថបទព្រះគម្ពីរទាំងនេះបានបំផ្លាស់បំប្រែជីវិតរបស់លោកអ្នកក្នុងអាទិត្យនេះយ៉ាងដូចម្តេច?» ឬក៏សួរថា «តើលោកអ្នកអាចអនុវត្តសេចក្តីពិតទាំងនេះនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់លោកអ្នកនៅសប្តាហ៍នេះដោយរបៀបណា?»

**ការសង្ខេប**

លោកអ្នកគួរស្នើសុំសមាជិកក្រុមណាម្នាក់ឲ្យអានឃ្លាប្រយោគដែលមានសរសេរជាចំណងជើងថា «**ចំណុចគួរចងចាំ**» ឲ្យឮៗ ។ ឬមួយគ្រាន់តែសួរថា «ប្រសិនបើព្រះជាម្ចាស់នឹងធ្វើការនេះជាថ្មីម្តងទៀត តើលោកអ្នកគិតថា ព្រះជាម្ចាស់នឹងអនុញ្ញាតឲ្យព្រះយេស៊ូវសុគតដែរឬទេ?»

*Pre-release គបស ស្បៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

## **ការចូលឲ្យបានស៊ីជម្រៅ**

ដោយសារតែវគ្គនេះមិនមែនជាវគ្គដែលតម្រូវឲ្យសមាជិកក្រុមបំពេញ នោះប្រហែលជាមានអ្នកខ្លះមិនបានបំពេញនោះទេ ។ តែសម្រាប់អ្នកផ្សេងទៀត វគ្គនេះអាចជាវគ្គគន្លឹះដ៏សំខាន់ក្នុងការសិក្សារបស់ពួកគេ ។ លោកអ្នកអាចនឹងសួរនូវសំណួរជាទូទៅមួយដូចជា ៖ «តើមានអ្នកណាចង់ចែកចាយពីអ្វីដែលខ្លួនបានសិក្សាពីវគ្គ **ការចូលឲ្យបានស៊ីជម្រៅ**ដែរឬទេ?»

## ការអធិស្ឋាន

នៅពេលដែលសមាជិកក្រុមចែកចាយសំណូមពរអធិស្ឋាន នោះមិនចាំបាច់ឲ្យពួកគេពន្យល់សាច់រឿងទាំងមូលនោះទេ ។ សូមប្រាប់ពួកគេឲ្យចែកចាយពីសំណូមពរអធិស្ឋានដោយសង្ខេប (លោកអ្នកត្រូវផ្តល់ជាគំរូក្នុងការចែកចាយផងដែរ) ដើម្បីឲ្យលោកអ្នកមានពេលអធិស្ឋានគ្រប់គ្រាន់ ។

**គន្លឹះនៃការពិភាក្សា ៖** អធិស្ឋាន អធិស្ឋាន ហើយអធិស្ឋាន ការដឹកនាំការពិភាក្សាព្រះគម្ពីរ ភាគច្រើនផ្តោតទៅលើការដកពិសោធន៍ជាមួយព្រះជាម្ចាស់ជាជាងការផ្តោតលើចំណេះដឹង ។ សូមអធិស្ឋានទៅព្រះជាម្ចាស់ឲ្យទ្រង់នាំបុគ្គលម្នាក់ៗនៅក្នុងក្រុមស្គាល់ទ្រង់កាន់តែជ្រាលជ្រៅ ។ ដូចគ្នាផងដែរ សូមអធិស្ឋានពី

*Pre-release គបស ស្បៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

តម្រូវការរបស់ពួកគេម្នាក់ៗ ។ ហើយនៅពេលដែលលោកអ្នកអធិស្ឋានសម្រាប់ពួកគេ នោះព្រះជាម្ចាស់នឹងធ្វើការអស្ចារ្យ!

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

សៀវភៅទី១
ជំពូកទី៤

# ព្រះវិញ្ញាណដែលគង់នៅក្នុងលោកអ្នក

**គោលបំណងនៃជំពូកនេះគឺ៖** ដើម្បីឲ្យដឹងថា ព្រះវិញ្ញាណបរិសុទ្ធរស់នៅក្នុងគ្រប់អ្នកដែលជឿលើព្រះគ្រីស្ទ ហើយព្រះវិញ្ញាណបរិសុទ្ធបណ្តាលឲ្យយើងស្តាប់បង្គាប់ព្រះគ្រីស្ទ ។

មកដល់ពេលនេះ សមាជិកក្រុមរបស់លោកអ្នកគួរតែបានស្គាល់គ្នាច្បាស់ជាងមុនបន្តិចហើយ ប៉ុន្តែប្រហែលជាពួកគេត្រូវការពេលវេលាខ្លះៗ ដើម្បីសួរសុខទុក្ខគ្នា ឬក៏ពិភាក្សាពីរឿងដែលបានកើតឡើងកាលពីសប្តាហ៍កន្លងទៅ ។ ប្រសិនបើលោកអ្នកបង្ហាញថាលោកអ្នកបានស្គាល់ពីតម្លៃរបស់បុគ្គលម្នាក់ៗនៅក្នុងក្រុមរួចហើយនោះអ្នកផ្សេងៗទៀតក៏នឹងដើរតាមគំរូរបស់លោកអ្នក ព្រមទាំងគោរព និងឲ្យតម្លៃគ្នាទៅវិញទៅមកផងដែរ ។

ដូចមុនដែរ លោកអ្នកគួរចាប់ផ្តើមការសិក្សាដោយរំឭកខ្លីៗនូវអ្វីៗដែលលោកអ្នកបានរៀនពីជំពូកមុន ។ លោកអ្នកគួរចាប់ផ្តើមការពិភាក្សាដោយស្នើសុំអ្នកណាម្នាក់ឲ្យអានកថាខណ្ឌនៅដើមជំពូកឲ្យឮៗ ឬក៏ពិភាក្សាគ្នាពីសម្រង់សម្តីរបស់លោក
អេ. ដាប់បិលយូ. ថូហ្ស័រ (A. W. Tozer) នៅទំព័រទី៧៧ ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

នៅចុងបញ្ចប់នៃការសិក្សាវគ្គនេះ សូមប្រាប់ដល់ក្រុមថា រូបភាពនៅទំព័រទី៨៦ក្នុងសៀវភៅមេរៀនរបស់ពួកគេ គឺជាគម្រោងនៃការសិក្សាសៀវភៅទី២ ។ ជំពូកទាំងប្រាំក្នុងសៀវភៅទី២រៀបរាប់ពីអត្ថបទប្រាំយ៉ាងដូចជា ការស្តាប់បង្គាប់ ព្រះបន្ទូល ការអធិស្ឋាន ការប្រកប និងការធ្វើបន្ទាល់ ។ លោកអ្នកគួរលើកទឹកចិត្តក្រុមឲ្យរៀនពីរូបភាពនោះ ដើម្បីឲ្យពួកគេចេះគូររូបភាពនោះឡើងវិញ ព្រមទាំងអាចពន្យល់ពីរូបភាពនោះដល់អ្នកផ្សេងទៀតផងដែរ ។

សំណួរដ៏ល្អៗមួយចំនួនសម្រាប់ការពិភាក្សាមានដូចជា សំណួរទី៣, ៤, ៦, ១១, ១២និង២០ ។

**ការយាងមករបស់ព្រះវិញ្ញាណបរិសុទ្ធ** (សំណួរទី១-៣)
លោកអ្នកគួរចាប់ផ្តើមដោយការសួរសំណួរទូទៅដូចជា ៖

«តើការយាងមករបស់ព្រះវិញ្ញាណបរិសុទ្ធបានប៉ះពាល់ចិត្តរបស់លោកអ្នកយ៉ាងដូចម្តេចខ្លះ នៅពេលដែលលោកអ្នកសញ្ជឹងគិតលើវគ្គដំបូង?»

សូមស្តាប់ចម្លើយរបស់ពួកគេដោយយកចិត្តទុកដាក់ ។ បន្ទាប់មក សួរសំណួរបន្តដោយផ្អែកលើចម្លើយរបស់ពួកគេផ្ទាល់ ។ សូមចងចាំថា គំរូនៃការសួរសំណួរបែបខាងលើនេះអាចប្រើបានគ្រប់

Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៩៩០៤៩១-៧-០
Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/

វគ្គទាំងអស់ ។ សំណួរដែលយើងបានលើកឡើងនៅក្នុងសៀវភៅនេះគ្រាន់តែជាសំណួរបន្ទាប់បន្សំទៅលើការពិភាក្សាជាមូលដ្ឋានដែលអាចនាំឲ្យពួកគេមានភាពងាយស្រួលក្នុងការពិភាក្សាគ្នាអំពីមេរៀនរបស់គេប៉ុណ្ណោះ ។

**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី៣

តាមការយល់ឃើញរបស់លោកអ្នក សូមគិតទៅមើលថា តើហេតុអ្វីបានជាព្រះជាម្ចាស់ចាត់ព្រះវិញ្ញាណបរិសុទ្ធមក បន្ទាប់ពីព្រះយេស៊ូវយាងទៅស្ថានសួគ៌វិញ?

ប្រសិនបើព្រះជាម្ចាស់មិនបានចាត់ព្រះវិញ្ញាណបរិសុទ្ធឲ្យយាងមកទេ តើការនេះនឹងប៉ះពាល់ដល់ជីវិតរបស់លោកអ្នកយ៉ាងដូចម្ដេច?

**ព័ន្ធកិច្ចរបស់ព្រះយេស៊ូវសព្វថ្ងៃ ៖** (សំណួរទី៤-៨)

**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី៤និង៦

តើសព្វថ្ងៃនេះព្រះយេស៊ូវកំពុងតែធ្វើអ្វី?

តើព័ន្ធកិច្ចរបស់ព្រះយេស៊ូវនាពេលបច្ចុប្បន្ននេះបំផ្លាស់បំប្រែលោកអ្នកយ៉ាងដូចម្ដេច នាពេលដែលលោកអ្នករស់នៅប្រចាំថ្ងៃនេះ?

**ការសណ្ឋិតរបស់ព្រះវិញ្ញាណបរិសុទ្ធ** (សំណួរទី៩-១១)


*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី១១

តើបុគ្គលម្នាក់អាចដឹងថា ខ្លួនមានព្រះវិញ្ញាណបរិសុទ្ធ គង់នៅជាមួយបានដោយរបៀបណា?

**ការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ** (សំណួរទី១២-១៨)

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី១២

តើព្រះវិញ្ញាណបរិសុទ្ធកំពុងតែដឹកនាំលោកអ្នកឲ្យធ្វើអ្វី?

តើព្រះវិញ្ញាណបរិសុទ្ធធ្លាប់ជួយលោកអ្នកក្នុងការដឹងជាក់លាក់អ្វីខ្លះ?

**ការពេញដោយព្រះវិញ្ញាណបរិសុទ្ធ** (សំណួរទី១៩-២០)

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី២០

តើការគ្រប់គ្រង ការសណ្ឋិត និងការពេញដោយព្រះវិញ្ញាណបរិសុទ្ធមានទំនាក់ទំនងគ្នាយ៉ាងដូចម្ដេច?

តើលោកអ្នកមានអារម្មណ៍យ៉ាងដូចម្ដេច ចំពោះការគ្រប់គ្រង ការសណ្ឋិត និងការពេញដោយព្រះវិញ្ញាណបរិសុទ្ធ? នៅពេលដែលលោកអ្នកពិចារណាលើភាពពិតជាក់ស្ដែងទាំងបីនេះ តើលោកអ្នកមានអារម្មណ៍បែបណាផុសចេញមក?

តើព្រះវិញ្ញាណបរិសុទ្ធកំពុងធ្វើការអ្វីខ្លះសព្វថ្ងៃនេះនៅក្នុងជីវិតរបស់លោកអ្នក?

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

សូមពិភាក្សាពីរូបភាពកង់រទេះជាមួយក្រុមរបស់លោកអ្នក ។ បន្ទាប់មកលោកអ្នកអាចពន្យល់ពីចំណុចនីមួយៗនៅក្នុងរូបភាពនោះ ស្របពេលដែលលោកអ្នកកំពុងតែគូររូបនោះលើក្ដារខៀន ឬលើផ្ទាំងក្រដាស់ ។ បន្ទាប់ពីនោះទៀត សូមលើកទឹកចិត្តពួកគេឲ្យសិក្សាលើរូបភាពកង់រទេះដ៏មានសារៈសំខាន់នេះ រហូតទាល់តែពួកគេអាចពន្យល់ពីរូបភាពនោះដល់អ្នកផ្សេងទៀតដោយសាមញ្ញ ហើយច្បាស់លាស់ ។

## ការបញ្ចប់កិច្ចពិភាក្សា

សូមជ្រើសរើសយកសកម្មភាពណាមួយខាងក្រោមនេះ (មិនយកទាំងអស់ទេ) ដើម្បីបញ្ចប់ការពិភាក្សា ។

## រូបភាពនិងសម្រង់សម្ពី

ស្នើសុំឲ្យសមាជិកទាំងអស់ផ្ដល់យោបល់លើ រូបភាព ឬ សម្រង់សម្ពីនៅក្នុងជំពូកនេះ ការឲ្យយោបល់នោះអាចជាមតិដែលបានប៉ះពាល់ចិត្តពួកគេ ឬជាមតិដែលមិនគាំទ្រក៏បាន ។

## ការអនុវត្ត

សូមចាំជានិច្ចថា លោកអ្នកត្រូវពិភាក្សាលើការអនុវត្តផ្ទាល់ខ្លួនទៅនឹងព្រះបន្ទូល ។ លោកអ្នកក៏អាចសួរនូវសំណួរថា «តើអត្ថបទព្រះគម្ពីរទាំងនេះ បានប៉ះពាល់ចិត្តលោកអ្នកតាមរបៀបណាខ្លះ នៅពេលដែលពិចារណាលើការសិក្សាទៅនឹងព្រះបន្ទូលក្នុង

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

អាទិត្យនេះ? តើលោកអ្នកអាចអនុវត្តសេចក្តីពិតទាំងនេះនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់លោកអ្នកនៅសប្តាហ៍នេះដោយរបៀបណា?»

## ការសង្ខេប

លោកអ្នកគួរស្នើសុំសមាជិកក្រុមណាម្នាក់ឲ្យអានឃ្លាប្រយោគដែលមានសរសេរជាចំណងជើងថា ចំណុចគួរចងចាំឲ្យឮៗ ។ ឬមួយស្នើសុំសមាជិកក្រុមឲ្យបំពេញឃ្លានេះ ៖ «យោងតាមការសិក្សានេះ ខ្ញុំដឹងថាព្រះវិញ្ញាណបរិសុទ្ធសណ្ឋិតក្នុងខ្ញុំព្រោះ...» ។

## ការចូលឲ្យបានស៊ីជម្រៅ

ដោយសារតែវគ្គនេះមិនមែនជាវគ្គដែលតម្រូវឲ្យបំពេញនោះប្រហែលជាមានអ្នកខ្លះមិនបានបំពេញដោយពេញលេញនោះទេ ។ តែសម្រាប់អ្នកផ្សេងទៀត វគ្គនេះអាចជាវគ្គគន្លឹះដ៏សំខាន់ក្នុងការសិក្សារបស់ពួកគេ ។ លោកអ្នកអាចនឹងសួរនូវសំណួរជាទូទៅមួយដូចជា «តើមានអ្នកណាចង់ចែកចាយនូវអ្វីដែលខ្លួនបានរៀនពីវគ្គ **ចូលឲ្យបានស៊ីជម្រៅ**ដែរឬទេ?»

*Pre-release គបស ស្បៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

## ការរំឭកឡើងវិញ

ដោយសារជំពូកនេះ គឺជាជំពូកចុងក្រោយនៃសៀវភៅទី១ ដូច្នេះ សូមចំណាយពេលខ្លះដើម្បីរំឭកមេរៀនផ្សេងៗឡើងវិញដែលលោកអ្នកបានសិក្សាកាលពីសប្ដាហ៍កន្លងទៅ ។ សូមលើកទឹកចិត្តសមាជិកក្នុងក្រុមឲ្យបន្តការសិក្សាលើសៀវភៅទី២ ។ លោកអ្នកគួរសួរសំណួររំឭកដូចជា ៖

តើលោកអ្នកចូលចិត្តចំណុចអ្វីខ្លះក្នុងសៀវភៅទី១?

តើមានចំណុចណាខ្លះដែលបានប៉ះពាល់ចិត្តលោកអ្នកខ្លាំងជាងគេបំផុត ចេញពីការសិក្សារបស់យើងនៅក្នុងសប្ដាហ៍កន្លងទៅនេះ?

តើលោកអ្នកចង់សិក្សាសៀវភៅទី២ដែរឬទេ?

តើលោកអ្នកគិតថា យើងគួរផ្លាស់ប្ដូររបៀបសិក្សារបស់យើងត្រង់ចំណុចណាខ្លះ ដើម្បីជួយឲ្យយើងកាន់តែចម្រើនឡើងក្នុងការសិក្សាបន្ថែមទៀត?

បន្ទាប់មកសូមចែកសៀវភៅទី២ដល់អស់អ្នកដែលចង់បន្តការសិក្សា

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ហើយប្រាប់ពួកគេពីលំហាត់ដែលត្រូវបំពេញ និងពីទីកន្លែងសិក្សាផងដែរ ។

## ការអធិស្ឋាន

នៅពេលដែលសមាជិកក្រុមចែកចាយសំណូមពរអធិស្ឋាន សូមកត់សំណូមពរអធិស្ឋានរបស់ពួកគេនៅក្នុងកូនសៀវភៅមួយ ។ ការធ្វើដូច្នេះបង្ហាញថា លោកអ្នកពិតជាចង់ចងចាំ ហើយនិងចង់អធិស្ឋានពីសំណូមពររបស់ពួកគេមែន ។ បន្ទាប់មក ស្នើសុំឲ្យសមាជិកក្រុមចែកចាយពីរបៀបដែលព្រះជាម្ចាស់បានឆ្លើយតបទៅនឹងសំណូមពរអធិស្ឋានរបស់ពួកគេដែលបានលើកឡើងកាលពីសប្តាហ៍មុនៗ ។ សូមចំណាយពេលខ្លះ ដើម្បីសរសើរតម្កើងព្រះជាម្ចាស់ពីភាពសប្បុរស និងភាពស្មោះត្រង់របស់ទ្រង់ដែលមានចំពោះយើង ។

**គន្លឹះនៃការពិភាក្សា ៖ លើកសំណួរទៅអ្នកផ្សេងវិញ**

ពេលខ្លះសមាជិកក្រុមនឹងចង់តាំងឲ្យលោកអ្នកធ្វើជាអ្នកជំនាញខាងការឆ្លើយសំណួរ ។ ប្រសិនបើពួកគេតែងតែសួរសំណួរដល់លោកអ្នកដែលជាអ្នកដឹកនាំ លោកអ្នកគួរលើកសំណួរនោះទៅអ្នកផ្សេងទៀតដោយសួរថា «នេះគឺជាសំណួរដ៏ល្អ ចុះតើអ្នកផ្សេងទៀតមាន

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

យោបល់យ៉ាងដូចម្ដេចវិញ?»

**ការវាយតម្លៃពីភាពដឹកនាំរបស់លោកអ្នក**

លោកអ្នកអាចប្រើសំណួរខាងក្រោមនេះ ដើម្បីវាយតម្លៃ និងជួយអភិវឌ្ឍលើការដឹកនាំរបស់លោកអ្នកទុកសម្រាប់ថ្ងៃអនាគតបន្ទាប់ពីលោកអ្នកបានសិក្សាលើវគ្គនីមួយៗ ។ ប្រសិនបើលោកអ្នកមានដៃគូដឹកនាំ សូមពិភាក្សាសំណួរទាំងនេះជាមួយគ្នា បន្ទាប់ពីពិភាក្សាជាក្រុមរួចមក ។ ហើយប្រសិនបើឃើញចំណុចខ្សោយណាមួយ នោះចូរអភិវឌ្ឍចំណុចនោះ ដើម្បីឲ្យការដឹកនាំរបស់លោកអ្នកកាន់តែមានប្រសិទ្ធភាពឡើង ។

១. តើលោកអ្នកចេះមេរៀនច្បាស់ ហើយអាចដឹកនាំបានយ៉ាងល្អហើយឬនៅ?

២. តើលោកអ្នកបានត្រៀមសំណួរគ្រប់គ្រាន់ ដើម្បីដឹកនាំការពិភាក្សាឲ្យបានល្អហើយឬនៅ?

៣. តើលោកអ្នកបានស្ដាប់ចម្លើយរបស់អ្នកផ្សេងៗដោយយកចិត្តទុកដាក់ ហើយបានសួរសំណួរបន្តដ៏ល្អហើយ ឬនៅ?

៤. តើលោកអ្នកបានពិភាក្សាលើចំណុចសំខាន់ៗនៅក្នុងជំពូកនីមួយៗហើយឬនៅ?

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to [www.cambodianchristianresources.com/dfd-leaders/](www.cambodianchristianresources.com/dfd-leaders/)*

៥. តើសមាជិកក្រុមមានការលូតលាស់ខាងការទុកចិត្តគ្នាទៅវិញទៅមកដែរឬទេ? តើពួកគេបានចែកចាយពីអ្វីដែលមាននៅក្នុងចិត្ត  និងក្នុងគំនិតដែរឬទេ?

៦. តើការពិភាក្សាអាចយកមកអនុវត្តជាក់ស្តែងបានដែរឬទេ?

៧. តើសមាជិកក្រុមទាំងអស់មានការរួបរួមក្នុងការពិភាក្សាដែរឬទេ?

៨. តើលោកអ្នកបានចាប់ផ្តើម  ហើយនិងបញ្ចប់ការសិក្សាបានយ៉ាងទៀងទាត់ដែរឬទេ?

*Pre-release គបស  សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣  NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

# សៀវភៅទី២
# អ្នកដើរតាមព្រះយេស៊ូវដែល
# ពេញដោយព្រះវិញ្ញាណ

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information,*
*come back to [www.cambodianchristianresources.com/dfd-leaders/](www.cambodianchristianresources.com/dfd-leaders/)*

## សៀវភៅទី២

## សេចក្ដីផ្ដើម

ការចាប់ផ្ដើមសិក្សាសៀវភៅទី២ នោះនឹងជួយលើកទឹកចិត្តសមាជិកក្រុមរបស់លោកអ្នកឲ្យប្ដេជ្ញាចិត្តក្នុងការទន្ទេញខគម្ពីរចងចាំនៅក្នុងជំពូកនីមួយៗ ។ ប្រសិនបើសមាជិកក្រុមរបស់លោកអ្នកមិនមានបទពិសោធន៍ក្នុងការទន្ទេញខគម្ពីរចងចាំទេ ដូច្នេះចំណុចនីមួយៗខាងក្រោមនេះនឹងជួយលោកអ្នកក្នុងការជំរុញចិត្តពួកគេឲ្យចាប់ផ្ដើមដាក់ពិន័យ ដើម្បីទន្ទេញខគម្ពីរចងចាំ ។ នៅពេលដែលសមាជិកក្រុមរបស់លោកអ្នករំឭកខគម្ពីរចងចាំជាមួយគ្នាទៅវិញទៅមក សូមឲ្យពួកគេចែកចាយតែមួយឬពីរខក្នុងមួយសប្ដាហ៍បានហើយ ។

## ហេតុអ្វីបានជាត្រូវចងចាំខគម្ពីរ?

លោកអ្នកនឹងមិនអាចរកឃើញពាក្យថា «ទន្ទេញខគម្ពីរ» នៅក្នុងព្រះគម្ពីរបានឡើយ ។ ប៉ុន្តែនៅក្នុងព្រះគម្ពីរមានបង្កប់នូវផ្នត់គំនិតនិងគំរូនោះ («កំណត់ចាំ...ទុក» ព្រះបន្ទូលនៅក្នុងចិត្ត) ។ ព្រះបន្ទូលបានលើកទឹកចិត្តយើងឲ្យ ៖ «ស្វែងរក...សញ្ជឹងគិត...មានចិត្តរីករាយចំពោះ...ឥតភ្លេច» ព្រះបន្ទូលឡើយ (ទំនុកដំកើង ១១៩:៩-១៦, ៣៧:៣១) ។

Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០
Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/

. «រក្សាទុក...ប្រុងស្តាប់...ផ្ទៀងត្រចៀកស្តាប់...ត្រូវឲ្យរក្សា [ព្រះបន្ទូល] ទុកនៅកណ្តាលដួងចិត្តឯងវិញ» (សុភាសិត ៤:៤, ២០-២២) ។

. «ចូរចង[បញ្ញត្តិរបស់អញ]នៅកឯងចុះ...ហើយចារិកទុកនៅដួងចិត្តឯងដែរ» (សុភាសិត ៣:៣) ។

. «ចូររក្សាអស់ទាំងពាក្យរបស់អញ ហើយប្រមូលអស់ទាំងបណ្តាំអញទុកនៅនឹងឯងចុះ ត្រូវឲ្យរក្សាបណ្តាំអញទាំងប៉ុន្មានដើម្បីឲ្យបានរស់នៅ ព្រមទាំងឱវាទអញ ដូចជារក្សាប្រស្រីភ្នែកឯងដែរ ចូរចងភ្ជាប់នៅម្រាមដៃ ហើយកំណត់ទុកនៅក្នុងដួងចិត្តឯងផង» (សុភាសិត ៧:១-៣) ។

. «ដ្បិតបើឯងរក្សាទុកសេចក្តីនោះនៅក្នុងខ្លួន នោះសប្បាយហើយគឺបើសេចក្តីនោះស្ថិតនៅជាប់នឹងបបូរមាត់ឯង» (សុភាសិត ២២:១៨) ។

. «សញ្ជឹងគិតលើ [ព្រះបន្ទូលព្រះជាម្ចាស់] ទាំងយប់ទាំងថ្ងៃ» (យ៉ូស្វេ ១:៨) ។

ខគម្ពីរទាំងនេះនិងខគម្ពីរផ្សេងៗទៀតជួយពន្យល់ហេតុផលនិងផ្តល់នូវសារប្រយោជន៍នៃការទន្ទេញខគម្ពីរ៖

. «ប្រយោជន៍កុំឲ្យទូលបង្គំធ្វើបាបនឹងទ្រង់ឡើយ...ឯជំហាននៃទូលបង្គំ ក៏នឹងមិនភាំងភ្លាត់ឡើយ» (ទំនុកដំកើង ១១៩:៩-១៦,

៣៧:៣១)

. «ជាជីវិត និងជាសេចក្ដីសុខស្រួល ដល់ខ្លួនប្រាណទាំងមូលផង» (សុភាសិត ៤:២២) ។

. «បានប្រកបដោយគុណ និងបំណាងល្អចំពោះព្រះ ហើយនឹងមនុស្សផង» (សុភាសិត ៣:៤) ។

. «បានទុកចិត្តដល់ព្រះយេហូវ៉ា» (សុភាសិត ២២:១៩) ។

. «ប្រព្រឹត្តតាមអស់ទាំងសេចក្ដី ដែលកត់ទុកក្នុងគម្ពីរនេះឯង ដ្បិតគឺយ៉ាងនោះដែលឯងនឹងបានកើតការនៅគ្រប់ទាំងផ្លូវឯង ហើយនឹងបានចំរើនឡើងផង »(យ៉ូស្វេ ១:៨) ។

. «ដើម្បីឲ្យសេចក្ដីនោះស្ថិតនៅជាប់នឹងបបូរមាត់ឯង» (សុភាសិត ២២:១៨) ។

. «ទូលបង្គំបានឃើញព្រះបន្ទូលទ្រង់ ទូលបង្គំក៏បានទទួលទានលេបចូលអស់ហើយ ព្រះបន្ទូលរបស់ទ្រង់ជាសេចក្ដីអំណរ ហើយជាទីរីករាយចិត្តដល់ទូលបង្គំ ដ្បិតឱព្រះយេហូវ៉ា ជាព្រះនៃពួកពលបរិវារអើយ ទូលបង្គំបានហៅតាមព្រះនាមទ្រង់» (យេរេមា ១៥:១៦) ។

ការដែលព្រះជាម្ចាស់ប្រើបុគ្គលណាម្នាក់ដែលបានចំណាយពេលវេលាខិតខំទន្ទេញខគម្ពីរជាប្រចាំឲ្យធ្វើការអស្ចារ្យ នោះជាហេតុដែលជំរុញឲ្យយើងចង់ទន្ទេញខគម្ពីរខ្លាំងជាងហេតុផលមួយចំនួនខាងលើ

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៩៩០៤៩១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

នេះទៅទៀត ។ នៅពេលដែលព្រះយេស៊ូវប្រឈមមុខជាមួយនឹងសាតាំង (ម៉ាថាយ ៤:៤-១១) ទ្រង់បានលើកយកខគម្ពីរជាច្រើនដែលទ្រង់បានចងចាំតាំងពីទ្រង់នៅក្មេង ដើម្បីតទល់នឹងការបញ្ឆោតរបស់សាតាំង ហើយតយុទ្ធនឹងសេចក្តីល្បួង ។ នៅពេលដែលសាវ័កពេត្រុសអធិប្បាយទៅកាន់ហ្វូងមនុស្សនៅថ្ងៃបុណ្យទីហាសិប គាត់មិនមានពេលវេលាក្នុងការពិគ្រោះសិក្សាលើពាក្យនីមួយៗនៃព្រះបន្ទូល និងរៀបចំសេចក្តីអធិប្បាយរបស់គាត់នោះទេ តែគាត់បានជ្រើសយកការទន្ទេញខគម្ពីរជាអាទិភាពចម្បងនៅក្នុងជីវិតរបស់គាត់រួចទៅហើយ ។ ដូច្នេះគាត់អាចលើកឡើងនូវខគម្ពីរចំនួនបីកន្លែងខុសៗគ្នាពីក្នុងកណ្ឌគម្ពីរសញ្ញាចាស់ ហើយខគម្ពីរទាំងនោះបាននាំមនុស្សចំនួន៣000នាក់ឲ្យថ្វាយខ្លួនទទួលជឿលើព្រះយេស៊ូវ ។

«ខ្ញុំមានការភ្ញាក់ផ្អើលជាខ្លាំងចំពោះកាលៈទេសៈដ៏ច្រើនលើសលប់ពីការដែលព្រះជាម្ចាស់បានប្រទាននូវខគម្ពីរដែលខ្ញុំបានចងចាំ ដើម្បីប្រើប្រាស់ទៅតាមស្ថានភាពជាក់លាក់ និងពេលវេលាដ៏ត្រឹមត្រូវ ។ ជួនកាលខគម្ពីរទាំងនោះចូលមកដើម្បីកំសាន្តចិត្ត ។ ហើយពេលខ្លះទ្រង់បានប្រទានខគម្ពីរទាំងនោះមក ដើម្បីដឹកនាំ ជួនកាលជំរុញយើងឲ្យទៅមុខឬទាញយើងឲ្យឈប់ ជាការរំឭកពីសេចក្តីសន្យារបស់ទ្រង់ ជាប្រភពប្រាជ្ញា ជាពាក្យប្រឹក្សាដល់អ្នកដទៃទៀត ឬក៏

Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០
Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/

ជាការយល់ឃើញយ៉ាងស៊ីជម្រៅដល់អស់អ្នកដែលកំពុងតែស្វែងរកព្រះអម្ចាស់»
លោក ដែននីស ស្តូខស៍, ជាបុគ្គលិកម្នាក់របស់ Navigator (Dennis Stokes, Navagator Staff)

ប្រសិនបើលោកអ្នកចង់ប្រដាប់ខ្លួន ដើម្បីតយុទ្ធជាមួយសាតាំង នោះត្រូវតស៊ូជាមួយនឹងបាប ទុកចិត្ត ហើយស្តាប់បង្គាប់ព្រះជាម្ចាស់ ស្តាប់សំឡេងរបស់ព្រះជាម្ចាស់ បន្ទាប់មកចូលរួមក្នុងព័ន្ធកិច្ចនៃការបម្រើដល់អ្នកដទៃ នោះលោកអ្នកត្រូវតែចំណាយពេលទន្ទេញខគម្ពីរឲ្យបានជាប្រចាំ ។

ចំណុចចាប់ផ្តើមដែលល្អ គឺយើងគួរតែពិចារណាទៅលើតម្លៃ និងសារប្រយោជន៍នៃការទុកព្រះបន្ទូលព្រះជាម្ចាស់នៅក្នុងចិត្តរបស់យើងតាមរយៈការទន្ទេញចាំមាត់ ។ បន្ទាប់មកលោកអ្នកត្រូវបង្ហាញពីវិធីនៃការទន្ទេញខគម្ពីរដល់សមាជិកក្រុមផងដែរ ។ លោកអ្នកគួរតែស្វែងរកវិធីសាស្ត្រល្អៗ ដើម្បីប្រើក្នុងការរំឭកខគម្ពីរទុកជាទម្លាប់ ។

សូមលើកទឹកចិត្តសមាជិកក្រុមឲ្យសរសេរខគម្ពីរចងចាំនៅលើក្រដាសតូចមួយ ហើយដាក់តាមខ្លួនជាប្រចាំ ។វិធីសាស្ត្រមួយទៀតគឺ យើងអាចដាក់ខគម្ពីរទាំងនោះនៅកន្លែងណាដែលយើង

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

អាចមើលបាន ដូចជានៅលើកញ្ចក់កុំព្យូទ័រជាដើម ។ សូមរំឭកខគម្ពីរទាំងនោះដោយអានឲ្យលឺៗជាប្រចាំ ។ សូមចម្លងខគម្ពីរទាំងនោះសាចុះសាឡើងរហូតទាល់តែលោកអ្នកអាចសរសេរវាបានដោយមិនចាំបាច់មើល ។ សូមសញ្ជឹងគិតលើខគម្ពីរទាំងនោះ ហើយអធិស្ឋានឲ្យលោកអ្នកបានដូចជាអ្វីដែលខគម្ពីរបានថែង ។សូមប្រាប់ពីអត្ថន័យនៃខគម្ពីរត្រង់ចំណុចនេះចំពោះជីវិតរបស់លោកអ្នកដល់មិត្រភក្តិណាម្នាក់ ។ ពេលយប់មុនចូលគេងត្រូវគិតអំពីខគម្ពីរនោះ ។ហើយរង់ចាំស្តាប់នូវអ្វីដែលព្រះជាម្ចាស់នឹងមានបន្ទូលមកកាន់លោកអ្នក ។ គន្លឹះនៃការទន្ទេញខគម្ពីរឲ្យចាំគឺ ត្រូវមើលហើយមើលទៀតដដែលៗ ។

ដកស្រង់ចេញពីសៀវភៅ «The Heart Beat of Jesus» Bible study. Copyright ២០០៥ ហើយបានទទួលការអនុញ្ញាតិសម្រាប់ប្រើប្រាស់ពីក្រុម The Navigators' National Training Team ដើម្បីឲ្យលោកអ្នកចំណេញពេលវេលានោះ ចូរត្រលប់ទៅមើលផ្នែកខាងដើមនៃសៀវភៅនេះ ដើម្បីរំឭកពីរបៀប និងគោលការណ៍នៃការដឹកនាំ មុនពេលដែលលោកអ្នកចាប់ផ្តើមសិក្សាសៀវភៅទី២ ។ សូមពិចារណាពីរបៀបជាក់លាក់មួយចំនួនដែលលោកអ្នកចង់អភិវឌ្ឍខ្លួនក្នុងនាមជាអ្នកដឹកនាំលើការសិក្សាព្រះបន្ទូលនៅពេលដែល

លោកអ្នកសិក្សាសៀវភៅទី២នេះ ។  ចូរទូលសូមឲ្យព្រះជាម្ចាស់ជួយលោកអ្នកឲ្យក្លាយជាបុរស  ឬស្ត្រីដែលពេញវ័យខាងឯព្រះបន្ទូល ។

*Pre-release គបស  សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣  NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

## សៀវភៅទី២
## ជំពូកទី១
## អ្នកដើរតាមព្រះយេស៊ូវដែលស្ដាប់បង្គាប់

**គោលបំណងនៃជំពូកនេះគឺ៖** ដើម្បីស្វែងយល់ឲ្យឃើញថា ការស្ដាប់បង្គាប់ដែលផ្អែកលើការជឿទុកចិត្ត គឺជាគុណតម្លៃដ៏សំខាន់បំផុតនៃសេចក្ដីស្រឡាញ់ដែលយើងមានចំពោះព្រះយេស៊ូវគ្រីស្ទ ។

លោកអ្នកអាចចាប់ផ្ដើមថ្នាក់នេះដោយអានសេចក្ដីផ្ដើមនៃសៀវភៅទី២ ចាប់ផ្ដើមពីទំព័រទី៣ទៅ ។ បន្ទាប់មកសូមរំឭករូបភាពកង់រទេះដែលមាននៅទំព័រទី១០ នោះគឺជាជំនួយមួយសម្រាប់យើងក្នុងការថ្លឹងថ្លែងពីការបោះជំហានរបស់យើងជាមួយនឹងព្រះគ្រីស្ទ ។ នៅពេលដែលពួកគេកំពុងពន្យល់នូវផ្នែកសំខាន់នីមួយៗដល់អ្នកឯទៀត លោកអ្នកក៏ត្រូវលើកទឹកចិត្តសមាជិកម្នាក់ៗឲ្យចេះគូររូបភាពនេះដែរ ។

វាជាការសំខាន់ណាស់ក្នុងការដែលលោកអ្នកពិភាក្សាពីផលប្រយោជន៍នៃការទន្ទេញខគម្ពីរនៅក្នុងក្រុម មុនពេលចាប់ផ្ដើមថ្នាក់រៀន ។ លោកអ្នកគួរអានគោលគំនិតជាទូទៅនៃគោលការណ៍ក្នុងការទន្ទេញខគម្ពីរដែលមាននៅក្នុងសៀវភៅសម្រាប់គ្រូនេះដោយផ្ទាល់ ។ ជាមួយគ្នានេះផងដែរ សូមចែកចាយពីជំនឿដ៏ជាក់លាក់

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

និងការអនុវត្តរបស់លោកអ្នកក្នុងការទន្ទេញខគម្ពីរ ។ សូមឲ្យក្រុមរបស់លោកអ្នកសម្រេចថា គេនឹងប្ដេជ្ញាចិត្ត ដើម្បីទន្ទេញខគម្ពីរមួយខក្នុងមួយសប្ដាហ៍ នៅពេលដែលគេសិក្សាសៀវភៅទី២នេះ ។ ប្រសិនបើគេយល់ព្រម សូមចំណាយពេលខ្លះៗនៅចុងម៉ោង ដើម្បីជួយឲ្យពួកគេចងចាំខគម្ពីរនៅសប្ដាហ៍នេះជាមួយគ្នា ។

សំណួរដ៏ល្អៗមួយចំនួនសម្រាប់ការពិភាក្សាមានដូចជា សំណួរទី៤, ៨, ១១, ១៥, ១៦, ១៩និង២០ ។

## មូលដ្ឋានគ្រឹះនៃការស្ដាប់បង្គាប់ ៖ ការរំពឹងមើលព្រះជាម្ចាស់

(សំណួរទី១-៧)

លោកអ្នកអាចចាប់ផ្ដើមការពិភាក្សាដោយសួរសំណួរទូទៅដូចជា ៖ «តើមានអ្វីដែលបានប៉ះពាល់ចិត្តរបស់លោកអ្នកនៅពេលដែលលោកអ្នកពិចារណាលើវគ្គដំបូងនេះ?»

សូមស្ដាប់ចម្លើយគេដោយយកចិត្តទុកដាក់ ហើយជ្រើសរើសយកម្នាក់មក ដើម្បីសួរសំណួរបន្ត ។ ចូរចងចាំថា យើងអាចប្រើវិធីនេះនៅក្នុងវគ្គផ្សេងៗក្នុងជំពូកនីមួយៗបាន ។ សំណួរដែលយើងបានលើកឡើងនៅក្នុងសៀវភៅនេះគ្រាន់តែជាសំណួរបន្ទាប់បន្សំទៅលើការពិភាក្សាជាមូលដ្ឋានដែលអាចនាំឲ្យពួកគេមានភាពងាយស្រួលក្នុងការពិភាក្សាគ្នាអំពីមេរៀនប៉ុណ្ណោះ ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី៤

តើការយល់ដឹងពីលក្ខណៈរបស់ព្រះជាម្ចាស់ ជះឥទ្ធិពលដល់ការស្តាប់បង្គាប់របស់យើងចំពោះទ្រង់យ៉ាងដូចម្តេច?

ហេតុអ្វីបានជាការដែលយើងស្តាប់បង្គាប់ព្រះជាម្ចាស់នាំការល្អដល់យើង?

តើសេចក្តីស្រឡាញ់មានសារៈសំខាន់ក្នុងទំនាក់ទំនងរវាងយើងនឹងព្រះជាម្ចាស់យ៉ាងដូចម្តេច?

**ការស្តាប់បង្គាប់តាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់ជីវិតរបស់លោកអ្នក** (សំណួរទី៨-១២)

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី៨និង១១

ហេតុអ្វីបានជាព្រះគម្ពីរផ្តោតសំខាន់លើការស្តាប់បង្គាប់?

**ការរស់នៅដោយស្តាប់បង្គាប់** (សំណួរទី១៣-២០)

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី១៥, ១៦, ១៩និង២០

សូមពណ៌នាពីផ្នែករបស់ព្រះជាម្ចាស់ និងផ្នែករបស់លោកអ្នកក្នុងជីវិតរស់នៅដោយការស្តាប់បង្គាប់ ។

ហេតុអ្វីបានជាអាកប្បកិរិយានៃការស្តាប់បង្គាប់របស់យើងមានសារៈសំខាន់ម្ល៉េះ?

តើសេចក្តីល្បួងនិងអំពើបាបមានភាពខុសគ្នាដូចម្តេចខ្លះ?

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

តើមនុស្សធ្លាក់ចូលក្នុងអំពើបាបដោយឯកឯង ឬក៏មានគម្រោងប្រព្រឹត្តបាប?
តើដំណោះស្រាយរបស់ព្រះជាម្ចាស់ទៅនឹងបាបគឺជាអ្វី?

បើព្រះជាម្ចាស់ជ្រាបការគ្រប់យ៉ាងទៅហើយ ចុះហេតុអ្វីបានជាយើងត្រូវតែលន់តួបាបរបស់យើង?
តើជីវិតរបស់លោកអ្នកធ្លាប់ដែលបានយកឈ្នះលើបាបត្រង់ផ្នែកណាខ្លះនាពេលថ្មីៗនេះ?

## ការបញ្ចប់កិច្ចពិភាក្សា

នៅពេលដែលលោកអ្នកឈានចូលដល់ការបញ្ចប់កិច្ចពិភាក្សា សូមកុំភ្លេចទុករយៈពេលពី៥-១០នាទី ដើម្បីចែកចាយពីសកម្មភាពដូចខាងក្រោម ។ លោកអ្នកអាចស្នើសុំអ្នកណាម្នាក់ដែលបានបញ្ចប់វគ្គ **ការចូលឲ្យបានស៊ីជម្រៅ** ឲ្យមកចែកចាយនូវអ្វីដែលប៉ះពាល់ចិត្តរបស់ពួកគេក្នុងមេរៀន ។ ឬក៏បញ្ចូលពេលវេលាខ្លះៗ ដើម្បីឲ្យគេអាចចែកចាយការអនុវត្តផ្ទាល់ខ្លួនពីការសិក្សានេះ ឬក៏ស្នើសុំអ្នកណាម្នាក់ឲ្យសង្ខេបមេរៀនក៏បានដែរ ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

## ការអធិស្ឋាន

សូមកុំភ្លេចអធិស្ឋានយ៉ាងអស់ពីចិត្ត និងឲ្យបានទៀងទាត់សម្រាប់សមាជិកក្រុមរបស់លោកអ្នក ។ ពួកគេម្នាក់ៗមានតម្រូវការផ្សេងៗគ្នាដែលលោកអ្នកអាចអធិស្ឋានឲ្យបាន ។ សូមស្វែងយល់អំពីការនេះ ។ សូមលើកទឹកចិត្តសមាជិកក្រុមទាំងឡាយឲ្យប្រើប្រាស់តារាងនៃសេចក្ដីអធិស្ឋានប្រចាំសប្ដាហ៍របស់ពួកគេ ហើយអធិស្ឋានឲ្យគ្នាទៅវិញទៅមកពេញមួយសប្ដាហ៍ ។

**សំណើសម្រាប់ការទន្ទេញខគម្ពីរចងចាំ**

សូមពិភាក្សាជាមួយក្រុមរបស់លោកអ្នកពីគុណតម្លៃនៃការទន្ទេញខគម្ពីរចងចាំ ។ បន្ទាប់មកសួរពួកគេថាតើផលប្រយោជន៍នៃការទន្ទេញព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។ សួរពួកគេប្រសិនបើ ចង់រំឭកខគម្ពីរប្រចាំសប្ដាហ៍នីមួយៗនោះឡើងវិញ ។ ប្រសិនបើចង់ លោកអ្នកអាចឲ្យពួកគេចាប់ផ្ដើមធ្វើនៅសប្ដាហ៍នេះ ឬសប្ដាហ៍ក្រោយក៏បាន ។ មានរបៀបល្អៗជាច្រើនក្នុងការរំឭកខគម្ពីរចងចាំជាមួយគ្នាដូចជា ៖ ការសូត្រឲ្យឮៗឡើងវិញទាំងអស់គ្នា ការសូត្រទៅវិញទៅមកជាមួយដៃគូ ឬក៏ការសរសេរខគម្ពីរនោះចុះ ។ សូមរំឭកខគម្ពីរចងចាំទាំងនោះតាមរបៀបផ្សេងគ្នាពីមួយសប្ដាហ៍ទៅមួយសប្ដាហ៍ ។ សម្រាប់ថ្ងៃនេះ សូមចំណាយពេលជួយសមាជិកក្រុម ឲ្យទន្ទេញខគម្ពីរជាមួយគ្នា

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៩៩០៤៩១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ដោយប្រើប្រធានបទណាមួយអមជាមួយនឹងខគម្ពីរ បន្ទាប់មក បន្ថែមមួយឃ្លាម្តងៗ ។ សូមផ្តោតសំខាន់លើ ការទន្ទេញចាំគ្រប់ពាក្យ គ្រប់ម៉ាត់ មិនមែនការនិយាយសង្ខេបដោយខ្លួនឯងនោះឡើយ ។ សូមអានសាចុះសាឡើងឲ្យឮៗច្រើនដងរហូតទាល់តែសមាជិកម្នាក់ៗមានទំនុកចិត្តថា គេចាំខគម្ពីរនោះហើយ ។

**គន្លឹះនៃការពិភាក្សា៖ ជួយម្នាក់ៗឲ្យមានចំណែកក្នុងការចូលរួម**

ក្នុងនាមជាអ្នកសម្របសម្រួល លោកអ្នកត្រូវមានគោលបំណងក្នុងការនាំឲ្យគេគ្រប់គ្នាបានចូលរួមការពិភាក្សា ។ ប្រហែលជាមានសមាជិកក្រុមខ្លះ មានការលំបាកក្នុងការពិភាក្សានៅក្នុងក្រុម ។ ជូនកាលសួរសំណួរណាមួយដល់ពួកគេ ដោយមិនចាំបាច់ដាក់គំនាបលើពួកគេក្នុងការពិភាក្សានោះឡើយ ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to [www.cambodianchristianresources.com/dfd-leaders/](www.cambodianchristianresources.com/dfd-leaders/)*

សៀវភៅទី២
ជំពូកទី២
**ព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងជីវិតលោកអ្នក**

**គោលបំណងនៃជំពូកនេះគឺ៖** ដើម្បីឲ្យយើងបានស្គាល់ច្បាស់ពីសារៈសំខាន់នៃព្រះបន្ទូលដែលព្រះជាម្ចាស់មានបន្ទូលផ្ទាល់មកយើង ហើយបណ្តាលឲ្យយើងប្តេជ្ញាចិត្តអានព្រះបន្ទូលជារៀងរាល់ថ្ងៃ ។

នៅពេលដែលក្រុមលោកអ្នកកំពុងរង់ចាំសមាជិកផ្សេងៗទៀតនោះ លោកអ្នកក៏អាចនាំក្រុមខ្លួនឲ្យរំឭកខគម្ពីរចងចាំពីជំពូកមុន និងជំពូកនេះ មុនចាប់ផ្តើមពិភាក្សាលើមេរៀននីមួយៗ ។ លោកអ្នកអាចរំឭកខគម្ពីរចងចាំនៅពេលលោកអ្នកបញ្ចប់មេរៀនក៏បានដែរ ។ សូមពន្យល់ពួកគេឲ្យបានយល់ថា តើការចងចាំព្រះបន្ទូលមានសារៈសំខាន់យ៉ាងណាចំពោះខ្លួន ។ សូមចាប់ផ្តើមការរំឭកខគម្ពីរចងចាំដោយការសូត្រខគម្ពីរដោយខ្លួនឯងដល់ក្រុមជាដំបូងសិន ។

សូមកុំភ្លេចពិភាក្សាហើយបង្ហាញពីវិធីសាស្ត្រនៃរូបភាពដែលមាននៅលើទំព័រទី៤៨

សំណួរដ៏ល្អៗមួយចំនួនសម្រាប់ការពិភាក្សាមានដូចជាសំណួរទី៤, ៨, ១២, ១៣និង១៦

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

**ព្រះបន្ទូលព្រះគឺជាការសន្ទនារវាងព្រះជាម្ចាស់ជាមួយលោកអ្នក** (សំណួរទី១-៦)

លោកអ្នកអាចចាប់ផ្ដើមការពិភាក្សាដោយការសួរនូវសំណួរទូទៅដូចជា ៖ «តើមានអ្វីដែលបានប៉ះពាល់ចិត្តរបស់លោកអ្នកតាមរយៈព្រះបន្ទូលរបស់ទ្រង់ចំពោះយើងគ្រប់គ្នា ចេញពីសំណួរទាំងប្រាំមួយដំបូងដែលរៀបរាប់អំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់?»

**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី៤

តើលោកអ្នកដឹងថា ព្រះគម្ពីរគឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយរបៀបណា?

តើព្រះគម្ពីរបានលំហើយវិញ្ញាណរបស់លោកអ្នកដោយរបៀបណា?

តើព្រះគម្ពីរបានបង្ហាញពីលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ដោយរបៀបណា?

តើសេចក្ដីពិតរបស់ព្រះជាម្ចាស់គឺរឿងដែលប្រាកដជាក់ ឬជារឿងច្បោលៗដែលអាចបត់បែនបាន? ហេតុអ្វី? តើអ្វីទៅជាភាពខុសគ្នារវាងការនេះ?

**របៀបដែលព្រះគម្ពីរអាចជួយលោកអ្នក** (សំណួរទី៧-៨)

**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី៨

តើព្រះគម្ពីរមានលក្ខណៈដូចជានំបុ័ងយ៉ាងដូចម្ដេច?

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៩១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

(ម៉ាថាយ ៤:៤)

តើព្រះគម្ពីរមានលក្ខណៈដូចជាកញ្ចក់យ៉ាងដូចម្តេច? (យ៉ាកុប ១:២៣-២៥)

តើព្រះគម្ពីរមានលក្ខណៈដូចជាភ្លើងនិងញញួរយ៉ាងដូចម្តេច? (យេរេមា ២៣:២៩)

តើព្រះគម្ពីរបានជួយលោកអ្នកយ៉ាងដូចម្តេចខ្លះនាពេលថ្មីៗនេះ?

**ការក្លាយជាបុរស ឬស្រ្តីនៃព្រះបន្ទូល** (សំណួរទី៩-១៣)

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី១២ និង១៣

ហេតុអ្វីបានជាព្រះជាម្ចាស់ដាក់ទំនួលខុសត្រូវក្នុងការដែលយើងត្រូវតែចេះ ហើយយល់ច្បាស់ពីបទគម្ពីរ?

តើការអនុញ្ញាតិឲ្យព្រះបន្ទូលរបស់ព្រះគ្រីស្ទសណ្ឋិតនៅក្នុងយើងជាបរិបូរណ៍មានអត្ថន័យយ៉ាងដូចម្តេច?

**សារៈសំខាន់នៃការសញ្ជឹងគិត** (សំណួរទី១៤-១៦)

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី១៦

ដូចម្តេចដែលហៅថា ការសញ្ជឹងគិត?

តើយើងអាចសញ្ជឹងគិតលើបទគម្ពីរទាំងយប់ទាំងថ្ងៃបាន


*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ដោយរបៀបណា?

តើយើងអាចដឹងពីភាពមាំមួនរបស់បុគ្គលម្នាក់ផ្អែកលើទំនាក់ទំនងរបស់គាត់ជាមួយនឹងព្រះជាម្ចាស់តាមរយៈបទគម្ពីរបានដោយរបៀបណា?

តើលោកអ្នកគិតថា ចិត្តរបស់លោកអ្នកអាចឆ្លើយតបទៅនឹងព្រះបន្ទូលដ៏រស់របស់ព្រះជាម្ចាស់បានយ៉ាងដូចម្ដេច?

## ការបញ្ចប់កិច្ចពិភាក្សា

ក្នុងការបញ្ចប់ការពិភាក្សាសម្រាប់សប្ដាហ៍នេះ លោកអ្នកគួរតែស្នើសុំសមាជិកក្រុមឲ្យផ្ដល់មតិយោបល់ទៅលើរូបភាព ឬក៏សម្រង់សម្ដីដើម្បីចែកចាយការអនុវត្តផ្ទាល់ខ្លួន ឬក៏ចែកចាយចេញពីវគ្គនៃការ**ចូលឲ្យបានស៊ីជម្រៅ**។ សូមចំណាយពេលដើម្បីបង្ហាញពីរូបដៃ ពេលលោកអ្នកបង្ហាញសូមកុំគូររូបដៃនោះ ប៉ុន្តែសូមប្រើដៃនិងព្រះគម្ពីររបស់លោកអ្នក ដើម្បីពន្យល់ដល់ពួកគេ។ សូមពន្យល់ពីផលប្រយោជន៍ និងពីភាពផ្ទុយគ្នារវាងវិធីសាស្រ្តទាំងប្រាំក្នុងការសិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់។ សូមលើកទឹកចិត្តសមាជិកក្រុមឲ្យចែកចាយពីរូបភាពនោះទៅកាន់មិត្រភក្ដិរបស់ពួកគេក្នុងសប្ដាហ៍នេះ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

# ការអធិស្ឋាន

សូមបញ្ចប់ការសិក្សាដោយការអធិស្ឋាន ។ សូមចំណាយពេលអធិស្ឋានឲ្យបានច្រើនជាងការចែកចាយសំណូមពរអធិស្ឋាន ដ្បិតព្រះជាម្ចាស់ជ្រាបពីទិដ្ឋភាពនៃសំណូមពរអធិស្ឋានរបស់លោកអ្នករួចហើយ ។ ដូចគ្នាផងដែរ សូមលើកទឹកចិត្តសមាជិកក្រុមឲ្យចែកចាយពីរបៀបដែលព្រះជាម្ចាស់បានឆ្លើយតបទៅនឹងសំណូមពរអធិស្ឋានរបស់ពួកគេកាលពីសប្តាហ៍មុនៗ រួមទាំងការសរសើរតម្កើងដល់ព្រះជាម្ចាស់ក្នុងការអធិស្ឋានរបស់លោកអ្នកផងដែរ ។

## ការរំឭកខគម្ពីរចងចាំ

ប្រសិនបើសមាជិកក្រុមរបស់លោកអ្នកបានយល់ព្រមទន្ទេញហើយនិងរំឭកខគម្ពីរជាមួយគ្នា ដូច្នេះសូមញែកពេលដើម្បីរំឭកខគម្ពីរនោះ ។ សូមរំឭកខគម្ពីរក្នុងជំពូកនេះ និងខគម្ពីរក្នុងជំពូកមុនផងដែរ ។

**គន្លឹះនៃការពិភាក្សា៖ ជួយអ្នកដែលពូកែមានយោបល់ឲ្យចេះស្តាប់**

ការពិភាក្សា គឺជាការសន្ទនារវាងមនុស្សនិងមនុស្ស ។ ប្រសិនបើមានសមាជិកក្នុងក្រុមរបស់លោកអ្នកមិនបានយកចិត្តទុកដាក់ក្នុងការស្តាប់ នោះលោកអ្នកគួរតែនិយាយជាមួយពួកគេមុន ឬ

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ក្រោយការពិភាក្សា ដើម្បីឲ្យពួកគេយកចិត្តទុកដាក់ស្តាប់ មិនមែនគ្រាន់តែឲ្យពួកគេឆាប់នឹងឆ្លើយតែប៉ុណ្ណោះនោះទេ ។ សូមប្រាប់ពួកគេថា លោកអ្នកបានសម្គាល់ឃើញមនុស្សមួយចំនួនមិនសូវនិយាយស្តីសោះ ។ ប្រាប់ពួកគេឲ្យជួយបង្កើតបរិយាកាសល្អដោយឲ្យពួកគេស្តាប់ច្រើនជាងនិយាយ ដើម្បីឲ្យក្រុមទាំងមូលមានការសន្ទនាគ្នាបានល្អ ។ សូមសួរពួកគេថា តើពួកគេមានភាពងាយស្រួលក្នុងការស្តាប់ដែរឬទេ ព្រោះមានមនុស្សមួយចំនួនងាយស្រួលក្នុងការចាប់យកព័ត៌មាន ស្របពេលដែលពួកគេនិយាយផងដែរ ។ សូមជួយពួកគេឲ្យមើលឃើញថា ពួកគេត្រូវតែអនុញ្ញាតិឲ្យអ្នកផ្សេងទៀតនិយាយផងដែរ ដូចដែលពួកគេត្រូវយកចិត្តទុកដាក់ស្តាប់យ៉ាងដូច្នោះដែរ ។

*Pre-release គបស ស្បៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to [www.cambodianchristianresources.com/dfd-leaders/](www.cambodianchristianresources.com/dfd-leaders/)*

សៀវភៅទី២
ជំពូកទី៣

## ការសន្ទនាជាមួយព្រះជាម្ចាស់

**គោលបំណងនៃជំពូកនេះគឺ៖** ដើម្បីឲ្យមើលឃើញថា ការអធិស្ឋានគឺជារបៀបមួយដែលព្រះជាម្ចាស់បានប្រទានមកយើង ដើម្បីឲ្យយើងមានទំនាក់ទំនងជាមួយនឹងទ្រង់ និងដើម្បីសម្រេចចិត្តចំណាយពេលអធិស្ឋានជារៀងរាល់ថ្ងៃ ។

នៅចុងបញ្ចប់ការពិភាក្សា សូមលើកទឹកចិត្តសមាជិកក្រុមឲ្យចាប់ផ្ដើមធ្វើតារាងសំណូមពរអធិស្ឋាន ។

ការជំរុញចិត្ត គឺជាគន្លឹះនៃការរៀនសូត្រ ។ សូមជួយសមាជិកក្រុមរបស់លោកអ្នកឲ្យមើលឃើញពីហេតុដែលត្រូវរៀនពីសារៈសំខាន់នៃភាពជាសិស្សរបស់ព្រះយេស៊ូវដែលដកស្រង់ចេញពីព្រះគម្ពីរ ។

សំណួរដ៏ល្អៗមួយចំនួនសម្រាប់ការពិភាក្សាមានដូចជា សំណួរទី១, ៣, ៦, ៧, ១១, ១៣, ១៦, ១៨និង១៩ ។

**ការអធិស្ឋានគឺជាការស្ដាប់និងការនិយាយជាមួយព្រះជាម្ចាស់**
(សំណួរទី១-៦)
លោកអ្នកអាចចាប់ផ្ដើមការពិភាក្សាដោយការសួរនូវសំណួរទូទៅ

*Pre-release គបស ស្យៅវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ដូចជា ៖ «តើមានអ្វីដែលបានប៉ះពាល់ចិត្តរបស់លោកអ្នក ជាងគេបំផុត ស្ដីពីការស្ដាប់ និងការនិយាយជាមួយព្រះជាម្ចាស់ នៅក្នុងវគ្គដំបូងនៃការអធិស្ឋាននេះ?»

**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី១, ៣និង៦

តើយើងគួរធ្វើយ៉ាងម៉េច ដើម្បីអភិវឌ្ឍទំនាក់ទំនងរបស់យើង ជាមួយព្រះជាម្ចាស់?

តើកណ្ឌគម្ពីរ ១ថែស្សាឡូនីច ៥:១៧ដែលចែងថា «ចូរ អធិស្ឋានឥតឈប់ឈរ» មានន័យយ៉ាងដូចម្ដេច?

តើនៅពេលដែលលោកអ្នកចូលទៅកាន់ព្រះវត្តមានរបស់ ព្រះជាម្ចាស់ដោយការអធិស្ឋាន លោកអ្នកគួរមានអកប្បកិរិយា និង អារម្មណ៍យ៉ាងដូចម្ដេច?

**សារប្រយោជន៍នៃការអធិស្ឋាន** (សំណួរទី៧-១១)

**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី៧និង១១

ប្រសិនបើលោកអ្នកអាចចំណាយពេលមួយម៉ោងជាមួយ ព្រះជាម្ចាស់ ហើយនិយាយអ្វីក៏បាន តើលោកអ្នកនឹងនិយាយអ្វីខ្លះ? តើលោកអ្នកនឹងស្នើសុំអ្វីខ្លះពីទ្រង់?

តើនឹងមានអ្វីជាលទ្ធផលនៅក្នុងជីវិតរបស់យើង នៅពេលដែលយើងជួបជាមួយព្រះជាម្ចាស់ដោយការអធិស្ឋាន?

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to [www.cambodianchristianresources.com/dfd-leaders/](www.cambodianchristianresources.com/dfd-leaders/)*

**លក្ខខណ្ឌនៃការអធិស្ឋាន** (សំណួរទី១២-១៤)

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី១៣

ហេតុអ្វីបានជាជំនឿ (ឬក៏ការទុកចិត្ត) មានសារៈសំខាន់នៅពេលដែលលោកអ្នកអធិស្ឋាន (ម៉ាថាយ ២១:២២)?

តើការទូលសូមក្នុងព្រះនាមព្រះយេស៊ូវមានអត្ថន័យយ៉ាងដូចម្ដេច (យ៉ូហាន ១៦:២៤)?

តើលោកអ្នកគួរអធិស្ឋានដែរឬទេ ប្រសិនបើចិត្តរបស់លោកអ្នកមិនចង់អធិស្ឋានក៏ដោយ? ហេតុអ្វីគួរអធិស្ឋាន ហេតុអ្វីមិនគួរអធិស្ឋាន?

**តើលោកអ្នកអធិស្ឋានឲ្យនរណា?** (សំណួរទី១៥-២១)

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី១៦, ១៨និង១៩

តើលោកអ្នកបានរៀនអ្វីខ្លះចេញពីការអធិស្ឋានរបស់សាវ័កប៉ុលនៅក្នុងកណ្ឌគម្ពីរ អេភេសូរ ៣:១៤-២១?

តើក្នុងឆាកជីវិតរបស់លោកអ្នក ធ្លាប់ដែលមានអ្នកណាធ្វើបាបលោកអ្នកដែរឬទេ? ឥឡូវនេះ សូមចំណាយពេលអធិស្ឋានទៅកាន់ព្រះជាម្ចាស់អំពីមនុស្សទាំងនោះ និងការឆ្លើយតបរបស់លោកអ្នកចំពោះពួកគេវិញ ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

តើលោកអ្នកដែលឃើញថា ការប្រើប្រាស់តារាងនៃការអធិស្ឋានមានសារប្រយោជន៍ដែរឬទេ? បើមានមែន តើដោយរបៀបណា?

ក្នុងនាមជាអ្នកដឹកនាំ លោកអ្នកត្រូវតែផ្ទាកបន្តិច ដើម្បីពន្យល់ពីរបៀបដែលលោកអ្នកបានប្រើប្រាស់តារាងនៃការអធិស្ឋាន បន្ទាប់មកសូមបង្ហាញសំណូមពរអធិស្ឋាននៅក្នុងតារាងនៃការអធិស្ឋានរបស់លោកអ្នកដល់សមាជិកក្រុម ។ សូមចែកក្រដាសដល់ពួកគេម្នាក់មួយសន្លឹកៗ ដើម្បីសរសេរពីសំណូមពរអធិស្ឋានដែលក្រុមបានចែកចាយ ។

**ការបញ្ចប់កិច្ចពិភាក្សា**

សូមជ្រើសរើសវិធីសាស្ត្រមួយឬពីរ ដើម្បីបញ្ចប់ការពិភាក្សារបស់លោកអ្នកដូចខាងក្រោមនេះ៖ ការចូលឲ្យបានស៊ីជម្រៅ ការអនុវត្ត រូបភាព និងសម្រង់សម្ដី ឬក៏សួរជាសំណួរសង្ខេបដូចតទៅ «តើលោកអ្នកមានបានជួបជាមួយព្រះជាម្ចាស់រាល់ថ្ងៃ ដើម្បីចំណាយពេលអធិស្ឋាន ហើយអានព្រះគម្ពីរ ព្រមទាំងសញ្ជឹងគិតតែម្នាក់ឯងឲ្យបានទៀងទាត់ដែរឬទេ? សូមប្រាប់យើងពីពេលវេលានោះ» ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

## ការអធិស្ឋាន

ស្នើសុំឲ្យសមាជិកចែកចាយពីចំណុច **ផ្នែកបន្ថែមដើម្បីអធិស្ឋាន**ត្រង់ទំព័រទី៧១ ។ បន្ទាប់មកយកតារាងនៃការអធិស្ឋានដើម្បីសរសេរពីសំណូមពរអធិស្ឋានរបស់ពួកគេម្នាក់ៗមុនពេលអធិស្ឋានជាមួយគ្នា ។

**ការរំឭកខគម្ពីរចងចាំ**

ប្រសិនបើសមាជិកក្រុមរបស់លោកអ្នកបានយល់ព្រមទន្ទេញហើយនិងរំឭកខគម្ពីរជាមួយគ្នា ដូច្នេះសូមញែកពេលដើម្បីរំឭកខគម្ពីរនោះ ។ សូមរំឭកខគម្ពីរក្នុងជំពូកនេះ និងខគម្ពីរក្នុងជំពូកមុនផងដែរ ។ ស្នើសុំសមាជិកម្នាក់ឲ្យចែកចាយពីរបៀបដែលខគម្ពីរចងចាំបានជួយដល់គាត់ក្នុងសប្ដាហ៍នេះ ។

**គន្លឹះនៃការពិភាក្សា៖ បញ្ចប់ឲ្យទៀងពេលវេលា**

បញ្ហានៃការពិភាក្សាជាក្រុមគឺ អ្នកដឹកនាំក្រុមមិនបានរក្សាម៉ោងពេលឲ្យបានទៀងទាត់ ។ ត្រូវធ្វើមួយៗកុំបំបោល ហើយបញ្ចប់ការសិក្សាដោយទៀងពេល ទោះបីជាសមាជិកក្រុមមកមិនទៀងម៉ោងក៏ដោយ ។ ប្រសិនបើការពិភាក្សាដំណើរការបានល្អនោះលោកអ្នកអាចនិយាយថា «ដល់ម៉ោងហើយ តោះយើងសម្រាកត្រឹមនេះ ។ ប្រសិនបើមាននរណាម្នាក់ចង់បន្តការពិភាក្សា នោះ

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

យើងនឹងបន្តនៅពេលដែលអ្នកផ្សេងទៀតត្រូវការចេញទៅផ្ទះមានពេលបន្តជាមួយគ្នា» ។ ប្រសិនបើលោកអ្នករក្សាពេលវេលារបស់លោកអ្នក នោះលោកអ្នកនឹងទទួលការកោតសរសើរពីសមាជិកក្រុមពីព្រោះលោកអ្នកបានគោរពពេលវេលារបស់ពួកគេ ។

*Pre-release គបស ស្បៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to [www.cambodianchristianresources.com/dfd-leaders/](www.cambodianchristianresources.com/dfd-leaders/)*

**សៀវភៅទី២**
**ជំពូកទី៤**
**ការប្រកបគ្នាជាមួយអ្នកដើរតាមព្រះយេស៊ូវ**

**គោលបំណងនៃជំពូកនេះគឺ ៖** ដើម្បីឲ្យមើលឃើញថា ការប្រកបគ្នាជាមួយអ្នកដើរតាមព្រះយេស៊ូវ គឺជាបញ្ញត្តដែលចេញមកពីព្រះគម្ពីរ ពីព្រោះយើងត្រូវការគ្នាទៅវិញទៅមក ។

ក្នុងការរៀបចំការពិភាក្សា ជាការល្អណាស់ប្រសិនបើយើងបង្កើតសំណួរទុកជាចំណុចចម្បងនៃការពិភាក្សាជាមុន បន្ទាប់រៀបចំពីរបៀបដែលលោកអ្នកនឹងចាប់ផ្ដើម ហើយបញ្ចប់ការពិភាក្សាវិញ ។

សំណួរដ៏ល្អៗមួយចំនួនសម្រាប់ការពិភាក្សាមានដូចជា សំណួរទី១, ៨, ១២, ១៤, ១៥, ១៧និង១៩ ។

**តើអ្វីទៅជាការប្រកបដែលយោងទៅតាមព្រះគម្ពីរ?**(សំណួរទី១-៦)
លោកអ្នកអាចចាប់ផ្ដើមការពិភាក្សាដោយការសួរនូវសំណួរទូទៅដូចជា ៖ «តើលោកអ្នកទទួលបានអ្វីខ្លះស្ដីពីការប្រកបដែលយោងទៅតាមព្រះគម្ពីរចេញពីវគ្គដំបូងនេះ?»
**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី១

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

តើការប្រកបគ្នាកើតឡើងនៅពេលណា?

តើចំណុចដែលសំខាន់ជាងគេបំផុតដែលយើងអាចចែកចាយជាមួយអ្នកដទៃគឺជាអ្វី?

តើលោកអ្នកពេញចិត្តនឹងការប្រកបគ្នាជាមួយអ្នកផ្សេងទៀតដែរឬទេ?

**គោលបំណងនៃការប្រកបគ្នា ៖** (សំណួរទី៧-១០)

**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី៨

តើយើងអាចជំរុញចិត្តគ្នាទៅវិញទៅមកឲ្យស្រឡាញ់ ហើយនិងប្រព្រឹត្តល្អនឹងគ្នាទៅវិញទៅមកបានដោយរបៀបណា?

សូមពន្យល់ពីហេតុផលដែលថា ការប្រកបគ្នាមានសារៈសំខាន់ចំពោះលោកអ្នក ។ តើលោកអ្នកទទួលបានសារប្រយោជន៍អ្វីខ្លះចេញពីការដំណាលរបស់យើង និងអ្នកដើរតាមព្រះយេស៊ូវផ្សេងៗទៀត?

**រូបកាយរបស់ព្រះគ្រីស្ទ** (សំណួរទី១២-១៥)

**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី១២, ១៤និង១៥

តើព្រះគ្រីស្ទអាចជាបុគ្គលទីមួយនៅក្នុងជីវិតរបស់យើង នៅពេលដែលយើងប្រកបគ្នាបានដោយរបៀបណា?

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ហេតុអ្វីបានជាសមាជិកក្រុមគ្រប់ៗរូបមានសារៈសំខាន់នៅក្នុងរូបកាយរបស់ព្រះគ្រីស្ទ?

តើលោកអ្នកពេញចិត្តនឹងផ្នែកដែលលោកអ្នកបានរួមចំណែកនៅក្នុងរូបកាយព្រះគ្រីស្ទដែរឬទេ? សូមពន្យល់ ៖

តើលោកអ្នកធ្លាប់តយុទ្ធជាមួយនឹងអារម្មណ៍ដែលថា លោកអ្នកពូកែជាង ឬក៏មិនពូកែជាងអ្នកផ្សេងទៀតនៅក្នុងរូបកាយរបស់ព្រះគ្រីស្ទដែលមានមុខងារខុសប្លែកពីលោកអ្នកដែរឬទេ? ប្រសិនបើធ្លាប់ តើលោកអ្នកដោះស្រាយអារម្មណ៍នោះដោយរបៀបណា?

**ក្រុមជំនុំតាមតំបន់** (សំណួរទី១៦-២០)

**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី១៧និង១៩

តើឥឡូវនេះ លោកអ្នកកំពុងតែ «ធ្វើការជំនួយ» បែបណាខ្លះដែលព្រះជាម្ចាស់ប្រើប្រាស់ ដើម្បីស្អាងអ្នកផ្សេងទៀតនៅក្នុងរូបកាយរបស់ព្រះគ្រីស្ទ?

តើព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យលោកអ្នកអធិស្ឋាន ហើយផ្តល់ជាថវិកាដល់អ្នកដឹកនាំខាងឯវិញ្ញាណយ៉ាងដូចម្តេច?

*Pre-release គបស ស្បៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៩១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

## ការបញ្ចប់កិច្ចពិភាក្សា

សូមជ្រើសរើសវិធីសាស្ត្រមួយឬពីរ ដើម្បីបញ្ចប់ការពិភាក្សារបស់លោកអ្នកដូចខាងក្រោមនេះ ៖ ការចូលឲ្យបានស៊ីជម្រៅ ការអនុវត្ត រូបភាព និងសម្រង់សម្ដី ឬការសង្ខេប ។

## ការអធិស្ឋាន

នេះគឺជាពេលវេលាល្អមួយ ដើម្បីចែកចាយការឆ្លើយតបទៅនឹងសំណូមពរអធិស្ឋាន និងបញ្ហាផ្សេងៗដែលសមាជិកក្រុមបានចែកចាយពីមុន ។ សូមសរសើរតម្កើងព្រះជាម្ចាស់ពីភាពស្មោះត្រង់របស់ទ្រង់ ។ ចូរបន្តអធិស្ឋានពីសេចក្ដីត្រូវការផ្សេងៗ ។ ចូរលើកទឹកចិត្តសមាជិកក្រុមឲ្យសរសេរពីសំណូមពរអធិស្ឋាននៅក្នុងតារាងអធិស្ឋានរបស់ពួកគេ ។

ដូចគ្នាផងដែរ សូមមើលត្រួសៗនៅជំពូកបន្ទាប់ ។ បន្ទាប់មកពន្យល់សមាជិកក្រុមថា ជំពូកនេះទាមទារពេលវេលាច្រើនជាងជំពូកផ្សេងៗក្នុងការរៀបចំ ពីព្រោះជំពូកនេះតម្រូវឲ្យពួកគេសរសេររឿងនៃការទុកចិត្តលើព្រះគ្រីស្ទ ។ សាតាំងនឹងទាស់ទទឹងនឹងការសរសេររឿង ដូច្នេះចូរអធិស្ឋានឲ្យគ្នាទៅវិញទៅមក ដើម្បីសញ្ជឹងគិត ហើយសរសេររឿងនៃការទុកចិត្តលើព្រះគ្រីស្ទសារជាថ្មី ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

## ការរំឭកខគម្ពីរចងចាំ

ប្រសិនបើសមាជិកក្រុមរបស់លោកអ្នកបានយល់ព្រមទន្ទេញ ហើយនិងរំឭកខគម្ពីរជាមួយគ្នា ដូច្នេះសូមញែកពេលដើម្បីរំឭកខគម្ពីរនោះ ។ សូមរំឭកខគម្ពីរក្នុងជំពូកនេះជាមួយគ្នាឲ្យបានពីរបីដង ។ ដោយសារតែសៀវភៅទី២នេះនៅសល់តែមួយជំពូកទៀត ដូច្នេះចូរចំណាយពេលបន្ថែមទៀត ដើម្បីរំឭកខគម្ពីរចងចាំ ។ ជាការល្អប្រសិនបើលោកអ្នកចែកក្រដាសដល់សមាជិកក្រុម ហើយឲ្យពួកគេសរសេរខគម្ពីរចងចាំទាំងបួនចេញពីជំពូកទី១-៤ ។ បន្ទាប់មកឲ្យពួកគេដូរក្រដាសគ្នាទៅវិញទៅមក ដើម្បីពិនិត្យមើលភាពត្រឹមត្រូវ ។

## គន្លឹះនៃការពិភាក្សា ៖ ចាប់ផ្ដើមឲ្យទៀងពេលវេលា

ជួនកាលមានមនុស្សមួយចំនួនមិនបានមកទៀងពេលនោះទេ ។ ជម្រើសដែលលោកអ្នកអាចដោះស្រាយបាននោះគឺ ត្រូវពិភាក្សាពីពេលវេលានៃការចាប់ផ្ដើម ។ ជម្រើសមួយផ្សេងទៀតគឺត្រូវចាប់ផ្ដើមឲ្យទៀងពេល ទោះបីជាមិនទាន់មានមនុស្សមកជុំគ្នាទាំងអស់ក៏ដោយ ។ ពេលដែលលោកអ្នកចាប់ផ្ដើមទៀងពេល នោះសមាជិកក្រុមនឹងព្យាយាមមកឲ្យទាន់ពេលដែរ ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

## សៀវភៅទី២
## ជំពូកទី៥
## ការធ្វើបន្ទាល់

**គោលបំណងនៃជំពូកនេះគឺ៖** ដើម្បីរកឲ្យឃើញពីសារៈសំខាន់នៃការចែកចាយដល់អ្នកផ្សេងៗនូវអ្វីៗដែលព្រះយេស៊ូវគ្រីស្ទបានធ្វើសម្រាប់យើង និងដើម្បីឲ្យយើងកាន់តែមានជំនាញក្នុងការចែកចាយពីរឿងនេះ ។

សូមចាប់ផ្ដើមការពិភាក្សាដោយអានសេចក្ដីផ្ដើមនៃជំពូកនេះ ។ បន្ទាប់មកពិភាក្សាត្រួសៗអំពីលក្ខណៈដូចគ្នារវាងការធ្វើបន្ទាល់ពីព្រះយេស៊ូវ និងការធ្វើជាមេអណ្ដើក ។

លោកអ្នកក៏ត្រូវញែកពេលវេលាទុកឲ្យបានច្រើនសម្រាប់វគ្គនេះ ដើម្បីឲ្យសមាជិកក្រុមអានទីបន្ទាល់របស់ពួកគេឲ្យបានឮៗ ។ ចូរស្វែងរកចំណុចណាមួយក្នុងទីបន្ទាល់របស់ពួកគេដើម្បីគាំទ្រ និងដើម្បីជួយពួកគេឲ្យអាចធ្វើបានល្អជាងមុន ។ សូមចងចាំថាទីបន្ទាល់ទាំងនេះមានសារៈសំខាន់ណាស់ ហើយក៏ជារឿងរបស់បុគ្គលផ្ទាល់ ។ ដូចគ្នាផងដែរ សូមចងចាំថា ការពិភាក្សានេះមានរួមជាមួយអារម្មណ៍ផ្ទាល់ខ្លួន ក៏ដូចជាអ្វីដែលគេជឿស្រាប់ពីទីបន្ទាល់របស់គេ ដូច្នេះចូរកុំធ្វើខុសដោយមិនយោគយល់ពីអារម្មណ៍ផ្ទាល់ខ្លួន


*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

របស់ពួកគេនោះឡើយ ។

សំណួរដ៏ល្អៗមួយចំនួនសម្រាប់ការពិភាក្សាមានដូចជា សំណួរទី២, ៧, ៨, ១១, ១២, ១៦, ១៧និង១៩ ។

**ឱកាស** (សំណួរទី១-៧)

លោកអ្នកអាចចាប់ផ្ដើមការពិភាក្សាដោយសួរសំណួរទូទៅដូចជា ៖ «នៅពេលដែលលោកអ្នកពិចារណាលើវគ្គដំបូងនេះ តើមានអ្វីខ្លះដែលបានប៉ះពាល់ចិត្តរបស់លោកអ្នកស្ដីពីឱកាសរបស់យើងដើម្បីចែកចាយពីព្រះគ្រីស្ទដល់អ្នកផ្សេងទៀត?

**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី២និង៧

ហេតុអ្វីបានជាសាវ័ក ពេត្រុសមានចិត្តឆេះឆួលក្នុងការចែកចាយពីព្រះយេស៊ូវ?

តើការស្វែងរកការគាំទ្រពីព្រះជាម្ចាស់អាចជួយជំរុញចិត្តយើងឲ្យធ្វើបន្ទាល់បានដោយរបៀបណា?

អាកប្បកិរិយារបស់យើងអាចជាជំនួយដ៏ខ្លាំងក្នុងការធ្វើបន្ទាល់ ។ តើលោកអ្នកឃើញមានអាកប្បកិរិយាដែលលោកអ្នកមិន

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to [www.cambodianchristianresources.com/dfd-leaders/](www.cambodianchristianresources.com/dfd-leaders/)*

គួរមានបែបណាខ្លះ? ហើយតើលោកអ្នកឃើញមានអាកប្បកិរិយារបស់អ្នកជឿដែលចែកចាយពីជំនឿរបស់ពួកគេដែលលោកអ្នកគួរមានបែបណាខ្លះ?

**តើលោកអ្នកអាចធ្វើបន្ទាល់ឲ្យមានប្រសិទ្ធភាពបានយ៉ាងដូចម្ដេច?**
(សំណួរទី៨-១៦)

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី៨, ១១, ១២និង១៦

ហេតុអ្វីបានជាសេចក្ដីស្រឡាញ់មានសារៈសំខាន់ក្នុងការធ្វើបន្ទាល់?

តើលក្ខណសម្បត្តិបែបណាដែលធ្វើឲ្យបុគ្គលម្នាក់មានឥទ្ធិពលក្នុងការធ្វើបន្ទាល់?

តើលោកអ្នកគួរដឹងអ្វីខ្លះ ដើម្បីចែកចាយពីជំនឿរបស់លោកអ្នកក្នុងព្រះគ្រីស្ទដល់នរណាម្នាក់?

តើមានអ្វីដែលអាចរារាំងលោកអ្នកមិនឲ្យចែកចាយពីជំនឿរបស់លោកអ្នកក្នុងព្រះយេស៊ូវដល់អ្នកផ្សេងទៀតបាន?

**រឿងរ៉ាវរបស់សាវ័កប៉ុល** (សំណួរទី១៧-១៨)

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី១៧

តើសាវ័ក ប៉ុលជាមនុស្សបែបណា មុនដែលគាត់បានជួប

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ព្រះគ្រីស្ទ?

តើព្រះយេស៊ូវបានបំផ្លាស់បម្រែជីវិតរបស់សាវ័ក ប៉ុលដោយរបៀបណា?

តើលោកអ្នកអាចរៀនបានអ្វីខ្លះចេញពីរឿងរ៉ាវរបស់សាវ័កប៉ុលដែលមានសារប្រយោជន៍ចំពោះលោកអ្នក?

**រឿងរ៉ាវរបស់លោកអ្នក** (សំណួរទី១៩)

**សំណើសម្រាប់ការពិភាក្សាបន្ទាប់ពីចែកចាយរឿងរ៉ាវរបស់យើង ៖**

សំណួរទី១៩

ហេតុអ្វីបានជាការសរសេររឿងរ៉ាវរបស់លោកអ្នកស្តីពីរបៀបដែលលោកអ្នកក្លាយជាអ្នកដើរតាមព្រះយេស៊ូវមានសារៈសំខាន់?

ក្នុងនាមជាអ្នកដឹកនាំ ត្រូវប្រាកដថា លោកអ្នកបានញែកពេលវេលាទុកបានច្រើន ដើម្បីឲ្យសមាជិកក្រុមអានពីរឿងរ៉ាវនៃរបៀបដែលពួកគេទុកចិត្តព្រះគ្រីស្ទ ។ បន្ទាប់មក ឆ្លើយតបពីការចែកចាយរបស់ពួកគេដោយប្រើពាក្យលើកទឹកចិត្តពីអ្វីដែលរឿងរ៉ាវរបស់ពួកគេបានប៉ះពាល់ចិត្តលោកអ្នក ឬក៏ពីរបៀបដែលលោកអ្នកគិតថា រឿងរ៉ាវនេះអាចប៉ះពាល់ចិត្តអ្នកដែលកំពុងតែត្រិះរិះពិចារណាទៅលើការដែលគេគួរទុកចិត្តព្រះគ្រីស្ទឬក៏អត់ ។ សូមកុំរកតែកំហុស ផ្ទុយទៅវិញចូរគាំទ្រពួកគេវិញ ។ ប្រសិនបើ

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

មិនមានពេលវេលាគ្រប់គ្រាន់ដើម្បីឲ្យបុគ្គលម្នាក់ៗចែកចាយនោះទេ នោះសូមរៀបចំពេលវេលាទុកសម្រាប់អស់អ្នកដែលមិនទាន់បានអាន រឿងរ៉ាវរបស់ខ្លួន ពេលជួបគ្នានៅសប្ដាហ៍ក្រោយ ។

## ការបញ្ចប់កិច្ចពិភាក្សា

សូមជ្រើសរើសវិធីសាស្ត្រមួយឬពីរ ដើម្បីបញ្ចប់ការពិភាក្សារបស់លោកអ្នកដូចខាងក្រោមនេះ ៖ ការចូលឲ្យបានស៊ីជម្រៅ ការអនុវត្ត រូបភាព និងសម្រង់សម្ដី ឬការសង្ខេប ។

## ការអធិស្ឋាន

សូមចំណាយពេលអធិស្ឋានសម្រាប់គ្នាទៅវិញទៅមក ហើយសរសើរតម្កើងព្រះជាម្ចាស់ពីអ្វីៗដែលព្រះជាម្ចាស់បានធ្វើនៅក្នុងជីវិតរបស់លោកអ្នក ។

## ការរំឭកខគម្ពីរចងចាំ

សូមបញ្ចប់ការពិភាក្សាជំពូកនេះដោយសូត្រខគម្ពីរចងចាំរួមគ្នា ក៏ដូចជាសូត្រម្ដងម្នាក់ជាមួយដៃគូ ដើម្បីពិនិត្យមើលពីភាពត្រឹមត្រូវ ។ ចូរលើកទឹកចិត្តសមាជិកក្រុមឲ្យរំឭកខគម្ពីរចងចាំទាំងប្រាំនេះជារៀងរាល់ថ្ងៃ ក៏ដូចជារំឭកខគម្ពីរចងចាំផ្សេងៗទៀត

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to [www.cambodianchristianresources.com/dfd-leaders/](www.cambodianchristianresources.com/dfd-leaders/)*

ចេញពីសៀវភៅទី១ផងដែរ ។

## ការរំឭកឡើងវិញ

នេះគឺជាជំពូកចុងក្រោយនៃសៀវភៅទី២ ។ ដូច្នេះ ប្រហែលជាដល់ពេលដែលលោកអ្នកគួររំឭកនូវអ្វីៗដែលបានជួយលោកអ្នកច្រើនជាងគេបំផុតនៅក្នុងដំណើរខាងឯវិញ្ញាណរបស់លោកអ្នកដែលបានដកស្រង់ចេញពីការសិក្សាក្នុងសៀវភៅទី២ ។ ចូរពិភាក្សាពីគម្រោងដែលលោកអ្នកនឹងឈ្មុលទៅមុខ ដើម្បីបន្តទៅសិក្សាសៀវភៅទី៣ ។ បន្ទាប់មកស្នើសុំឲ្យសមាជិកក្រុមថា តើយើងគួរផ្លាស់ប្តូរវិធីសាស្ត្រណាខ្លះ ដើម្បីជួយឲ្យការសិក្សារបស់យើងកាន់តែចម្រើនឡើងជាមួយគ្នា ។ សូមចែកសៀវភៅទី៣ដល់អស់អ្នកដែលនឹងបន្តការសិក្សា ។

**គន្លឹះនៃការពិភាក្សា ៖ ពេលខ្លះត្រូវបង្វែរមេរៀនតាមអ្នកស្តាប់**

ជួនកាលមានមនុស្សមួយចំនួនចង់ពិភាក្សាពីគំនិតណាមួយដែលមិនស៊ីគ្នាទៅនឹងប្រធានបទរបស់ជំពូក ។ នោះមិនជាបញ្ហាអ្វីទេ ។ ការនេះចំពោះលោកអ្នកប្រហែលជានៅក្រៅប្រធានបទ ប៉ុន្តែប្រហែលជាសំខាន់ចំពោះពួកគេ ។ ការដែលលោកអ្នកមានបំណងចិត្តពិភាក្សាពីសំណួរ និងគំនិតរបស់ពួកគេនឹងធ្វើឲ្យពួកគេកាន់តែ

Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០
Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/

ដាក់ទុកចិត្តមកលើលោកអ្នក ។ ពេលនោះលោកអ្នកអាចទាញពួកគេឲ្យចូលមកក្នុងការពិភាក្សាលើប្រធានបទស្នូលនៃមេរៀនវិញ ។

## របៀបនៃការអធិស្ឋានសម្រាប់ក្រុមរបស់លោកអ្នក

ការរៀបចំវគ្គសិក្សានីមួយៗដោយអធិស្ឋាន នោះគឺជាការដ៏សំខាន់បំផុតចំពោះលោកអ្នក ។ លោកអ្នកប្រហែលជាមានសំណូមពរផ្ទាល់ខ្លួន ប៉ុន្តែខាងក្រោមនេះគឺជាសំណូមពរអធិស្ឋានសម្រាប់អាទិត្យនីមួយៗ ៖

ចូរអធិស្ឋានសម្រាប់សមាជិកក្រុមទាំងអស់ឲ្យបំពេញការរៀបចំជំពូកនេះ ហើយចូលរួមការពិភាក្សានៅសប្ដាហ៍នេះ ។ ទូលសូមព្រះជាម្ចាស់ឲ្យជួយពួកគេ ដើម្បីឲ្យចែកចាយពីគំនិតរបស់ពួកគេដោយស្មោះត្រង់ និងដើម្បីឲ្យពួកគេចូលរួមឲ្យបានច្រើនលើការពិភាក្សា ។

ចូរទូលសូមព្រះជាម្ចាស់ឲ្យប្រទានពួកគេយល់ពីអ្វីដែលពួកគេសិក្សា ។ ទូលសូមព្រះជាម្ចាស់ឲ្យប្រទាននូវអ្វីៗដែលសមាជិកក្រុមត្រូវការតាមរយៈការសិក្សាព្រះបន្ទូលរបស់ទ្រង់ ។ ចូរអធិស្ឋានសម្រាប់សំណូមពរដ៏ជាក់លាក់ដែលសមាជិកក្រុមបានចែកចាយ ។

ក្នុងនាមជាអ្នកដឹកនាំ ចូរអធិស្ឋានថា លោកអ្នកនឹងដឹងពី

*Pre-release គបស ស្បៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធក្នុងការអនុវត្តលើ ការអត់ធ្មត់ ការទទួលយក ការយល់ដឹងពីគ្នាទៅវិញទៅមក និងប្រាជ្ញា ។ ចូរអធិស្ឋានសូមឲ្យព្រះជាម្ចាស់ប្រទាននូវបរិយាកាសដែលមានសេចក្តីស្រឡាញ់ពិតប្រាកដនៅក្នុងក្រុមរបស់លោកអ្នកចំពោះគ្នាទៅវិញទៅមករួមមាន ការបើកចិត្តដើម្បីរៀនសូត្រ និងការផ្លាស់ប្រែដោយស្មោះត្រង់ ។ ចូរធ្វើគ្រប់អ្វីៗដែលលោកអ្នកអាចធ្វើបាន ដើម្បីស្តារបរិយាកាសដែលពេញដោយសេចក្តីមេត្តាករុណា និងមិនមានការថ្កោលទោស ។

ចូរអធិស្ឋានសូមព្រះជាម្ចាស់ប្រទានឲ្យសមាជិកក្រុមកាន់តែស្រឡាញ់ព្រះយេស៊ូវថែមទៀត ទុកជាលទ្ធផលនៃការសិក្សា និងការពិភាក្សារបស់ពួកគេ និងឲ្យពួកគេកាន់តែមានទំនុកចិត្តលើព្រះបន្ទូល ព្រមទាំងមានបំណងចិត្តចង់ស្តាប់តាមព្រះអម្ចាស់តាមរយៈការអនុវត្តបទគម្ពីរដែលលោកអ្នកបានសិក្សា ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

# សៀវភៅទី៣
# ការដើរជាមួយព្រះគ្រីស្ទ

*Pre-release គបស  សៀវភៅសម្រាប់គ្រូ  / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣  NavPress Publishing. All rights reserved. For purchase information,*
*come back to [www.cambodianchristianresources.com/dfd-leaders/](http://www.cambodianchristianresources.com/dfd-leaders/)*

# សៀវភៅទី៣
## ជំពូកទី១
## ការលូតលាស់ក្នុងព្រះគ្រីស្ទ

**គោលបំណងនៃជំពូកនេះគឺ៖** ដើម្បីកំណត់ចំណាំថា ការរីកចម្រើនខាងឯវិញ្ញាណ គឺជាដំណើរពេញមួយជីវិត នៅពេលដែលព្រះជាម្ចាស់បំផ្លាស់បម្រែយើងឲ្យកាន់តែរីកចម្រើនឡើងក្នុងលក្ខណៈនៃរូបអង្គព្រះគ្រីស្ទ ពេលនោះយើងកាន់តែចុះចូលនឹងទ្រង់ ។ នេះគឺជាដំណើរនៃការរួមបញ្ចូលគ្នាទាំងជ័យជំនះ និងការបំបាក់សត្រូវ ការតស៊ូយ៉ាងស្វិតស្វាញ និងជោគជ័យ ក៏ដូចជាការសាកល្បងផ្សេងៗទៅលើចរិតលក្ខណៈរបស់យើងផងដែរ ។

សូមលើកទឹកចិត្តសមាជិកក្រុមរបស់លោកអ្នកឲ្យរំឭកខគម្ពីរចងចាំ ហើយត្រូវទុកពេលឲ្យពួកគេរំឭកខគម្ពីរផ្សេងៗដែលបានទន្ទេញចាំនៅក្នុងសៀវភៅទី១ និងទី២ សាឡើងវិញ ។ សូមសម្រេចចិត្តថា គួរឲ្យសមាជិកក្រុមរំឭកខគម្ពីរមុនចាប់ផ្តើមការសិក្សា ឬក៏ក្រោយការសិក្សា ។ រាល់សប្តាហ៍នីមួយៗ សូមលោកអ្នកជ្រើសយកមធ្យោបាយនៃការច្នៃប្រឌិតមួយចំនួនក្នុងការរំឭកខគម្ពីរសាឡើងវិញ ដើម្បីកុំឲ្យលោកអ្នកជាប់គាំងតែក្នុងផ្លូវមួយ ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ប្រហែលជាត្រូវធ្វើគម្រោងសម្រាប់សកម្មភាពដែលមាន ការសហការគ្នា ឬក៏ការកំសាន្តជាមួយក្រុមរបស់លោកអ្នកក្រៅម៉ោងពិភាក្សា ។

លោកអ្នកត្រូវស្នើសុំនរណាម្នាក់ឲ្យអានសេចក្ដីផ្ដើមនៅក្នុងទំព័រទី៥ នៃសៀវភៅទីពឲ្យឮៗ ។

សំណួរដ៏ល្អៗមួយចំនួនសម្រាប់ការពិភាក្សាមានដូចជា សំណួរទី១, ៥ ១២, ១៥និង១៨ ។

**ចំណុចចាប់ផ្ដើមរបស់លោកអ្នក** (សំណួរទី១-៤)

លោកអ្នកអាចចាប់ផ្ដើមការពិភាក្សាដោយសួរសំណួរទូទៅដូចជា ៖ «តើអ្វីទៅជាចំណុចនៃការចាប់ផ្ដើមធ្វើដំណើររបស់លោកអ្នកជាមួយព្រះជាម្ចាស់ ពេលដែលលោកអ្នកពិចារណាលើវគ្គដំបូងនេះ?»

សូមស្ដាប់ចម្លើយពួកគេដោយយកចិត្តទុកដាក់ ហើយជ្រើសរើសម្នាក់មក ដើម្បីសួរសំណួរបន្ត ។ ចូរចងចាំថា យើងអាចប្រើវិធីនេះនៅក្នុងវគ្គផ្សេងៗក្នុងជំពូកនីមួយៗបាន ។ សំណួរដែលយើងបានលើកឡើងនៅក្នុងសៀវភៅនេះជាសំណួរបន្ទាប់បន្សំទៅលើការពិភាក្សាជាមូលដ្ឋានដែលអាចនាំឲ្យពួកគេមានភាពងាយស្រួលក្នុងការពិភាក្សាមេរៀន ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៩១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to [www.cambodianchristianresources.com/dfd-leaders/](www.cambodianchristianresources.com/dfd-leaders/)*

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី១

តើព្រះជាម្ចាស់បានប្រទានអ្វីខ្លះដល់លោកអ្នក ដើម្បីជួយឲ្យលោកអ្នកពេញវ័យខាងឯវិញ្ញាណ?

តើសព្វថ្ងៃនេះ លោកអ្នកបានពេញវ័យខាងឯវិញ្ញាណល្អជាងកាលពីមួយឆ្នាំមុនដែរឬទេ? តើលោកអ្នកដឹងបានដោយរបៀបណា?

**ដំណើរឆ្ពោះទៅរកភាពពេញវ័យ** (សំណួរទី៥-៩)

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី៥

តើការ «រួបរួមខាងឯសេចក្ដីជំនឿ» ក្នុងកណ្ឌគម្ពីរ អេភេសូរ ៤:១៣ មានអត្ថន័យយ៉ាងដូចម្ដេច?

តើគេអាចសម្គាល់លក្ខណសម្បត្តិខាងឯវិញ្ញាណរបស់បុគ្គលម្នាក់ដែលមានភាពពេញវ័យបានដោយរបៀបណា?

**ដំណើរនៃការលូតលាស់** (សំណួរទី១០-១៣)

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី១២

តើលោកអ្នកអាចវាស់វែងភាពពេញវ័យខាងឯរូបកាយបានដោយរបៀបណា? តើលោកអ្នកអាចវាស់វែងភាពពេញវ័យខាងឯវិញ្ញាណបានដោយរបៀបណា?

តើលោកអ្នកគិតថា អ្នកដែលដើរតាមព្រះគ្រីស្ទហើយបាន

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

«សោយរាជ្យក្នុងជីវិត» ដែលមានចែងនៅក្នុងកណ្ឌគម្ពីរ រ៉ូម ៥:១៧ នោះនឹងមានលក្ខណៈយ៉ាងដូចម្ដេចទៅ?

លើសអំពីនេះទៅទៀត តើលោកអ្នកគិតថា លោកអ្នកនឹងមានលក្ខណៈយ៉ាងដូចម្ដេច នៅពេលដែលលោកអ្នកបាន «សោយរាជ្យក្នុងជីវិត» ក្នុងពេលដែលលោកអ្នកកំពុងធ្វើដំណើរខាងឯវិញ្ញាណ?

**របៀបក្នុងការរស់នៅ** (សំណួរទី១៤) **និងជីវិតដែលពេញវ័យ** (សំណួរទី១៥-១៩)

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី១៥ និង១៨

តើលោកអ្នកបានជួបប្រទះការល្អ និងការអាក្រក់នៅក្នុងជីវិតប្រចាំថ្ងៃរបស់លោកអ្នកតាមរបៀបណាខ្លះ?

នៅពេលដែលលោកអ្នកជួបប្រទះការអាក្រក់ ជាធម្មតា តើលោកអ្នកប្រាថ្នាចង់ដោះស្រាយការនោះដោយ យុត្តិធម៌ ឬក៏ដោយក្ដីមេត្តា? (សូមមើលយ៉ាកុប ២:១២-១៣)

តើលោកអ្នកធ្លាប់ទទួលបានការរីកចម្រើនខាងឯវិញ្ញាណត្រង់ផ្នែកណាខ្លះ?

Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០
Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/

## ការបញ្ចប់កិច្ចពិភាក្សា

សូមកុំភ្លេចញែកពេលវេលាពី៥-១០នាទី ដើម្បីនាំពួកគេចូលទៅកាន់ការបញ្ចប់កិច្ចពិភាក្សា ។ លោកអ្នកអាចធ្វើការនេះបានតាមរបៀបច្រើនយ៉ាងខុសៗគ្នា ។ លោកអ្នកក៏អាចស្នើសុំឲ្យសមាជិកក្រុមណាម្នាក់សង្ខេបនូវអ្វីដែលគេបានពិភាក្សា តាមរយៈការអាន **ចំណុចគួរចងចាំ** ដោយបញ្ជាក់ចំណុចគន្លឹះៗដែលក្រុមបានសរុប ឬក៏ការសួរសំណួរសង្ខេបជាទូទៅមួយដូចជា ៖ «តើលោកអ្នកគិតថាសព្វថ្ងៃនេះលោកអ្នកមានការរីកចម្រើនខាងឯវិញ្ញាណលើផ្នែកណាខ្លះ?»

វិធីមួយទៀតក្នុងការបញ្ចប់ការពិភាក្សានោះគឺ អញ្ជើញអ្នកណាដែលបានបញ្ចប់ផ្នែកនៃ**ការចូលឲ្យបានស៊ីជម្រៅ** ឲ្យគាត់ចែកចាយនូវចំណុចសំខាន់ដែលខ្លួនបានរៀនពីមេរៀននេះ ។ គ្រប់ជំពូកនីមួយៗមានសំណួរខ្លះដែលនឹងត្រូវអញ្ជើញសមាជិកក្រុមឲ្យចែកចាយ ការអនុវត្តផ្ទាល់ខ្លួនរបស់គេ ។ ទោះបីជាយ៉ាងនេះក្តីលោកអ្នកអាចសរុបការពិភាក្សា ដោយស្នើសុំអ្នកផ្សេងៗមកចែកចាយពីរបៀបឆ្លើយតបទៅនឹងអ្វីដែលពួកគេបានសិក្សាបន្ទាប់មកយកទៅអនុវត្តក្នុងជីវិតរបស់ពួកគេ ។

លោកអ្នកក៏អាចអញ្ជើញសមាជិកណាម្នាក់ឲ្យជ្រើសរើសយករូបភាពណាមួយ ឬក៏លើកយកសម្រង់សម្ដីណាមួយមកពីជំពូកនោះ

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៩៩០៤៩១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ហើយផ្ដល់ជាមតិខ្លះៗទាក់ទងនឹងឥទ្ធិពលរបស់វាដែលបានប៉ះពាល់ចិត្តរបស់លោកអ្នក ក៏ដូចជាលើជីវិតរបស់ពួកគេផងដែរ ។ ក្នុងនាមជាអ្នកដឹកនាំម្នាក់ លោកអ្នកគួរតែគ្រោងមើលថា តើសកម្មភាពណាមួយនៃការបញ្ចប់កិច្ចពិភាក្សានេះដែលល្អបំផុតសម្រាប់ក្រុមរបស់លោកអ្នកមុននឹងអធិស្ឋានបិទ ។

## ការអធិស្ឋាន

ប្រសិនបើក្រុមរបស់លោកអ្នកធ្លាប់បានជួបជុំគ្នាមួយរយៈកន្លងមកហើយ ឧទាហរណ៍ថាបានរៀនចប់សៀវភៅទី១ និងទី២រួចហើយ នោះពួកគេគួរតែមានភាពងាយស្រួលក្នុងការចែកចាយនូវសំណូមពរអធិស្ឋាន និងការអធិស្ឋានឲ្យឮៗទាំងអស់គ្នាជាងមុន ។ នៅពេលដែលលោកអ្នកអធិស្ឋានបញ្ចប់ការពិភាក្សាថ្ងៃនេះ សូមរំឭកសមាជិកក្រុមទាំងអស់ថា ភាពពេញវ័យខាងឯវិញ្ញាណ គឺជាដំណើរការដ៏អាថ៌កំបាំងមួយដែលយើងអាចរារាំងបាន ប៉ុន្តែមានតែព្រះជាម្ចាស់ប៉ុណ្ណោះដែលអាចសម្រេចបានពេញលេញ ។ សូមសរសើរតម្កើងព្រះជាម្ចាស់ពីគ្រប់ទាំងជំហាននៃការរីកចម្រើនដែលលោកអ្នកមើលឃើញនៅក្នុងក្រុមទៅវិញទៅមក ។ មួយគ្នាផងដែរ សូមពិចារណាពីសំណើនៃអធិស្ឋានដែលមានក្នុង**គន្លឹះនៃការពិភាក្សា**ខាងក្រោម ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

## ការរំឭកខគម្ពីរចងចាំ

ប្រសិនបើក្រុមរបស់លោកអ្នកបានយល់ព្រមទន្ទេញ ហើយនិងរំឭកខគម្ពីរជាមួយគ្នានោះ សូមកុំភ្លេចទុកពេលខ្លះ ដើម្បីរំឭកសារឡើងវិញផង ។ ដោយសារតែវាជាចំណុចចាប់ផ្តើមនៃសៀវភៅថ្មី ដូច្នេះលោកអ្នកប្រហែលជាត្រូវចំណាយពេលខ្លះ ដើម្បីរំឭកសំណើខគម្ពីរចងចាំដែលមាននៅលើទំព័រទី ៤៣-៤៥ ។ សូមរិះរកគំនិតដើម្បីលើកទឹកចិត្តសមាជិកក្រុមឲ្យទន្ទេញខគម្ពីរ ហើយក៏ត្រូវបត់បែនវិធីសាស្ត្រដែលលោកអ្នកទម្លាប់ធ្វើ ពេលរំឭកខគម្ពីរចងចាំជាមួយគ្នាផងដែរ ។

**គន្លឹះនៃការពិភាក្សា ៖ ចូលរួមអធិស្ឋានជាមួយគ្នា**

សមាជិកម្នាក់ៗនៅក្នុងក្រុមរបស់លោកអ្នកតែងតែមានតម្រូវការពិសេសណាមួយក្នុងចិត្តរបស់ពួកគេ ។ តម្រូវការរបស់ពួកគេប្រហែលជាអាចទាក់ទិនទៅនឹង ការប្រលង បញ្ហាសុខភាព បញ្ហាថវិកា ឬទំនាក់ទំនងជាដើម ។ យើងម្នាក់ៗតែងតែមានសេចក្តីត្រូវការគ្រប់គ្នា ។ ហើយយើងក៏អាចថ្វាយសេចក្តីត្រូវការទាំងនេះទៅព្រះជាម្ចាស់ជាមួយគ្នាដែរ ។ សូមអធិស្ឋានឲ្យគ្នាទៅវិញទៅមកក្នុងអំឡុងសប្តាហ៍ចន្លោះការពិភាក្សានីមួយៗ ។ ជម្រើសមួយនៃ

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ការអធិស្ឋាននោះគឺ ការចាប់ដៃគូ រួចអធិស្ឋានឲ្យគ្នា
ទៅវិញទៅមក ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information,*
*come back to www.cambodianchristianresources.com/dfd-leaders/*

# សៀវភៅទី៣
## ជំពូកទី២
## ភាពជាព្រះអម្ចាស់របស់ព្រះគ្រីស្ទ

**គោលបំណងនៃជំពូកនេះគឺ៖** ដើម្បីឲ្យដឹងថា ការទុកចិត្តលើព្រះគ្រីស្ទក្នុងការគ្រប់គ្រងលើជីវិតរបស់យើង គឺជាផ្លូវតែមួយគត់ ដើម្បីឲ្យមានជីវិតពេញបរិបូណ៌ និងដើម្បីសិក្សាពីរបៀបដែលយើងអនុញ្ញាតិឲ្យទ្រង់គ្រប់គ្រងលើជីវិតរបស់យើង ។

សូមលើកទឹកចិត្តក្រុមឲ្យចេះបង្កើតគោលដៅផ្ទាល់ខ្លួនតាមផ្នែកនីមួយៗដូចដែលមាននៅក្នុងរូបភាពកង់រទេះ និងរូបភាពម្រាមដៃ ។ សូមចែកចាយគំរូស្ដីពីរបៀបនៃការអភិវឌ្ឍគោលដៅរបស់លោកអ្នកដល់ពួកគេ ។ ឧទាហរណ៍ នៅត្រង់ចំណុចនៃការអធិស្ឋាននៅក្នុងរូបភាពកង់រទេះ លោកអ្នកអាចចែកចាយពីគោលដៅដែលលោកអ្នកមាននៅក្នុងតារាងនៃការអធិស្ឋានប្រចាំថ្ងៃស្ដីពីតម្រូវការផ្សេងៗរបស់លោកអ្នក ។ នៅត្រង់ចំណុចនៃការអាន (រូបភាពម្រាមដៃ) លោកអ្នកអាចចែកចាយពីគោលដៅនៃការអានព្រះគម្ពីរទាំងមូលក្នុងរយៈពេលមួយឆ្នាំ ដោយអានចាប់ពីបីទៅបួនជំពូកជារៀងរាល់ថ្ងៃ ។

ខណៈពេលដែលសមាជិកក្រុមរបស់លោកអ្នកកំពុងតែរង់ចាំ

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

អ្នកផ្សេងៗទៀត នោះសូមលើកទឹកចិត្តអ្នកដែលមកដល់មុនឲ្យរំឭកខគម្ពីរចងចាំជាដៃគូ ។

សំណួរដ៏ល្អៗមួយចំនួនសម្រាប់ការពិភាក្សាមានដូចជា សំណួរទី២, ៧, ៩, ១៣, ១៤, ១៧និង២០ ។

**ព្រះអម្ចាស់យេស៊ូវគ្រីស្ទ** (សំណួរទី១-៦)

សំណួរសម្រាប់ចាប់ផ្ដើមការពិភាក្សារបស់លោកអ្នកលើវគ្គនីមួយៗ គួរចាប់ផ្ដើមដោយសំណួរ «តើ...ដោយរបៀបណា» ឬ «ហេតុអ្វី» ហើយសំណួរទាំងនេះគួរសួរទៅសមាជិកក្រុមទាំងមូលជាជាងសួរទៅកាន់បុគ្គលតែម្នាក់ ។

លោកអ្នកអាចចាប់ផ្ដើមការពិភាក្សាដោយសួរសំណួរទូទៅដូចជា ៖ «មុនពេលដែលយើងពិភាក្សាអំពីភាពជាព្រះអម្ចាស់របស់ព្រះយេស៊ូវ សូមគិតទៅមើលថា ហេតុអ្វីបានជាព្រះគម្ពីរហៅព្រះយេស៊ូវថា **ព្រះអម្ចាស់?**» ឬក៏សួរថា «តើមានអ្វីដែលបានប៉ះពាល់ចិត្តរបស់លោកអ្នក នៅពេលដែលលោកអ្នកពិចារណាលើវគ្គដំបូងនេះ?»

**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី២

នៅពេលដែលលោកអ្នកហៅបុគ្គលណាម្នាក់ថា

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

«ព្រះអម្ចាស់» តើលោកអ្នកចង់មានអត្ថន័យយ៉ាងដូចម្ដេច?

តើមានចំណុចណាខ្លះដែលបង្ហាញថា ព្រះយេស៊ូវគឺជាព្រះអម្ចាស់?

តើលោកអ្នកយល់យ៉ាងណាដែលថា ព្រះយេស៊ូវគឺជា**ព្រះអម្ចាស់**?

**ការទទួលស្គាល់ភាពជាព្រះអម្ចាស់របស់ព្រះគ្រីស្ទតាមរយៈការសម្រេចចិត្ត** (សំណួរទី៧-១២)

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី៧និង៩

បើព្រះយេស៊ូវជាព្រះអម្ចាស់លើជីវិតរបស់លោកអ្នក តើទ្រង់មានសិទ្ធិបែបណាខ្លះលើលោកអ្នក?

តើការចុះចូលទៅនឹងភាពជាព្រះអម្ចាស់របស់ព្រះគ្រីស្ទទាមទារឲ្យមានអ្វីខ្លះ?

តើមានរបៀបណាខ្លះដែលយើងអាចយាងព្រះគ្រីស្ទមកធ្វើជាព្រះអម្ចាស់នៃជីវិតរបស់យើងបាន?

តើលោកអ្នកគិតថា អស់អ្នកដែលដើរតាមព្រះយេស៊ូវតែងតែចុះចូលចំពោះភាពជាព្រះអម្ចាស់របស់ព្រះគ្រីស្ទឬ? ហេតុអ្វីចុះចូល ឬហេតុអ្វីមិនចុះចូល?

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to [www.cambodianchristianresources.com/dfd-leaders/](www.cambodianchristianresources.com/dfd-leaders/)*

តើលោកអ្នកបានធ្វើអ្វីខ្លះដែលបង្ហាញថា លោកអ្នកបានចុះចូលចំពោះភាពជាព្រះអម្ចាស់របស់ព្រះគ្រីស្ទ?

**ការទទួលស្គាល់ភាពជាព្រះអម្ចាស់របស់ទ្រង់ក្នុងការអនុវត្ត** (សំណួរទី១៣)

**ការពិនិត្យរកសារធាតុពិត** (សំណួរទី១៤-២០)

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី១៣, ១៤, ១៧និង២០

តើការដែលយើងបន្ទាបខ្លួន «នៅក្រោមព្រះហស្តដ៏ពូកែរបស់ព្រះ» មានន័យយ៉ាងដូចម្តេច (១ពេត្រុស ៥:៦)?

តើការបន្ទាបខ្លួន និងការផ្ទេរគ្រប់ទាំងសេចក្តីទុក្ខព្រួយរបស់យើងទៅលើព្រះជាម្ចាស់មានទំនាក់ទំនងអ្វីនឹងគ្នា?

តើលោកអ្នករក្សាទុក្ខកង្វល់ និងទុក្ខព្រួយជាមួយខ្លួនលោកអ្នកនៅពេលណាខ្លះ?

តើមានវិធីសាស្ត្រដ៏ល្អណាមួយដែលលោកអ្នកអាចប្រើ ដើម្បីឲ្យដឹងថា ព្រះយេស៊ូវពិតជាព្រះអម្ចាស់នៃជីវិតរបស់លោកអ្នកមែន?

តើភាពជាព្រះអម្ចាស់របស់ព្រះគ្រីស្ទមានន័យយ៉ាងដូចម្តេចចំពោះលោកអ្នកផ្ទាល់?

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

## ការបញ្ចប់កិច្ចពិភាក្សា

ប្រធានបទនេះពិតជានាំយើងឲ្យមានការអនុវត្តផ្ទាល់ខ្លួនមែន ។ សូមញែកពេលវេលាទុកសមាជិកក្រុម ដើម្បីចែកចាយពីការអនុវត្ត នៅពេលដែលលោកអ្នកសង្ខេប ឬបញ្ចប់ការពិភាក្សា ។ សូមបញ្ចប់ការពិភាក្សាដោយសួរសំណួរទូទៅដូចជា «តើលោកអ្នកធ្លាប់ដកពិសោធន៍ពីការលូតលាស់នៃការចុះចូលចំពោះភាពជាព្រះអម្ចាស់របស់ព្រះគ្រីស្ទក្នុងផ្នែកណាខ្លះ?»

## ការអធិស្ឋាន

ពេលអធិស្ឋាន សូមលោកអ្នកផ្តោតទៅលើភាពជាព្រះអម្ចាស់របស់ព្រះគ្រីស្ទលើគ្រប់អ្វីៗទាំងអស់ និងភាពជាព្រះអម្ចាស់របស់ព្រះគ្រីស្ទលើជីវិតលោកអ្នក ព្រមទាំងភាពពេញវ័យខាងឯវិញ្ញាណរបស់លោកអ្នក ។

## ការរំឭកខគម្ពីរចងចាំ

តើសមាជិកក្រុមរបស់លោកអ្នកកំពុងតែប្រើខគម្ពីរដែលមាននៅក្នុងកូនក្រដាសដើម្បីទន្ទេញ ហើយនិងរំឭកខគម្ពីរចងចាំដែរឬទេ? ប្រសិនបើមិនទាន់ប្រើប្រាស់ទេ សូមចំណាយពេលលើកទឹកចិត្តពួកគេថា ការប្រើខគម្ពីរដែលមាននៅក្នុងកូនក្រដាសជាវិធីមួយដ៏ល្អ

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ក្នុងការទន្ទេញ ហើយនិងរំឭកខគម្ពីរចងចាំ ។ សូមចែកកូនក្រដាសសដល់ពួកគេ ដើម្បីយកទៅប្រើប្រាស់នៅក្នុងសៀវភៅទី៣ ។

**គន្លឹះនៃការពិភាក្សា ៖ មានការប្រកបជាមួយគ្នា**

ការប្រកបដោយការនិយាយស្តី និងការប្រកបដោយធ្វើអ្វីមួយ គឺជាវិធីដែលជួយឲ្យយើងចេះទុកចិត្តគ្នាទៅវិញទៅមក ។ ការប្រកបនោះមានដូចជា ការបម្រើអ្នកផ្សេងៗជាមួយគ្នា ការទៅញ៉ាំអាហារជាមួយគ្នា ការទៅមើលកុនជាមួយគ្នា ការទៅបោះជំរំជាមួយគ្នា ។ល។ នៅពេលដែលក្រុមរបស់លោកអ្នកចាប់ផ្តើមប្រកបគ្នាដោយធ្វើអ្វីមួយ នោះការនិយាយស្តីជាមួយគ្នានឹងកាន់តែមានភាពស៊ីជម្រៅ

Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០
Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/

ស្បៀវភៅទី៣
ជំពូកទី៣

# ជំនឿនិងសេចក្តីសន្យារបស់ព្រះជាម្ចាស់

**គោលបំណងនៃជំពូកនេះគឺ៖** ដើម្បីឲ្យដឹងថា ជំនឿរបស់យើងគឺត្រូវផ្អែកទៅលើសេចក្តីសន្យារបស់ព្រះជាម្ចាស់ដែលមានចែងនៅក្នុងព្រះគម្ពីរ ដូច្នេះយើងអាចទុកចិត្តបានថា ព្រះជាម្ចាស់នឹងបំពេញសេចក្តីសន្យារបស់ទ្រង់ចំពោះយើង ហើយអាចទុកចិត្តបានថាព្រះជាម្ចាស់ស្មោះត្រង់ ទោះបីជាការបំពេញសេចក្តីសន្យារបស់ទ្រង់ប្រើពេលវេលាយូរឆ្នាំក៏ដោយ ។

សំណួរដ៏ល្អៗមួយចំនួនសម្រាប់ការពិភាក្សាមានដូចជា សំណួរទី១, ៤, ៥, ៩, ១០, ១១, ១៣និង១៧

**ការដើរដោយជំនឿ** (សំណួរទី១-៦)

សូមជួយដល់សមាជិកក្រុមនីមួយៗឲ្យដឹងថា ការផ្តល់ឲ្យនិងការទាញយកសារប្រយោជន៍ចេញពីការពិភាក្សាក្នុងក្រុម គឺជាតួនាទីរបស់ពួកគេ ។ លោកអ្នកអាចចាប់ផ្តើមការពិភាក្សាដោយសួរសំណួរទូទៅដូចជា៖ «តើព្រះគម្ពីរបានពណ៌នាពីជំនឿដោយ

Pre-release គបស ស្បៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០
Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/

របៀបណា នៅពេលដែលលោកអ្នកពិចារណាលើវគ្គដំបូងនេះ?»

**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី១, ៤និង៥

តើជំនឿ និងការទុកចិត្តមានភាពស្រដៀងគ្នាយ៉ាងដូចម្ដេចខ្លះ?

ហេតុអ្វីបានជាជំនឿមានសារៈសំខាន់ក្នុងការដើរតាមព្រះយេស៊ូវ?

តើយើងអាចប្រឈមមុខដោយស្មោះត្រង់ជាមួយនឹងមន្ទិលសង្ស័យរបស់យើង ស្របពេលដែលជំនឿរបស់យើងលូតលាស់យ៉ាងដូចម្ដេច?

ប្រសិនបើលោកអ្នកកំពុងតែប្រឈមមុខជាមួយនឹងកាលៈទេសៈដ៏ពិបាកនៅពេលនេះ តើលោកអ្នកអាចឆ្លើយតបទៅនឹងកាលៈទេសៈនោះដោយទុកចិត្តលើភាពស្មោះត្រង់របស់ព្រះជាម្ចាស់បានយ៉ាងដូចម្ដេច?

**គោលបំណងនៃជំនឿ** (សំណួរទី៧-៩)

**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី៩

តើទំហំនៃជំនឿដែលយើងមាន ឬក៏មនុស្សនិងវត្ថុ មួយណាសំខាន់ជាង? ហេតុអ្វី?


*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

តើយើងទទួលបានជំនឿមកពីព្រះជាម្ចាស់ ឬក៏អ្វីម្យ៉ាងដែលយើងដាក់ក្នុងព្រះជាម្ចាស់? សូមពន្យល់ ៖

**គំរូនៃជំនឿ** (សំណួរទី១០)

**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី១០

តើយើងអាចធ្វើតាមគំរូនៃជំនឿក្នុងកណ្ឌគម្ពីរ ហេព្រើរ ១១ ដោយរបៀបណា?

**សេចក្ដីសន្យារបស់ព្រះជាម្ចាស់** (សំណួរទី១១-១៣)

ដូចម្ដេចដែលហៅថា សេចក្ដីសន្យា?

តើការរក្សាសេចក្ដីសន្យា ឬការមិនរក្សាសេចក្ដីសន្យាបានជះឥទ្ធិពលមកលើលោកអ្នកយ៉ាងដូចម្ដេច?

**សេចក្ដីសន្យាដែលត្រូវទាមទារ** (សំណួរទី១៤-១៩)

**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី១៧

តើការទាមទារយកសេចក្ដីសន្យាមានន័យយ៉ាងដូចម្ដេច?

ហេតុអ្វីបានជាព្រះជាម្ចាស់សន្យាចំពោះបុត្រាបុត្រីរបស់ទ្រង់?

តើលោកអ្នកអាចទាមទារយកសេចក្ដីសន្យាមួយណានៅក្នុងព្រះគម្ពីរ?

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

**ការបញ្ចប់កិច្ចពិភាក្សា**

ពេលដែលលោកអ្នកបញ្ចប់ការពិភាក្សាក្នុងមេរៀននេះ ចូរសួរសំណួរសង្ខេបថា «តើលោកអ្នកកំពុងតែទាមទារយកសេចក្ដីសន្យាមួយណាពីព្រះជាម្ចាស់ទុកសម្រាប់ជីវិតរបស់លោកអ្នក?» ឬក៏លោកអ្នកអាចមើលនៅក្នុងវគ្គ **ការចូលឲ្យបានស៊ីជម្រៅ**ជាមួយគ្នា ព្រោះវគ្គនេះមានរៀបរាប់ពីការអស្ចារ្យមួយចំនួនស្ដីពីព្រះជាម្ចាស់ដែលបណ្ដាលឲ្យយើងទុកចិត្តលើទ្រង់ដោយជំនឿបាន ។

ដូចគ្នាផងដែរ សូមលើកទឹកចិត្តសមាជិកក្រុមរបស់លោកអ្នកឲ្យញែកពេលវេលាឲ្យបានច្រើនជាងមុន ដើម្បីត្រិះរិះ និងបំពេញតារាងសំណួរទី១៩ក្នុងជំពូកទី៤ ។

## ការអធិស្ឋាន

ប្រសិនបើលោកអ្នកបានបញ្ចប់ការពិភាក្សាដោយប្រើវគ្គ **ការចូលឲ្យបានស៊ីជម្រៅ**រួចមកហើយនោះ នោះលោកអ្នកក៏គួរប្រើតារាងនៃលក្ខណៈដ៏អស្ចារ្យមួយចំនួនរបស់ព្រះជាម្ចាស់ ដើម្បីដឹកនាំឲ្យចូលទៅកាន់ពេលវេលាមួយនៃការថ្វាយបង្គំ និងការសរសើរតម្កើងដល់ព្រះជាម្ចាស់ ។

**ការរំឭកខគម្ពីរចងចាំ**

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

នៅពេលដែលលោកអ្នករំឭកខគម្ពីរចងចាំ នោះចូរកត់សម្គាល់ថា តើមានអ្នកណាក្នុងសមាជិកក្រុមរបស់លោកអ្នកដែលបានបាក់ទឹកចិត្តឈប់ទន្ទេញខគម្ពីរ ។ ចូរចំណាយពេលជាមួយពួកគេម្នាក់ទល់ម្នាក់ ដើម្បីពង្រឹងទឹកចិត្តពួកគេឲ្យទន្ទេញខគម្ពីរចងចាំឡើងវិញក្នុងអំឡុងសប្តាហ៍ខាងមុខ ឬក៏លោកអ្នកមានវិធីណាផ្សេងទៀត ។

**គន្លឹះនៃការពិភាក្សា ៖** មានភាពប្រាកដប្រជា

អ្នកដឹកនាំដែលមានភាពប្រាកដប្រជាតែងតែយើងក្នុងដំណើរខាងឯវិញ្ញាណរបស់យើងជាជាងអ្នកដឹកនាំដែលដឹងគ្រប់ទាំងចម្លើយហើយមិនដែលស្គាល់ទុក្ខលំបាក ។ លោកអ្នកប្រហែលជាមិនចាំបាច់ចែកចាយពីការតយុទ្ធរបស់លោកអ្នកដោយល្អិតល្អន់ជាមួយសមាជិកក្រុមនោះទេ ប៉ុន្តែត្រូវមានភាពស្មោះត្រង់ និងប្រាកដប្រជា ។ ក្រុមរបស់លោកអ្នកអាចនឹងគាំទ្រលោកអ្នកនៅពេលដែលលោកអ្នកចែកចាយពីជីវិតដ៏ពិតដល់ពួកគេ ។ ហើយស្របពេលដែលលោកអ្នកចែកចាយរឿងផ្ទាល់ខ្លួន ហើយទុកចិត្តលើសមាជិកក្រុមនោះលោកអ្នកនឹងបង្កើតបរិយាកាសដែលពេញដោយព្រះគុណដែលពួកគេនឹងចាប់ផ្តើមមានភាពប្រាកដប្រជាដែរ ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

សៀវភៅទី៣
ជំពូកទី៤

**ការស្គាល់ព្រះហឫទ័យរបស់ព្រះជាម្ចាស់**

**គោលបំណងនៃជំពូកនេះគឺ៖** ដើម្បីស្គាល់ពីរបៀបនៃការស្វែងរក និងការស្គាល់បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ។

ដោយសារតែសៀវភៅទី៣នៅសល់តែមួយជំពូកទៀត ដូច្នេះឥឡូវនេះគឺជាពេលវេលាដ៏ល្អមួយដើម្បីចំណាយពេលឲ្យបានច្រើនជាមុនក្នុងរំឭកខគម្ពីរចងចាំចេញពីសៀវភៅនេះ រួមទាំងខគម្ពីរក្នុងជំពូកនេះផងដែរ ។

សំណួរដ៏ល្អៗមួយចំនួនសម្រាប់ការពិភាក្សាមានដូចជាសំណួរទី២, ៥, ៦, ៧និង១៣ ។ ហើយនៅក្នុងគោលការណ៍នៃការសម្រេចចិត្ត៖ តើលោកអ្នកបានរៀនចំណុចចម្បងអ្វី? តើចំពោះលោកអ្នក គោលការណ៍ដ៏សំខាន់បំផុតក្នុងការសម្រេចចិត្តគឺជាអ្វី?

**ព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលទ្រង់បានបើកសម្តែង** (សំណួរទី១-៥)

លោកអ្នកអាចចាប់ផ្តើមការពិភាក្សាដោយការស្នើសុំនរណាម្នាក់ឲ្យអានសេចក្តីផ្តើមក្នុងជំពូកនវ ។ អញ្ជើញសមាជិកក្រុមឲ្យ

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ឆ្លើយតបទៅនឹងសម្រង់សម្ដីរបស់លោក ប៉ុល លីថល Paul Littleស្ដីពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ ប្រសិនបើពួកគេធ្លាប់ឆ្លងកាត់។ បន្ទាប់មក លោកអ្នកអាចចាប់ផ្ដើមពិភាក្សាវគ្គនេះដោយសួរសំណួរទូទៅមួយដូចជា «តើមានអ្វីដែលប៉ះពាល់ចិត្តលោកអ្នកខ្លាំងជាងគេបំផុតស្ដីពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលទ្រង់បានបើកសម្ដែង?»

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី២និង៥

តើយើងអាចរំពឹងទុកបានប៉ុណ្ណាដែលថា ព្រះជាម្ចាស់បើកសម្ដែងពីព្រះហឫទ័យរបស់ទ្រង់ដល់យើង?

ហេតុអ្វីបានជាការយល់ពីព្រះហឫទ័យរបស់ព្រះជាម្ចាស់មានសារៈសំខាន់ចំពោះយើង?

តើព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យអ្នកដើរតាមព្រះយេស៊ូវទទួលបាននូវភាពជាក់លាក់អ្វីខ្លះ?

**គោលការណ៍នៃការសម្រេចចិត្ត** (សំណួរទី៦-១៨)

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី៦, ៧និង១៣

នៅពេលដែលលោកអ្នករំឭកពីវិធីសាស្ត្រផ្សេងៗ ដើម្បីឲ្យព្រះហឫទ័យរបស់ព្រះជាម្ចាស់ តើលោកអ្នកបានប្រើវិធីសាស្ត្រណា

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ខ្លះហើយ?

តើលោកអ្នកនឹងពន្យល់កណ្ឌគម្ពីរ ម៉ាថាយ ៦:៣៣ ដល់អ្នកដែលទើបនឹងដើរតាមព្រះយេស៊ូវថ្មីៗដោយរបៀបណា?

តើលោកអ្នកយល់យ៉ាងដូចម្ដេចពីជីវិតដ៏បរិសុទ្ធ (១ពេត្រុស ១:១៥)?

តើការត្រាប់តាមសម័យនេះមានន័យយ៉ាងដូចម្ដេច?

តើព្រះវិញ្ញាណបរិសុទ្ធដឹកនាំយើងដោយរបៀបណា?

តើអ្នកដែលផ្ដល់ការប្រឹក្សាដល់លោកអ្នកគួរមានគុណសម្បត្តិដូចម្ដេចខ្លះ?

ចូរពិចារណាកណ្ឌគម្ពីរ យ៉ាកុប ១:៥ ។ តើលោកអ្នកទូលសូមប្រាជ្ញាពីព្រះជាម្ចាស់ដែរឬទេ? តើទ្រង់ឆ្លើយតបឬទេ? សូមពន្យល់ ៖

**ការអនុវត្តគោលការណ៍** (សំណួរទី១៩-២៧)

**សំណើសម្រាប់ការពិភាក្សា ៖**

តើលោកអ្នកបានរៀនចំណុចចម្បងអ្វីចេញពីតារាងនេះ?

តើចំពោះលោកអ្នក គោលការណ៍ដ៏សំខាន់បំផុតក្នុងការសម្រេចចិត្តគឺជាអ្វី?

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

## ការបញ្ចប់កិច្ចពិភាក្សា

ក្នុងការបញ្ចប់ការពិភាក្សានៅសប្តាហ៍នេះ លោកអ្នកអាចស្នើសុំសមាជិកក្រុមឲ្យផ្តល់ជាមតិលើរូបភាព និងសម្រង់សម្តី ឬក៏ចែកចាយពីការអនុវត្តផ្ទាល់ខ្លួន ។ បន្ថែមលើសពីនេះទៅទៀត ត្រូវសង្ខេបរូបភាពដែលបង្ហាញពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់នៅក្នុងវគ្គ **ការចូលឲ្យបានស៊ីជម្រៅ** ។

## ការអធិស្ឋាន

តើមានសមាជិកនៅក្នុងក្រុមរបស់លោកអ្នកស្វែងរកបំណងព្រះហឫទ័យក្នុងការសម្រេចចិត្តដ៏ជាក់លាក់ដែរឬទេ? ប្រសិនបើមានសូមទៅក្បែរគាត់ ហើយអធិស្ឋានជាមួយគ្នា ។

### ការរំឭកខគម្ពីរចងចាំ

ប្រសិនបើសមាជិកក្រុមរបស់លោកអ្នកបានយល់ព្រមទន្ទេញហើយនិងរំឭកខគម្ពីរជាមួយគ្នា ដូច្នេះសូមញែកពេលដើម្បីរំឭកខគម្ពីរនោះ ។ សូមរំឭកខគម្ពីរក្នុងជំពូកនេះ និងខគម្ពីរក្នុងជំពូកមុនផងដែរ ។ ចូរសួរសមាជិកក្រុមថា តើការចងចាំព្រះគម្ពីរបានជួយពួកគេដោយរបៀបណាខ្លះក្នុងសប្តាហ៍នេះ?

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

**គន្លឹះនៃការពិភាក្សា៖** សំណួរដែលគ្មានចម្លើយ

ពេលខ្លះសមាជិកក្រុមរបស់លោកអ្នកនឹងសួរសំណួរដែលគេនឹងមិនទទួលបានចម្លើយដ៏ពេញចិត្ត ។ នោះវាមិនអីទេ ។ ក្នុងដំណើររបស់យើងជាមួយព្រះយេស៊ូវ ជួនកាលទ្រង់អនុញ្ញាតិឲ្យយើងទទួលចម្លើយដែលយើងមិនពេញចិត្ត ពីព្រោះសព្វព្រះហឫទ័យឲ្យយើងទុកចិត្តលើទ្រង់បន្ថែមទៀត ។ ជាធម្មតា ព្រះជាម្ចាស់នឹងបើកសម្តែងចម្លើយឲ្យយើងដឹងនៅក្នុងពេលវេលារបស់ទ្រង់ ។ ប្រសិនបើមានសមាជិកក្រុមណាម្នាក់កំពុងតែមានការពិបាកក្នុងការទទួលយកចម្លើយដែលគេមិនទាន់ពេញចិត្ត នោះសូមលើកទឹកចិត្តគាត់ឲ្យអធិស្ឋានទៅកាន់ព្រះជាម្ចាស់អំពីសំណួរនោះ បន្ទាប់មកលើកទឹកចិត្តគាត់ថា ព្រះជាម្ចាស់នឹងបើកសម្តែងឲ្យគេដឹងពីចម្លើយនោះ ។ ស្របពេលនោះដែរ ចូរបញ្ជាក់ប្រាប់គ្នាទៅវិញទៅមកថា «ការរង់ចាំ» គឺជាចម្លើយមួយដែលព្រះជាម្ចាស់ឆ្លើយតបចំពោះការអធិស្ឋានរបស់យើង ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

សៀវភៅទី៣
ជំពូកទី៥

# ការដើរក្នុងនាមជាអ្នកបម្រើ

**គោលបំណងនៃជំពូកនេះគឺ៖** ដើម្បីដើរតាមគំរូរបស់ព្រះគ្រីស្ទក្នុងការថ្វាយជីវិតយើងទុកជាអ្នកបម្រើដល់អ្នកផ្សេងៗ ។

ដោយសារតែត្រង់នេះជាជំពូកចុងក្រោយនៃសៀវភៅទី៣ ដូច្នេះចូរចំណាយពេលឲ្យបានច្រើនជាងមុនដើម្បីរំឭកខគម្ពីរចងចាំក្នុងជំពូកនេះ ក៏ដូចជាខគម្ពីរចងចាំនៅជំពូកទាំងបួនមុន ។ តើលោកអ្នកអាចរកគំនិតថ្មីក្នុងការរំឭកខគម្ពីរចងចាំឲ្យមានភាពរីករាយដែរឬទេ?

សូមផ្តល់ព័ត៌មានដល់សមាជិកក្រុមពីរបៀបនៃការផ្តល់ថវិកាដល់បេសកជន និងអង្គការបេសកកម្មផ្សេងៗ ។ លោកអ្នកក៏ប្រហែលជាត្រូវរៀបចំគម្រោងក្នុងការបម្រើ ដើម្បីបំពេញតម្រូវការនៅក្នុងព្រះវិហារ ឬក៏សហគមន៍របស់លោកអ្នកផងដែរ ។

សំណួរដ៏ល្អៗមួយចំនួនសម្រាប់ការពិភាក្សាមានដូចជាសំណួរទី២, ៥, ៩, ១៤និង១៦ ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

**ព្រះគ្រីស្ទជាគំរូរបស់លោកអ្នក** (សំណួរទី១-៤)

លោកអ្នកអាចចាប់ផ្តើមសួរសំណួរពិភាក្សាទូទៅមួយដូចជា «តើមានអ្វីដែលប៉ះពាល់ចិត្តលោកអ្នកខ្លាំងបំផុតស្តីពីដួងចិត្តនៃការបម្រើរបស់ព្រះយេស៊ូវចេញពីវគ្គដំបូងនេះ?»

ប្រសិនបើសមាជិកក្រុមមិនយល់ពីសំណួររបស់លោកអ្នក ដូច្នេះចូររកវិធីថ្មីដើម្បីសួរសំណួរនោះម្តងទៀត ។

**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី២

ហេតុអ្វីបានជាព្រះយេស៊ូវយាងមកធ្វើជាអ្នកបម្រើ?

តាមការយល់ឃើញរបស់លោកអ្នក ហេតុអ្វីបានជាព្រះយេស៊ូវលាងជើងសិស្សរបស់ទ្រង់?

តើមានរូបភាពបែបណាផុសមកក្នុងគំនិតរបស់លោកអ្នក នៅពេលដែលលោកអ្នកគិតពីភាពជាអ្នកបម្រើ?

**ព្រះហឫទ័យរបស់ព្រះគ្រីស្ទសម្រាប់លោកអ្នក** (សំណួរទី៥-៧)

**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី៥

ហេតុអ្វីបានជាព្រះយេស៊ូវផ្តោតលើភាពជាអ្នកបម្រើខ្លាំងម្ល៉េះ?

តើលោកអ្នកមានអារម្មណ៍យ៉ាងដូចម្តេច នៅពេលដែល

Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០
Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/

លោកអ្នកបានបម្រើនរណាម្នាក់ដោយស្ម័គ្រចិត្ត?

តើលោកអ្នកមានអារម្មណ៍យ៉ាងដូចម្ដេច នៅពេលដែលមាននរណាម្នាក់រាប់លោកអ្នកដូចជាអ្នកបម្រើ? តើលោកអ្នកមានដំណោះស្រាយយ៉ាងណាពីអារម្មណ៍ទាំងនេះ?

តើលោកអ្នកចង់ក្លាយជាមនុស្សដ៏អស្ចារ្យម្នាក់ ឬក៏អ្នកបម្រើដ៏អស្ចារ្យម្នាក់?

**ការថ្វាយខ្លួន** (សំណួរទី៨-៩)

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី៩

តើលោកអ្នកគិតថា ការល្បងដ៏ពិតនៃភាពជាអ្នកបម្រើគឺជាអ្វី?

តើសាវ័ក ប៉ុលជាអ្នកបម្រើបែបណារបស់ព្រះយេស៊ូវគ្រីស្ទ?

**គន្លឹះនៃភាពជាអ្នកបម្រើ** (សំណួរទី១០-១៨)

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី១៤និង១៦

ហេតុអ្វីបានជាការបន្ទាបខ្លួនមានសារៈសំខាន់?

តើលោកអ្នកអាចក្លាយជាអ្នកបម្រើដ៏ល្អមួយក្នុងសប្ដាហ៍នេះដោយរបៀបណា?

*Pre-release គបស ស្បៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to [www.cambodianchristianresources.com/dfd-leaders/](www.cambodianchristianresources.com/dfd-leaders/)*

## ការបញ្ចប់កិច្ចពិភាក្សា

ចូរជ្រើសរើសវិធីសាស្ត្រខាងក្រោមនេះដើម្បីបញ្ចប់ការពិភាក្សា៖ ការសង្ខេប រូបភាពនិងសម្រង់សម្ដី ការអនុវត្តផ្ទាល់ខ្លួន ការចូលឲ្យបានស៊ីជម្រៅ ។ ឬក៏សួរថា «យោងតាមមេរៀនដែលយើងបានសិក្សា តើលោកអ្នកអាចផ្ដល់អ្វីដល់អ្នកផ្សេងទៀត ដើម្បីបង្ហាញថាលោកអ្នកពិតជាបម្រើគេមែន?»

## ការអធិស្ឋាន

សូមអញ្ជើញសមាជិកឲ្យអធិស្ឋានសម្រាប់គ្នាទៅវិញទៅមកជាដៃគូ ជាជាងអធិស្ឋានជាក្រុមទាំងមូល ។

## ការរំឭកខគម្ពីរចងចាំ

ចូរសួរសមាជិកក្រុមថា តើការចងចាំព្រះគម្ពីរបានជួយពួកគេដោយរបៀបណាខ្លះក្នុងសប្ដាហ៍នេះ? ប្រសិនបើលោកអ្នកមិនទាន់បានរំឭកខគម្ពីរចងចាំនោះទេ នោះសូមចំណាយពេលឥឡូវនេះដើម្បីរំឭកខគម្ពីរទាំងប្រាំក្នុងសៀវភៅទី៣ ។

## ការរំឭកឡើងវិញ

នេះគឺជាជំពូកចុងក្រោយនៃសៀវភៅទី៣ ។ ប្រហែលជាដល់ពេលដែលលោកអ្នកគួររំឭកពីអ្វីៗដែលបានជួយលោកអ្នកច្រើន

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to [www.cambodianchristianresources.com/dfd-leaders/](www.cambodianchristianresources.com/dfd-leaders/)*

ជាងគេបំផុតនៅក្នុងដំណើរខាងឯវិញ្ញាណរបស់លោកអ្នកដែលបាន ដកស្រង់ចេញពីការសិក្សាក្នុងសៀវភៅទី៣ ។ ចូរពិភាក្សាពី គម្រោងដែលលោកអ្នកនឹងឈ្មោលទៅមុខក្នុងការសិក្សាសៀវភៅ ទី៤ ។ បន្ទាប់មកស្នើសុំឲ្យសមាជិកក្រុមថា តើលោកអ្នកគួរផ្លាស់ប្ដូរ វិធីសាស្ត្រដោយរបៀបណាខ្លះ ដើម្បីជួយឲ្យការសិក្សារបស់ លោកអ្នកកាន់តែចម្រើនឡើងជាមួយគ្នា ។ សូមចែកសៀវភៅទី៤ ដល់អស់អ្នកដែលនឹងបន្តការសិក្សា ។

**គន្លឹះនៃការពិភាក្សា ៖** ការចូលឲ្យបានស៊ីជម្រៅ

មានមនុស្សខ្លះតែងតែចង់យល់បន្ថែមទៀត...ប្រហែលមិន មែនផ្ដោតទៅលើមេរៀននីមួយៗ តែប្រហែលជាពេលវេលាផ្សេង ទៀត ។ អ្នកនិពន្ធបាននិពន្ធវគ្គនៃ**ការចូលឲ្យបានស៊ីជម្រៅ**នេះមក ដើម្បីជួលអ្នកសិក្សាក្នុងការស្វែងយល់បទគម្ពីរបន្ថែមទៀត និង ដើម្បីពិចារណាពីដំណើរជីវិតរបស់ពួកគេជាមួយព្រះជាម្ចាស់ក្នុង កម្រិតដ៏ខ្ពង់ខ្ពស់មួយ ។ ចូរលើកទឹកចិត្តសមាជិក តែកុំទាមទារឲ្យ ពួកគេចែកចាយជ្រៅពេក ។ សូមអញ្ជើញសមាជិកក្រុមដែលបាន បំពេញវគ្គនៃការចូលឲ្យបានស៊ីជម្រៅឲ្យចែកចាយត្រួសៗ នៅពេលដែលលោកអ្នកបញ្ចប់ការពិភាក្សា ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

# សៀវភៅទី៤
# អត្តចរិតរបស់អ្នកដើរតាម ព្រះយេស៊ូវ

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

## សៀវភៅទី៤
## ជំពូកទី១
## ការត្រាស់ហៅចំពោះការរស់នៅប្រកបដោយផលផ្លែ

**គោលបំណងនៃជំពូកនេះគឺ៖** ដើម្បីឲ្យបានយល់ថា ជីវិតរស់នៅដ៏ពេញបរិបូរណ៍ទាមទារនូវភាពបរិសុទ្ធក្នុងការគិត ការនិយាយស្ដី និងការប្រព្រឹត្តរបស់យើង ។

នៅពេលដែលលោកអ្នកចាប់ផ្ដើមសិក្សាសៀវភៅទី៤ ប្រហែលជាលោកអ្នកត្រូវការរំឭករូបភាពកង់រទេះ និងដៃផងដែរ ។ ស្នើសុំសមាជិកក្រុមឲ្យពិចារណាពីរបៀបដែលពួកគេចង់ឲ្យព្រះជាម្ចាស់ជួយពួកគេឲ្យមានភាពពេញវ័យនៅក្នុងសប្ដាហ៍ និងខែខាងមុខៗ ។ បន្ទាប់មកស្នើសុំឲ្យពួកគេជ្រើសយកចំណុចមួយនៅក្នុងរូបភាពកង់រទេះ និងរូបភាពដៃដែលពួកគេចង់ឲ្យមានការលូតលាស់ ។ លោកអ្នកក៏គួរប្រាប់ពួកគេឲ្យសរសេរវិធីជាក់លាក់ខ្លះៗដែលពួកគេចង់ឲ្យមានការលូតលាស់ និងអភិវឌ្ឍនូវចំណុចទាំងពីរដែលពួកគេបានជ្រើសរើសនោះ ។

ដូចគ្នាផងដែរ សូមលោកអ្នកអានសៀវភៅទី៤ដែលមានចំណងជើងថា **ការសាងសង់ដើម្បីគុណភាព និងហេតុអ្វីពេលនេះយើងត្រូវយកចិត្តទុកដាក់ទៅលើអត្តចរិតជាមួយគ្នា ។**

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ចូរព្យាយាមបង្កើតបរិយាកាសដែលនិងបណ្ដាលឲ្យសមាជិកក្រុមមានភាពធូរស្រាល និងមានភាពងាយស្រួលចូលរួមជាមួយក្រុម ។

សំណួរដ៏ល្អៗមួយចំនួនសម្រាប់ការពិភាក្សាមានដូចជា សំណួរទី១, ៣, ៨, ១០, ១៥, ១៦និង១៧ ។

**ការលូតលាស់នៅក្នុងផលផ្លែខាងឯវិញ្ញាណ** (សំណួរទី១-៦)
នៅពេលដែលលោកអ្នកចាប់ផ្ដើមសិក្សាសៀវភៅទី៤ នោះលោកអ្នកប្រហែលជានឹងទទួលបាននូវអត្ថប្រយោជន៍ពីការរំឭកជំពូកដំបូងនៃសៀវភៅនេះ ។ ការរំឭកនេះនឹងជួយលោកអ្នកឲ្យដឹងពីសារប្រយោជន៍នៃគោលការណ៍សម្រាប់ពិភាក្សា ។ ឧទាហរណ៍ លោកអ្នកអាចចាប់ផ្ដើមការពិភាក្សាដោយសួរសំណួរទូទៅដូចជា «យោងតាមវគ្គការលូតលាស់នៅក្នុងផលផ្លែខាងវិញ្ញាណ តើមានអ្វីខ្លះដែលប៉ះពាល់ចិត្តលោកអ្នក?»

មកដល់ពេលឥឡូវនេះ ដោយសារតែលោកអ្នកបានដឹកនាំការពិភាក្សាចេញពី **គម្រោងនៃការបង្កើតសិស្ស** ជាច្រើនមកហើយ ដូច្នេះលោកអ្នកក៏គួរតែមានបទពិសោធន៍ជាច្រើនក្នុងការដឹកនាំលើការពិភាក្សា ។ ដោយហេតុតែលោកអ្នកដឹងថា ការស្ដាប់ចម្លើយ

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

របស់សមាជិកក្រុម និងការជ្រើសរើសនរណាម្នាក់ដើម្បីសួរសំណួរបន្តមានសារៈសំខាន់យ៉ាងណានោះ នោះលោកអ្នកក៏ប្រហែលជាអាចក្លាយទៅជាអ្នកដឹកនាំម្នាក់ដែលអាចបង្កើតសំណួរបន្តបានយ៉ាងល្អភ្លាមៗផងដែរ ។ សំណួរដែលយើងបានផ្តល់ជូនខាងក្រោមនេះគឺគ្រាន់តែជាសំណួរជំនួយប៉ុណ្ណោះ ។

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី១, ២និង៣

តើលោកអ្នកអាចនឹងពន្យល់កណ្ឌគម្ពីរ យ៉ូហាន ១៥:១-៥ ដល់នរណាម្នាក់ផ្សេងទៀតបានយ៉ាងដូចម្តេច?

ហេតុអ្វីបានជាព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យយើងបង្កើតផលផ្លែខាងវិញ្ញាណ?

តើកណ្ឌគម្ពីរ យ៉ូហាន ១៥:១-៥ និងកាឡាទី ៥:២២-២៣ មានទំនាក់ទំនងនឹងគ្នាយ៉ាងដូចម្តេច?

តើលោកអ្នកគិតថា បុគ្គលដែលអង្គុយនៅខាងស្តាំដៃរបស់លោកអ្នកបង្ហាញពីអត្តចរិតបែបណាចេញពីកណ្ឌគម្ពីរ ម៉ាថាយ ៥:៣-១២?

**ការលូតលាស់ខាងឯអត្តចរិត** (សំណួរទី៧-១៣)

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី៨និង១០

តើលោកអ្នកចង់ឃើញអត្តចរិតរបស់លោកអ្នកមាន


*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ការផ្លាស់ប្រែយ៉ាងដូចម្ដេចខ្លះ?

ចូរដាក់ឈ្មោះនរណាម្នាក់ដែលលោកអ្នកជឿថា គេមានប្រាជ្ញាដែលមកពីព្រះជាម្ចាស់ ។ តើលោកអ្នកសង្កេតឃើញអ្វីនៅក្នុងបុគ្គលនេះដែលលោកអ្នកយល់ឃើញថាគេមានប្រាជ្ញា?

**ការលូតលាស់ក្នុងសេចក្ដីអំណរនៃការរស់នៅដ៏បរិសុទ្ធ** (សំណួរទី១៤-១៨)

**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី១៥, ១៦និង១៧

តើលោកអ្នកយល់ឃើញថា ជីវិតដែលពោរពេញដោយអំណរមានលក្ខណៈដូចម្ដេច? តើលោកអ្នកធ្លាប់ឃើញនរណាម្នាក់ពោរពេញដោយអំណរតែមានការយំសោកដែរឬទេ? សូមពន្យល់ ៖

**ការបញ្ចប់កិច្ចពិភាក្សា**

ជារឿយៗ មនុស្សយើងភាគច្រើនតែងតែចងចាំនូវសម្រង់សម្ដីដែលបានលើកឡើងក្រោយគេនៅចុងបញ្ចប់ការពិភាក្សា ។ ចូរចំណាយពេលប្រាំទៅដប់នាទីសម្រាប់ការពិភាក្សារបស់លោកអ្នកដើម្បីផ្ដោតទៅលើប្រធានបទសំខាន់ៗនៃមេរៀន មុននឹងបញ្ចប់ការពិភាក្សា ។ លោកអ្នកអាចធ្វើការនេះបានដោយស្នើសុំសមាជិកក្រុមរបស់លោកអ្នកម្នាក់ឲ្យឆ្លើយនូវសំណួរអនុវត្តដូចជា សំណួរទី១៣ (កដល់ង) ឬក៏សួរសំណួរទូទៅដូចជា «តើលោកអ្នកយល់ថា ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យលោកអ្នក

Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០
Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/

យកចិត្តទុកដាក់ទៅលើការអនុវត្តដែលមានភាពបរិសុទ្ធណាមួយក្នុងចំណុច ការគិត ការនិយាយស្ដី ឬការប្រព្រឹត្ត?»

វិធីសាស្ត្រផ្សេងៗទៀតក្នុងការបញ្ចប់ការពិភាក្សាមានជារួមដូចជា ការអាន**ចំណុចគួរចងចាំ** ការពិភាក្សាលើ**រូបភាព** ឬ**សម្រង់សម្ដី**ណាមួយដែលបានប៉ះពាល់ចិត្តបុគ្គលណាម្នាក់ ឬក៏ចែកចាយពីអ្វីមួយចេញពីវគ្គនៃ**ការចូលឲ្យបានស៊ីជម្រៅ**ដែលជាវគ្គជម្រើស ។

## ការអធិស្ឋាន

ចូរកុំភ្លេចអធិស្ឋានជាមួយគ្នា ។ ការនិយាយ**ជាមួយ**ព្រះជាម្ចាស់មានសារៈសំខាន់ជាជាងការនិយាយ**អំពី**ព្រះជាម្ចាស់នៅពេលដែលសិក្សាទៅទៀត ។ ចូរអសប្បាយក្នុងការថ្វាយបង្គំនិងការសរសើរតម្កើងព្រះជាម្ចាស់ ក៏ដូចជាការកត់យកសំណូមពរអធិស្ឋានផងដែរ ។

### ការរំឭកខគម្ពីរចងចាំ

ប្រសិនបើសមាជិកក្រុមរបស់លោកអ្នកបានយល់ព្រមទន្ទេញហើយនិងរំឭកខគម្ពីរជាមួយគ្នា ដូច្នេះសូមញែកពេលដើម្បីរំឭកខគម្ពីរនោះ ។ សូមរំឭកខគម្ពីរចងចាំនៅក្នុងសប្ដាហ៍នេះ ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ការរំឭកខគម្ពីរចងចាំអាចធ្វើឡើងជាដៃគូ នៅពេលដែលសមាជិកក្រុមកំពុងតែប្រមូលផ្តុំគ្នាមុនការពិភាក្សា ឬក៏អាចកើតឡើងនៅក្រោយការពិភាក្សា ។

**គន្លឹះនៃការពិភាក្សា ៖ ការដឹកនាំក្រុមជាមួយដៃគូ**

ប្រសិនបើលោកអ្នកមិនទាន់មានដៃគូដើម្បីជួយលោកអ្នកក្នុងការដឹកនាំ ចូរស្នើសុំនរណាម្នាក់នៅក្នុងក្រុមរបស់លោកអ្នកមកធ្វើជាដៃគូ ឬក៏ស្នើឲ្យនរណាម្នាក់ផ្សេងទៀតធ្វើជាអ្នកដឹកនាំ ។ អ្នកដឹកនាំដែលមានឥទ្ធិពលតែងតែចង់ជួយដល់អ្នកផ្សេងទៀតឲ្យក្លាយជាអ្នកដឹកនាំដែរ ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

សៀវភៅទី៤

ជំពូកទី២

## សកម្មភាពនៃសេចក្ដីស្រឡាញ់ដែលឥតពុតមាយា

**គោលបំណងនៃជំពូកនេះគឺ៖** ដើម្បីឲ្យឃើញថា សេចក្ដីស្រឡាញ់ទាមទារឲ្យមានការសម្រេចចិត្តដែលមានការពិគ្រោះយ៉ាងល្អិតល្អន់ទាក់ទងនឹងបំណងនេះ និងអាកប្បកិរិយាដែលចេះបន្ទាបខ្លួន ព្រមទាំងបំណងប្រាថ្នាក្នុងការរស់នៅដែលពេញដោយក្ដីស្រឡាញ់ ។

របៀបក្នុងការលូតលាស់ខាងផ្នែកអត្តចរិតគឺ ការស្នើសុំឲ្យសមាជិកក្រុមអាន ហើយអធិស្ឋានកណ្ឌគម្ពីរ សុភាសិតមួយថ្ងៃមួយជំពូកក្នុងរយៈពេលមួយខែទុកដូចជាពេលវេលាស្ងៀមស្ងាត់ផ្ទាល់ខ្លួនមួយជាមួយនឹងព្រះជាម្ចាស់ ។ បន្ទាប់មក សូមពិភាក្សាលើអ្វីៗដែលលោកអ្នកបានរៀនពីកណ្ឌគម្ពីរ សុភាសិតជាមួយគ្នាមួយសប្ដាហ៍ម្ដងៗ ។

សំណួរដ៏ល្អៗមួយចំនួនសម្រាប់ការពិភាក្សាមានដូចជា សំណួរទី១, ២, ៧, ៨, ១២, ១៣និង១៨ ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

## ដូចម្ដេចដែលហៅថាសេចក្ដីស្រឡាញ់ឥតពុតមាយា?

(សំណួរទី១-៤)

លោកអ្នកអាចចាប់ផ្ដើមការពិភាក្សានេះដោយសួរសំណួរទូទៅមួយដូចជា «តើលោកអ្នកបានសង្កេតឃើញចំណុចណាដែលល្អបំផុតនៃសេចក្ដីស្រឡាញ់ឥតពុតមាយា ចេញពីបួនសំណួរ ដំបូង?»

ដូចគ្នាផងដែរ លោកអ្នកក៏អាចស្នើសុំនរណាម្នាក់ឲ្យអានសម្រង់សម្ដីរបស់លោក ភីលីព យេនស៊ី (Philip Yancey) ដើម្បីចាប់ផ្ដើមការពិភាក្សា ។

**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី១និង២

តើលោកអ្នកយល់ថា «សេចក្ដីស្រឡាញ់មិនដែលផុតឡើយ» មានន័យយ៉ាងដូចម្ដេច (១កូរិនថូស ១៣:៨)?

**សេចក្ដីស្រឡាញ់ដែលគ្មានភាពអាត្មានិយម** (សំណួរទី៥-៧)

**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី៧

តើការស្គាល់ពីសេចក្ដីស្រឡាញ់ដ៏ពិត និងការបង្ហាញសេចក្ដីស្រឡាញ់នោះមានទំនាក់ទំនងជាមួយគ្នាយ៉ាងដូចម្ដេច?

តើសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់មានដែនកំណត់ចំពោះនរណាម្នាក់ដែរឬទេ? សូមពន្យល់ ៖

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

តើព្រះជាម្ចាស់មានសេចក្ដីស្រឡាញ់ដែលគ្មានភាពអាត្មានិយមចំពោះលោកអ្នកយ៉ាងដូចម្ដេច?

**សេចក្ដីស្រឡាញ់ដែលចេះបន្ទាបខ្លួន** (សំណួរទី៨-១២)

**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី៨និង១២

តើមានពេលណាមួយដែលសមស្របសម្រាប់លោកអ្នកក្នុងការមានអំនួតលើប្រាជ្ញា កម្លាំង និងទ្រព្យសម្បត្តិរបស់លោកអ្នកដែរឬទេ? (យេរេមា ៩:២៣-២៤)? សូមពន្យល់ ៖

តើលោកអ្នកយល់យ៉ាងណាអំពីការលូតលាស់ក្នុងការបន្ទាបខ្លួន? តើលោកអ្នកមានបំណងចង់បានការបន្ទាបខ្លួនដែរឬទេ? តើលោកអ្នកកំពុងតែស្វែងរករបៀបដែលជួយឲ្យលោកអ្នកចេះបន្ទាបខ្លួនដែរឬទេ?

**សេចក្ដីស្រឡាញ់តាមការនិយាយស្ដី** (សំណួរទី១៣-១៥)

**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី១៣

ហេតុអ្វីបានជាការនិយាយស្ដីមានសារៈសំខាន់ក្នុងការស្រឡាញ់?

តើលោកអ្នកអាចបង្ហាញការគាំទ្រអ្នកផ្សេងទៀតតាមពាក្យសម្ដីដោយរបៀបណា? ជាទូទៅ តើពួកគេឆ្លើយតបទៅនឹងការនិយាយស្ដីរបស់យើងយ៉ាងដូចម្ដេច?

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

**សេចក្តីស្រឡាញ់តាមរយៈការប្រព្រឹត្តល្អ** (សំណួរទី១៦-១៩)
**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី១៨ (ការរំឭកពីសារធាតុនៃសេចក្តីស្រឡាញ់)

តើមានការប្រព្រឹត្តល្អបែបណាខ្លះដែលលោកអ្នកគិតថាលោកអ្នកអាចធ្វើបាន? ហើយហេតុអ្វីបានជាលោកអ្នកគួរធ្វើការនោះ?

## ការបញ្ចប់កិច្ចពិភាក្សា

ក្នុងការបញ្ចប់ការពិភាក្សា លោកអ្នកអាចស្នើសុំនរណាម្នាក់សង្ខេបចំណុចចម្បង អាន**ចំណុចគួរចងចាំ** និងផ្តល់មតិយោបល់ទៅលើរូបភាពនិងសម្រង់សម្តី ព្រមទាំងចែកចាយការអនុវត្តផ្ទាល់ខ្លួន ឬក៏ចែកចាយចេញពីវគ្គ **ការចូលឲ្យបានស៊ីជម្រៅ**។ លោកអ្នកមិនចាំបាច់ធ្វើគ្រប់ទាំងចំណុចនោះទេ ប៉ុន្តែចូរជ្រើសរើសចំណុចដែលលោកអ្នកគិតថានឹងជួយការពិភាក្សាឲ្យមានការរីកចម្រើន។ សំណួរសង្ខេបអនុវត្តទូទៅមួយអាចមានដូចជា «តើលោកអ្នកគួរមានការសម្រេចចិត្តដ៏ល្អិតល្អន់បែបណាខ្លះទាក់ទងទៅនឹងឆន្ទៈដែលនឹងបង្ហាញដល់អ្នកដទៃពីសេចក្តីស្រឡាញ់ក្នុងជីវិតលោកអ្នក?»

ចូរព្យាយាមជួបជាមួយសមាជិកក្រុម យ៉ាងហោចណាស់ឲ្យបានម្តងទៅពីរដងនៅក្រៅម៉ោងនៃការពិភាក្សា។ ចូរប្រើពេលវេលានោះដើម្បីជួយពួកគេខាងឯការរីកចម្រើនខាងឯវិញ្ញាណ

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

និងដើម្បីជួយពិគ្រោះពីកង្វល់ និងសំណួរដែលពួកគេមាន ។

## ការអធិស្ឋាន

ចូរសួរសមាជិកក្រុមពីសំណូមពរអធិស្ឋានរបស់ពួកគេ ហើយអធិស្ឋានសម្រាប់ពួកគេមុនបញ្ចប់ការពិភាក្សា ។

**ការរំឭកខគម្ពីរចងចាំ**

ប្រសិនបើសមាជិកក្រុមរបស់លោកអ្នកបានយល់ព្រមទន្ទេញ ហើយនិងរំឭកខគម្ពីរជាមួយគ្នា ដូច្នេះសូមញែកពេលដើម្បីរំឭកខគម្ពីរនោះ ។ សូមរំឭកខគម្ពីរចងចាំនៅក្នុងសប្តាហ៍នេះ និងសប្តាហ៍មុនៗ ។

**គន្លឹះនៃការពិភាក្សា ៖** ស្តាប់ដោយយកចិត្តទុកដាក់បន្ថែមទៀត ការស្តាប់គឺជាជំនាញសំខាន់មួយក្នុងការដឹកនាំលើការពិភាក្សា ។ សូមស្តាប់ដោយយកចិត្តទុកដាក់ពីមតិយោបល់ដែលសមាជិកក្រុមចែកចាយជាពិសេសពីអារម្មណ៍របស់ពួកគេ ។ ចូរសួរសំណួរទាក់ទងទៅនឹង «អារម្មណ៍» របស់ពួកគេ ដើម្បីឲ្យបានយល់នូវអ្វីៗដែលលោកអ្នកបានឮបន្ថែមទៀត ។

*Pre-release គបស ស្បៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to [www.cambodianchristianresources.com/dfd-leaders/](www.cambodianchristianresources.com/dfd-leaders/)*

សៀវភៅទី៤
ជំពូកទី៣
**ភាពបរិសុទ្ធនៃជីវិត**

**គោលបំណងនៃជំពូកនេះគឺ៖** ដើម្បីឲ្យស្គាល់ពីសារៈសំខាន់ស្ដីពីក្រមសីលធម៌របស់ព្រះជាម្ចាស់នៅក្នុងទំនាក់ទំនងដែលយើងមានជាមួយអ្នកផ្សេងទៀត និងដើម្បីពឹងផ្អែកលើបទគម្ពីរទុកជាអំណាចក្នុងការរស់នៅតាមក្រមសីលធម៌ដ៏ត្រឹមត្រូវ ។

សំណួរដ៏ល្អៗមួយចំនួនសម្រាប់ការពិភាក្សាមានដូចជា សំណួរទី៤, ៦, ៧, ៩, ១០, ១៣, ១៥, ១៧និង២៣ ។

**ខ្នាតគំរូនៃព្រះជាម្ចាស់** (សំណួរទី១-៥)
លោកអ្នកអាចចាប់ផ្ដើមការពិភាក្សាដោយការអានសេចក្ដីផ្ដើមក្នុងជំពូកនេះ ឬអានសម្រង់សម្ដីរបស់អ្នកស្រី ស៊ូសាណា វេស្លី (Susanna Wesley) ។ បន្ទាប់មកលោកអ្នកអាចចាប់ផ្ដើមវគ្គដំបូងដោយសួរសំណួរទូទៅមានដូចជា «តើលោកអ្នកបានរកឃើញអ្វីខ្លះស្ដីពីខ្នាតគំរូនៃព្រះជាម្ចាស់ទុកសម្រាប់ភាពបរិសុទ្ធនៃជីវិតរបស់យើងចេញពីវគ្គដំបូងនេះ?»

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី៤

តើយើងអាចមានចិត្តបរិសុទ្ធបានដោយរបៀបណា?

តើយើងអាចធ្វើតាមខ្នាតគំរូដ៏ជាក់លាក់របស់ព្រះជាម្ចាស់បានដោយរបៀបណា?

**សារៈសំខាន់នៃភាពបរិសុទ្ធផ្ទាល់ខ្លួន** (សំណួរទី៦-១០)

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី៦, ៧, ៩និង១០

តើភាពមិនបរិសុទ្ធអាចប៉ះពាល់ទំនាក់ទំនងរបស់លោកអ្នកជាមួយនឹងព្រះជាម្ចាស់យ៉ាងដូចម្ដេច?

ហេតុអ្វីបានជាការប្រព្រឹត្តសេចក្ដីកំផិតគឺជាការខុសឆ្គង?

**គន្លងឆ្ពោះទៅរកភាពបរិសុទ្ធ** (សំណួរទី១១-១៨)

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី១៣, ១៥និង១៧

សូមចំណាយពេលពិភាក្សាលើសម្រង់សម្ដីរបស់លោក ក្រេក ហ្គ្រូស និង ម៉ៃក ហ្វូស្ទ័រ (Craig Gross and Mike Foster) ។

តើជំហានដំបូងនៃការឆ្ពោះទៅរកភាពបរិសុទ្ធគឺជាអ្វី?

តើការដែលយើងប្រដាប់ខ្លួនដោយព្រះអម្ចាស់យេស៊ូវមានន័យយ៉ាងដូចម្ដេច (រ៉ូម ១៣:១៤)?

**ទស្សនៈចំពោះអាពាហ៍ពិពាហ៍** (សំណួរទី១៩-២៤)

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី២៣

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៩១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

តើអាពាហ៍ពិពាហ៍រវាងបុរស និងស្ត្រីមានន័យយ៉ាងដូចម្ដេចនៅចំពោះព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់?

ហេតុអ្វីបានជាព្រះជាម្ចាស់ប្រៀបធៀបអាពាហ៍ពិពាហ៍ទៅនឹងទំនាក់ទំនងរវាងព្រះគ្រីស្ទនិងក្រុមជំនុំ (អេភេសូរ ៥:២១-៣៣)?

តើការប្រៀបធៀបនេះជះឥទ្ធិពលមកលើគំនិត និងអារម្មណ៍របស់លោកអ្នកពីភាពបរិសុទ្ធយ៉ាងដូចម្ដេច?

## ការបញ្ចប់កិច្ចពិភាក្សា

បើទោះជាវគ្គ ចូលឲ្យបានស៊ីជម្រៅជាជម្រើសនៃជំពូកនីមួយៗក៏ដោយ ក៏ក្រុមរបស់លោកអ្នកទទួលបានប្រយោជន៍ចេញពីការអានជាមួយគ្នា និងការពិភាក្សាពីវិធីផ្សេងៗ ដើម្បីឲ្យលោកអ្នកអាចចៀសចេញពីអន្ទាក់របស់បាបខាងផ្លូវភេទ ។

វិធីដ៏ល្អក្នុងការបញ្ចប់វគ្គនីមួយៗគឺ សង្ខេបនូវអ្វីដែលលោកអ្នកបានពិភាក្សា ហើយលើកទឹកចិត្តសមាជិកក្រុមដោយចែកចាយពីសារៈសំខាន់របស់ប្រធានបទនេះជាមួយពួកគេ បន្ទាប់មកចូរបញ្ចប់ដោយការអធិស្ឋានជាមួយគ្នា ។

## ការអធិស្ឋាន

នៅក្នុងជំពូកនេះ សមាជិកក្រុមនឹងចែកចាយនូវរឿងរ៉ាវនៃជីវិតផ្ទាល់ខ្លួនរបស់ពួកគេម្នាក់ៗ ប្រហែលជាមានអ្នកខ្លះក៏មានការខ្មាសអៀននឹងរឿងអតីតកាលរបស់គេ ឬក៏មានអ្នកខ្លះទៀតក៏

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៩៩០៤៩១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

កំពុងជួបប្រទះរឿងឈឺចាប់នៅឡើយ ព្រោះពួកគេបានឆ្លងកាត់ទុក្ខលំបាកផ្សេងៗជាច្រើនផង ។ ជាការល្អ ប្រសិនបើយើងពង្រឹងបន្ថែមនូវទំនុកចិត្តលើអ្វីដែលសមាជិកក្រុមបានប្ដេជ្ញាចិត្តដោយសន្យាថានឹងមិនប្រាប់រឿងរ៉ាវនេះដល់អ្នកដទៃទៀតក្រៅពីអ្នកនៅក្នុងក្រុមឡើយ ។

## ការរំឭកខគម្ពីរចងចាំ

ប្រសិនបើសមាជិកក្រុមរបស់លោកអ្នកបានយល់ព្រមទន្ទេញ ហើយនិងរំឭកខគម្ពីរជាមួយគ្នា ដូច្នេះសូមញែកពេលដើម្បីរំឭកខគម្ពីរនោះ ។ សូមរំឭកខគម្ពីរចងចាំនៅក្នុងសប្ដាហ៍នេះ និងសប្ដាហ៍មុនៗ ។ បន្ទាប់ចូរសួរសមាជិកក្រុមថា តើខគម្ពីរចងចាំបានជួយពួកគេយ៉ាងដូចម្ដេចក្នុងអំឡុងសប្ដាហ៍មុននេះ?

**គន្លឹះនៃការពិភាក្សា ៖ ជឿជាក់ព្រះជាម្ចាស់នឹងជួយបំផ្លាស់បំប្រែ**

ការលូតលាស់ដ៏ពិតខាងឯវិញ្ញាណគឺមកពីព័ន្ធកិច្ចរបស់ព្រះវិញ្ញាណបរិសុទ្ធ ។ ចូរទូលសូមព្រះជាម្ចាស់ឲ្យជួយលោកអ្នក និងសមាជិកក្រុមឲ្យចេះឆ្លើយតបដោយស្ម័គ្រចិត្តទៅនឹងរបៀបដែលព្រះជាម្ចាស់បំផ្លាស់បំប្រែអត្តចរិតរបស់លោកអ្នកទាក់ទងទៅនឹងភាពបរិសុទ្ធរបស់លោកអ្នកផ្ទាល់ ។ ព្រមទាំងជឿថា ព្រះជាម្ចាស់នឹងបំផ្លាស់បំប្រែជីវិតលោកអ្នកមែន ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

សៀវភៅទី៤

ជំពូកទី៤

**ភាពស្អាតស្អំក្នុងការរស់នៅ**

**គោលបំណងនៃជំពូកនេះគឺ៖** ដើម្បីអនុវត្តនូវភាពស្មោះត្រង់ និងភាពដែលអាចទុកចិត្តបាននៅក្នុងគ្រប់ទាំងផ្នែកនៃជីវិតរបស់យើង ។

ស្នើសុំសមាជិកក្រុមអានពីរឿងរ៉ាវនៃជីវិតរបស់លោកយ៉ូសែបដែលមាននៅក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ជំពូក ៣៧-៥០ ទុកជាការអានបន្ថែមមួយ ។ លោកអ្នកអាចពិភាក្សាលើការនេះនៅម៉ោងសិក្សាបន្ទាប់ទៀត ។

សូមចងចាំថា វិធីសាស្ត្រនៃការពិភាក្សានឹងមិនមានដំណើរការនោះទេ លុះត្រាតែសមាជិកក្រុមរបស់លោកអ្នកចំណេះដឹងក្នុងការចែកចាយ ។ សូមលើកទឹកចិត្តសមាជិកក្រុមឲ្យរៀបចំការសិក្សារៀងរាល់អាទិត្យ ហើយសូមរក្សាពេលវេលានៃការពិភាក្សាឲ្យផ្តោតទៅលើអ្វីដែលព្រះបន្ទូលបានចែង និងពីរបៀបដែលពួកគេនឹងយកមកអនុវត្តជាប្រចាំថ្ងៃ ។

សំណួរដ៏ល្អៗមួយចំនួនសម្រាប់ការពិភាក្សាមានដូចជា សំណួរទី៤, ៧, ១១, ១៤, ១៦, ១៧និង១៨ ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៩១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to [www.cambodianchristianresources.com/dfd-leaders/](www.cambodianchristianresources.com/dfd-leaders/)*

**ការតយុទ្ធដើម្បីភាពស្អាតស្អំ** (សំណួរទី១-៥)

ដូចដែលមាននៅក្នុងជំពូកមុនៗ ឃើញថា ប្រធានបទនេះបាននាំលោកអ្នក និងសមាជិកក្រុមឲ្យស្វែងយល់ពីលក្ខណៈនៃអត្តចរិតផ្ទាល់ខ្លួនមួយចំនួនដែលយើងគ្រប់គ្នាខិតខំតយុទ្ធ ។ បន្ទាប់ពីឲ្យអ្នកណាម្នាក់អានសេចក្ដីផ្ដើមរួចមក លោកអ្នកអាចចាប់ផ្ដើមការពិភាក្សាដោយសួរសំណួរទូទៅមួយស្ដីពីការតយុទ្ធដើម្បីភាពស្អាតស្អំរបស់សមាជិកក្រុមដូចជា «តើមានអ្វីដែលបានប៉ះពាល់ចិត្តលោកអ្នកនៅក្នុងវគ្គដំបូងនេះស្ដីពី ការតយុទ្ធដើម្បីភាពស្អាតស្អំដែលមនុស្សគ្រប់គ្នាជួបប្រទះ?»

**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី៤

តាមការយល់ឃើញរបស់លោកអ្នកសូមគិតទៅមើលថា ហេតុអ្វីបានជាការតយុទ្ធដើម្បីរក្សាភាពស្អាតស្អំរបស់យើងមានការពិបាកម្ល៉េះ?

ហេតុអ្វីបានជាចិត្តយើងមានងាយស្រួលធ្លាក់ចូលក្នុងការបញ្ឆោត?

តើអ្វីទៅជាការតយុទ្ធដ៏ធំបំផុតក្នុងការរក្សាភាពស្អាតស្អំ?

**ការប្រកាសពីកង្វះខាតនៃភាពស្អាតស្អំ** (សំណួរទី៦-១១)

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី៧និង១១

តើអ្វីទៅជាបញ្ញាចិត្តរបស់យើង?

តើបញ្ញាចិត្តបានពញ្ញាក់អារម្មណ៍យើងយ៉ាងដូចម្ដេច?

តាមការយល់ឃើញរបស់លោកអ្នកសូមគិតទៅមើលថា ហេតុអ្វីបានជាព្រះយេស៊ូវសង្កត់ធ្ងន់ទៅលើការមានពុតខ្លាំងម្ល៉េះ?

តើលោកអ្នកឆ្លើយតបទៅនឹងការមានពុតរបស់អ្នកផ្សេងទៀតយ៉ាងដូចម្ដេច? ចុះការមានពុតរបស់លោកអ្នកវិញ យ៉ាងណាដែរ?

**ការអនុវត្តសេចក្ដីទៀងត្រង់** (សំណួរទី១២-១៤)

**សំណើនៃការពិភាក្សា៖** សំណួរទី១៤

តើមានពេលណាមួយដែលអ្នកជឿព្រះយេស៊ូវមិនគួរចុះចូលចំពោះអំណាចអ្នកដឹកនាំដែរឬទេ? បើមាន តើពេលណាទៅ?

**ភាពទៀងត្រង់ក្នុងការនិយាយស្ដី** (សំណួរទី១៥-២១)

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី១៦, ១៧និង១៨

ហេតុអ្វីបានជាការនិយាយស្ដីចាប់ផ្ដើមពីក្នុងដួងចិត្តទៅវិញ? តើការនិយាយស្ដីរបស់យើងបានបង្ហាញឲ្យអ្នកដទៃដឹងពីលក្ខណៈរបស់យើងដោយរបៀបណា?

## ការបញ្ចប់កិច្ចពិភាក្សា

សូមជ្រើសរើសវិធីសាស្ត្រផ្សេងៗដែលលោកអ្នកអាចប្រើដើម្បីបញ្ចប់ការពិភាក្សា ។ លោកអ្នកអាចសួរយ៉ាងដូច្នេះ៖ «ហេតុអ្វីបានជាលោកអ្នកជឿថា លោកអ្នកគួរតែបង្ហាញភាពទៀងត្រង់គ្រប់ទាំងផ្នែកនៃជីវិតរបស់លោកអ្នក?» ឬក៏លោកអ្នកអាចស្នើសុំសមាជិកក្រុមមួយចំនួនឲ្យពួកគេចែកចាយពីការអនុវត្តផ្ទាល់ខ្លួនដោយសួរថា «តើព្រះបន្ទូលបានប៉ះពាល់ចិត្តរបស់លោកអ្នកតាមរបៀបណាខ្លះក្នុងសប្ដាហ៍នេះ ស្របពេលដែលលោកអ្នកសញ្ជឹងគិតលើព្រះបន្ទូលដែលលោកអ្នកបានសិក្សារួចមកហើយ? តើលោកអ្នកអាចអនុវត្តអ្វីៗដែលបានប៉ះពាល់ចិត្តនៅសប្ដាហ៍បានដោយរបៀបណា?»

ឬក៏ លោកអ្នកអាចសួរសមាជិកក្រុមឲ្យផ្ដល់មតិយោបល់ទៅលើរូបភាពផ្សេងៗទៀត ប្រសិនបើលោកអ្នកមិនបានប្រើប្រាស់វិធីសាស្ត្រនេះជាយូរមកហើយ ។

## ការអធិស្ឋាន

សូមកុំភ្លេចចែកចាយនូវចម្លើយនៃការអធិស្ឋាន និង

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៩៩០៤៩១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

ហេតុផលដែលយើងត្រូវសរសើរតម្កើងព្រះជាម្ចាស់ ក៏ដូចជា សំណូមពរអធិស្ឋានផ្សេងៗទៀតផងដែរ ។ ប្រធានបទនេះក៏នឹង ដឹកនាំយើងឲ្យមានពេលវេលាមួយ ដើម្បីឲ្យយើងលន់តួបាបដល់ ព្រះជាម្ចាស់ ។ ព្រះបន្ទូលក៏បានលើកទឹកចិត្តយើងឲ្យចេះលន់តួបាប ទៅគ្នាទៅវិញទៅមក ក៏ដូចជាទៅព្រះជាម្ចាស់ដែរ ពីព្រោះការនេះ នាំយើងចេញពីសេចក្តីងងឹត ហើយចូលទៅក្នុងពន្លឺ ។ ប្រសិនបើ មានសមាជិកក្រុមណាម្នាក់របស់លោកអ្នកចង់ផ្សះផ្សាជាមួយអ្នកណា ម្នាក់ ឬក៏ចង់ចាប់ផ្តើមដើរក្នុងភាពស្អាតស្អំ នោះសូមលោកអ្នកជួយ ពួកគេក្នុងការទាំងនោះ ។

## ការរំឭកខគម្ពីរចងចាំ

ប្រសិនបើក្រុមរបស់លោកអ្នកបានយល់ព្រមទន្ទេញ ហើយនិងរំឭកខគម្ពីរជាមួយគ្នានោះ សូមកុំភ្លេចទុកពេលខ្លះសម្រាប់ ការរំឭកសារឡើងវិញផង មិនថានៅចុងបញ្ចប់នៃការពិភាក្សា ឬ ការចាប់ផ្តើមនោះទេ ។ ហើយប្រសិនបើលោកអ្នកនៅមាន ពេលវេលា នោះសូមស្នើសុំឲ្យសមាជិកក្រុមចែកចាយពីរបៀបដែល ខគម្ពីរចងចាំបានជួយពួកគេក្នុងអំឡុងសប្តាហ៍នេះ ។ ដោយសារតែ សៀវភៅទី៤នេះនៅសល់តែមួយជំពូកទៀត ដូច្នេះចូរចំណាយពេល

Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០
Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information,
come back to www.cambodianchristianresources.com/dfd-leaders/

បន្ថែមទៀត ដើម្បីរំឭកខគម្ពីរចងចាំទាំងបួន បន្ទាប់មកសូមប្រាប់ពួកគេឲ្យត្រៀមខ្លួន ដើម្បីឡើងសូត្រខគម្ពីរទាំងប្រាំនៅសប្ដាហ៍ក្រោយ ។

**គន្លឹះនៃការពិភាក្សា ៖ គិតពិចារណាលើការចាប់ផ្ដើមបង្កើតក្រុមថ្មី**

ឥឡូវនេះប្រហែលជាពេលដែលត្រូវចាប់ផ្ដើមក្រុមថ្មីហើយ ។ ខាងក្រោមនេះគឺជាសំណើក្នុងការចាប់ផ្ដើម ៖ ស្នើសុំសមាជិកពីរនាក់នៅក្នុងក្រុមឲ្យអធិស្ឋានដោយពិចារណាទៅលើការចាប់ផ្ដើមក្រុមថ្មី ។ សូមសួរពួកគេថា ប្រសិនបើពួកគេមានមិត្រភក្ដិ ហើយមិត្រភក្ដិនោះមានមិត្រភក្ដិផ្សេងទៀត នោះសូមឲ្យពួកគេអញ្ជើញមិត្រភក្ដិទាំងនេះមកចូលរួមដើម្បីចាប់ផ្ដើមក្រុមថ្មី ។ ហើយលោកអ្នកក៏អាចធ្វើជាអ្នកស្ដាប់ នៅពេលដែលពួកគេមានសំណួរផ្សេងៗក្នុងការចាប់ផ្ដើម ។


*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

សៀវភៅទី៤

ជំពូកទី៥

**ការអភិវឌ្ឍផ្នែកអត្តចរិតក្នុងការរងទុក្ខ**

**គោលបំណងនៃជំពូកនេះគឺ៖** ដើម្បីឲ្យដឹងថា ព្រះជាម្ចាស់អនុវត្តឲ្យមានការរងទុក្ខក្នុងជីវិតរស់នៅរបស់យើង ដើម្បីជួយបង្កើតអត្តចរិតដូចព្រះជាម្ចាស់នៅក្នុងជីវិតយើង និងដើម្បីឲ្យយើងចេះអរព្រះគុណដល់ទ្រង់ក្នុងគ្រប់កាលៈទេសៈទាំងអស់ ។

ដោយសារតែនេះជាជំពូកចុងក្រោយក្នុងសៀវភៅទី៤ ដូច្នេះចូរចំណាយពេលបន្ថែមទៀត ដើម្បីរំឭកខគម្ពីរចងចាំទាំងប្រាំនៅក្នុងការចាប់ផ្តើមនៃការពិភាក្សានេះ និងដើម្បីជំរុញចិត្តសមាជិកក្រុមឲ្យព្យាយាមហ្វឹកហាត់ការដាក់វិន័យដ៏មានតម្លៃនៃការកំណត់ចាំព្រះបន្ទូលទ្រង់ទុកនៅក្នុងចិត្តរបស់ពួកគេ ។

នៅពេលដែលលោកអ្នកពិភាក្សាលើប្រធានបទនេះ សូមព្យាយាមញែកឲ្យឃើញភាពខុសគ្នារវាងការរងទុក្ខសម្រាប់ព្រះគ្រីស្ទ និងការរងទុក្ខដោយសារតែយើងរស់នៅក្នុងលោកីយ៍ដែលធ្លាក់ក្នុងបាប និងជាមួយមនុស្សបាប និងការរងទុក្ខដែលជាផលនៃការប្រព្រឹត្តខុសរបស់យើង ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

សំណួរល្អៗសម្រាប់ពិភាក្សា មានដូចជា សំណួរទី២, ៣, ៤, ៩, ១១, ១៩, ២០និង២១ ។

**ការគ្រប់គ្រងដ៏ធំបំផុតរបស់ព្រះជាម្ចាស់** (សំណួរទី១-៤)
នៅពេលដែលលោកអ្នកចាប់ផ្តើមពិភាក្សាលើប្រធានបទនេះ នោះសូមចងចាំថា ការប្រើប្រាស់វិធីសួរសំណួរដ៏ស្ទាត់ជំនាញគឺជាវិធីដ៏សំខាន់មួយ ដើម្បីទទួលបានជ័យជម្នះក្នុងការពិភាក្សា ។ សូមរៀបចំសំណួររបស់លោកអ្នកដោយយកចិត្តទុកដាក់ ។ ឧទាហរណ៍ បន្ទាប់ពីលោកអ្នកបានស្នើសុំឲ្យអ្នកណាម្នាក់អានសេចក្តីផ្តើមនៃជំពូក នោះលោកអ្នកអាចចាប់ផ្តើមដោយសួរសំណួរទូទៅមួយដូចជា «តើមានអ្វីដែលបានប៉ះពាល់ចិត្តលោកអ្នកខ្លាំងជាងគេបំផុតស្តីពីការគ្រប់គ្រងដ៏ធំបំផុតរបស់ព្រះជាម្ចាស់ចេញពីបួនសំណួរដំបូងនេះ?»

**សំណើសម្រាប់ការពិភាក្សា ៖** សំណួរទី២, ៣និង៤

តើកណ្ឌគម្ពីរ លោកុប្បត្តិ ៥០:២០ បានបង្ហាញអ្វីខ្លះស្តីពីអត្តចរិតរបស់លោក យ៉ូសែប?

តើឃ្លាថា គ្រប់ការទាំងផ្សំគ្នាសម្រាប់សេចក្តីល្អដល់ពួកអ្នកដែលស្រឡាញ់ព្រះជាម្ចាស់មានន័យយ៉ាងដូចម្តេច?

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

**គោលបំណងក្នុងការរងទុក្ខ** (សំណួរទី៥-៩)

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី៩

ហេតុអ្វីបានជាអ្នកដើរតាមព្រះយេស៊ូវត្រូវរងទុក្ខ?

តើមានការរងទុក្ខអ្វីខ្លះដែលយើងប្រហែលនឹងត្រូវប្រឈមមុខ?

**ការឆ្លើយតបរបស់លោកអ្នកចំពោះការរងទុក្ខ** (សំណួរទី១០-១៨)

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី១១

ហេតុអ្វីបានជាអាកប្បកិរិយានៅក្នុងជីវិតរបស់យើងមានសារៈសំខាន់?

នៅពេលដែលលោកអ្នករងទុក្ខ តើវាជាការត្រឹមត្រូវប្រសិនបើយើងសួរព្រះជាម្ចាស់ថា «ហេតុអ្វីបានជាខ្ញុំត្រូវរងទុក្ខ?» សូមពន្យល់៖

**ការលូតលាស់តាមរយៈការរងទុក្ខ** (សំណួរទី១៩-២២)

**សំណើសម្រាប់ការពិភាក្សា៖** សំណួរទី១៩, ២០និង២១

ហេតុអ្វីបានជាសេចក្តីទុក្ខលំបាកបង្កើតឲ្យមានសេចក្តីទ្រាំទ្រ សេចក្តីទ្រាំទ្របង្កើតឲ្យមានសេចក្តីសាំុថ្មឹក សេចក្តីសាំុថ្មឹកបង្កើតឲ្យមានសេចក្តីសង្ឃឹម?

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to [www.cambodianchristianresources.com/dfd-leaders/](www.cambodianchristianresources.com/dfd-leaders/)*

តើព្រះជាម្ចាស់ផ្ចាញ់ផ្ចាលយើងនៅពេលណា?

តើព្រះជាម្ចាស់លួងលោមយើងដោយរបៀបណា?

តើលោកអ្នកធ្លាប់រងទុក្ខយ៉ាងដូចម្ដេចដែរ? តើការនេះបានប៉ះពាល់ទំនាក់ទំនងរបស់លោកអ្នកជាមួយព្រះជាម្ចាស់យ៉ាងដូចម្ដេច?

## ការបញ្ចប់កិច្ចពិភាក្សា

សូមជ្រើសរើសជម្រើស **ក** ចេញពីវគ្គ **ការចូលឲ្យបានស៊ីជម្រៅ** មកប្រើដើម្បីបញ្ចប់ការពិភាក្សាជាមួយគ្នា ។ ក្នុងការបញ្ចប់ការពិភាក្សានេះ លោកអ្នកក៏អាចជ្រើសរើសយកចំណុចនៃការសង្ខេប ការអនុវត្តផ្ទាល់ខ្លួន ឬក៏មតិយោបល់លើរូបភាព ឬសម្រង់សម្ពីនៅក្នុងជំពូកនេះក៏បាន ។ ប្រសិនបើសមាជិកក្រុមរបស់លោកអ្នកណាមួយដែលធ្លាប់ប្រឈមមុខ ឬក៏កំពុងតែប្រឈមមុខទៅនឹងការរងទុក្ខដ៏ពិបាក នោះសូមលោកអ្នកត្រៀមខ្លួនជាស្រេចដើម្បីទៅកំសាន្តចិត្ត និងត្រូវពីអារម្មណ៍នៃការរងទុក្ខរបស់ពួកគេព្រមទាំងអធិស្ឋានសម្រាប់ពួកគេផងដែរ ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*

## ការរំឭកខគម្ពីរចងចាំ

ប្រសិនបើក្រុមរបស់លោកអ្នកបានយល់ព្រមទន្ទេញ ហើយនិងរំឭកខគម្ពីរជាមួយគ្នានោះ សូមកុំភ្លេចទុកពេលខ្លះសម្រាប់រំឭកខគម្ពីរចងចាំទាំងប្រាំចេញពីសៀវភៅនេះឡើងវិញ ។ ហើយសូមលើកទឹកចិត្តពួកគេឲ្យរំឭកមេរៀនចាស់ និងខគម្ពីរចងចាំពីសៀវភៅផ្សេងៗពីមុនផងដែរ ។ គន្លឹះដើម្បីចងចាំខគម្ពីរនោះគឺត្រូវរំឭកហើយរំឭកទៀត!

## ការរំឭកឡើងវិញនិងការអធិស្ឋាន

ដោយសារតែជំពូកនេះ គឺជាជំពូកចុងក្រោយនៃសៀវភៅទី៤ ដូច្នេះសូមចំណាយពេលខ្លះ ដើម្បីរំឭកពីមេរៀនដែលយើងបានសិក្សាកាលពីសប្តាហ៍មុនៗ ។ សូមលើកទឹកចិត្តសមាជិកក្រុមឲ្យបន្តសិក្សាសៀវភៅទី៥ ។ លោកអ្នកអាចសួរសំណួរដូចជា ៖

«តើលោកអ្នកចូលចិត្តអ្វីខ្លះនៅក្នុងសៀវភៅទី៤?»

«តើមានអ្វីដែលបានប៉ះពាល់ចិត្តលោកអ្នកខ្លាំងជាងគេបំផុតចេញពីការសិក្សាក្នុងសប្តាហ៍នេះ?»

«តើលោកអ្នកចង់បន្តការសិក្សានៅក្នុងសៀវភៅទី៥ដែរឬទេ?»

«តើមានអ្វីដែលយើងគួរផ្លាស់ប្តូរ ដើម្បីជួយឲ្យពេលវេលានៃ

Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០
Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/

ការសិក្សារបស់កាន់តែប្រសើរដែរឬទេ?»
បន្ទាប់មកសូមចែកសៀវភៅទី៥ឲ្យដល់អ្នកដែលចង់បន្ត ហើយយល់ព្រមធ្វើលំហាត់នៅក្នុងសៀវភៅមេរៀន និងការរៀបចំជួបប្រជុំផ្សេងៗ ។ ចូរបញ្ចប់ការសិក្សាដោយការអធិស្ឋាន ។

**គន្លឹះនៃការពិភាក្សា ៖ ការផ្លាស់ប្តូរទីតាំង**

មួយរយៈកន្លងមកនេះឃើញថា ក្រុមទាំងឡាយហាក់ដូចជាមានភាពសាំទៅនឹងរបៀបនៃការសិក្សាជាមួយគ្នា ជាការល្អប្រសិនបើយើងផ្លាស់ប្តូរទីតាំងជួបពិភាក្សាគ្នាដែលវាអាចនឹងជួយឲ្យការពិភាក្សារបស់លោកអ្នកកាន់តែប្រសើរឡើង ។ ការផ្លាស់ប្តូរទីតាំងអាចជួយឲ្យក្រុមរបស់លោកអ្នកកាន់តែមានការរីកចម្រើនខ្លាំងឡើងៗ ។ លោកអ្នកអាចប្តូរទីតាំងនៃការពិភាក្សាទៅផ្ទះរបស់សមាជិកក្រុមណាម្នាក់ក៏បានដែរ ។

*Pre-release គបស សៀវភៅសម្រាប់គ្រូ / ISBN ៩៧៨-០-៩៨៩០៤៨១-៧-០*
*Copyright © ២០១៣ NavPress Publishing. All rights reserved. For purchase information, come back to www.cambodianchristianresources.com/dfd-leaders/*